# ការកាន់កាប់ដីនៅកម្ពុជា

## ការវិភាគលើទិន្នន័យចុងក្រោយ

### ឯកសាពិភាក្សាលេខ ១៩

ច័ន្ទ សុផល  ទេព សារ៉ាវី  និង  Sarthi Acharya

វិទ្យាស្ថានបណ្តុះបណ្តាល  និង  ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ភ្នំពេញ  ខែធ្នូ  ឆ្នាំ២០០១

© រក្សាសិទ្ធិឆ្នាំ២០០១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជាៈ អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISSN 1560 9812

**ការកាន់កាប់ដីនៅកម្ពុជាៈ ការវិភាគលើទិន្នន័យចុងក្រោយ — ឯកសារពិភាក្សាលេខ ១៩ ខែធ្នូ ឆ្នាំ២០០១**

*ច័ន្ទ-សុផល ទេព-សារ៉ាវី និង* ***Sarthi Acharya***

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទៈ (៨៥៥-២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារៈ (៨៥៥-២៣) ៣៦៦-០៩៤
អ៊ីមែលៈ **cdri@camnet.com.kh** **website: http://www.cdri.org.kh**

កែសម្រួល និងរចនាដោយៈ យូ សិទ្ធីរិទ្ធ អ៊ុំ ចាន់ថា និង អែម សូវ៉ានី
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន ផ្ទះលេខ៧៤ ផ្លូវលេខ៩៩ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

# មាតិកា


សម្រង់អត្ថបទ......i
បញ្ជីអក្សរកាត់......v
សេចក្តីថ្លែងអំណរគុណ......vii

**ជំពូកមួយ. សេចក្តីផ្តើម**......១
១.១. បុព្វកថា......១
១.២. គោលដៅ......១
១.៣. វិធីសាស្ត្រ......២
១.៤. រចនាសម្ព័ន្ធរបាយការណ៍......៣

**ជំពូកពីរ. ការប្រើប្រាស់ដីធ្លី**......៥
២.១. ចំណាត់ថ្នាក់ដីធ្លី......៥
២.២. ការប្រើប្រាស់ដីសំរាប់ដាំដំណាំផ្សេងៗ......៧
២.៣. ផ្ទៃដីដែលមានមីន......១២

**ជំពូកបី. ដីសម្បទាន**......១៧
៣.១. ប្រព័ន្ធផ្តល់សម្បទាន......១៧
៣.២. ការផ្តល់ព្រៃសម្បទាន......១៧
៣.៣. សម្បទានកសិកម្ម......១៧
៣.៤. តួនាទីរបស់យោធាក្នុងការផ្តល់ដីសម្បទាន......២៦
៣.៥. មូលហេតុដែលក្រុមហ៊ុនមិនអនុវត្តកិច្ចសន្យា......២៦
៣.៦. ឡូតិ៍នៃសាទសម្បទាន......២៦
៣.៧. ទស្សនៈស្តីពីការគ្រប់គ្រងដីធ្លី......២៩

**ជំពូកបួន. រដ្ឋបាលដីធ្លី: ការទទួលខុសត្រូវ និងការផ្តល់បំណ្ណកម្មសិទ្ធិ**......៣១
៤.១. សាវតារ......៣១
៤.២. ការចុះបញ្ជីចោះៗ......៣២
៤.៣. ការចុះបញ្ជីជាប្រព័ន្ធ......៣៣

**ជំពូកប្រាំ. ការពិពណ៌នាពីទិន្នន័យដែលទាក់ទងនឹងការកាន់កាប់ និងគ្រប់គ្រងដីធ្លី** ..................... ៣៧
៥.១. អង្កេត MRC-95-96 ..................... ៣៧
៥.២. អង្កេត SES-96 ..................... ៣៨
៥.៣. អង្កេត SES-97 ..................... ៣៨
៥.៤. អង្កេត UNICEF-WFP (Baseline-98) ..................... ៣៨
៥.៥. អង្កេត PET-98 ..................... ៣៩
៥.៦. អង្កេត SES-99 ..................... ៤០
៥.៧. អង្កេត Follow-up-00 ..................... ៤១
៥.៨. អង្កេត LADIT-00 ..................... ៤១

**ជំពូកប្រាំមួយ. លទ្ធផលសំខាន់ៗស្តីពីការកាន់កាប់ដីប្រមូលបានពីអង្កេតនៅមូលដ្ឋាន** ..................... ៤៣
៦.១. ចំនួន ទំហំដីកសិកម្មជាមធ្យម និងដីលំនៅដ្ឋាន ..................... ៤៣
៦.២. ការទទួលបានដី ..................... ៤៨
៦.៣. ការកាន់កាប់ដីធ្លី ..................... ៤៨
៦.៤. សិទ្ធិកាន់កាប់ដីធ្លី ..................... ៥១
៦.៥. ភាពគ្មានដីធ្លី ..................... ៥៣
៦.៦. ការជួលដី ..................... ៥៦
៦.៧. វិសមភាពដីធ្លី ..................... ៥៦

**ជំពូកប្រាំពីរ. ទិដ្ឋភាពផ្សេងៗនៃការកាន់កាប់ដីកសិកម្ម** ..................... ៦១
៧.១. ការកាន់កាប់ដី និងកំរិតជីវភាព - តារាងមានអញ្ញាតពីរ ..................... ៦១
៧.២. ការវិភាគមានអញ្ញាតច្រើន ..................... ៦៤

**ជំពូកប្រាំបី. សេចក្តីសន្និដ្ឋាន** ..................... ៦៧

ឯកសារយោង ..................... ៦៩
សេចក្តីបន្ថែម ..................... ៧១
បញ្ជីឯកសាររបស់ វិបសអ ..................... ៧៥

# សម្រង់អត្ថបទ

១. ជាបឋមរបាយការណ៍នេះមានបំណងបង្ហាញពីរបៀបបែងចែកដីធ្លីសំរាប់ការប្រើប្រាស់ផ្សេងៗ បន្ទាប់មកពិនិត្យមើលទិន្នន័យស្តីពីដីសម្បទាន និងឡូត៍នៃសាទសម្បទាន ។ ការចុះបញ្ជីដីធ្លី ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ និងទិន្នន័យ នឹងត្រូវពិនិត្យជាបន្ទាប់មកទៀត ។ ចុងក្រោយបំផុត គឺជាការគណនាឡើងវិញ និងការបកស្រាយនូវទិន្នន័យបានមកពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចចំនួន ៨ ដែលបានធ្វើឡើងនៅប្រទេសកម្ពុជានាឆ្នាំថ្មីៗកន្លងទៅ ដើម្បីវិភាគលើពតិមាននានាស្តីពីដីធ្លី ។ ការប្រឹងប្រែងនៅក្នុងផ្នែកនេះ គឺដើម្បីរាប់ចំនួនដីធ្លីនៅក្នុងប្រទេស គណនាទំហំដីជាមធ្យម ធ្វើការប៉ាន់ស្មានពីចំនួនអ្នកគ្មានដីធ្លី វិសមភាពខាងដីធ្លី និងធ្វើការប៉ាន់ស្មានជាដំបូងមួយពីចំណងទាក់ទងរវាងភាពក្រីក្រ និងភាពគ្មានដីធ្លី ។

២. ទិន្នន័យសេដ្ឋកិច្ចដ៏ទូលាយមួយស្តីពីការប្រើប្រាស់ដីធ្លីសំរាប់ឆ្នាំថ្មីៗនេះ ត្រូវបានគេផ្សព្វផ្សាយក្នុងឆ្នាំ១៩៩២-៩៣ និង ១៩៩៦-៩៧ ។ គេបង្កើតទិន្នន័យទាំងនេះឡើងតាមការវាស់វែង និងគណនា ដោយប្រើផែនទីដែលគូសចេញពីរូបភាពថតពីលើអាកាស និងពីផ្កាយរណប ។ ទោះបីជាការពិពណ៌នាតាមពតិមានទាំងនេះហាក់ដូចជាបានត្រឹមត្រូវគួរសមក៏ដោយ ក៏នៅមានបញ្ហាចោទនៃការគណនាតួលេខសរុបក្នុងតារាងទិន្នន័យមួយចំនួន ។ បញ្ហាទាំងនេះកើតមានឡើងនៅពេលដែលផែនទីមានគំនូសលំអិតតូច (detailed cartographic maps) ដែលធ្វើឡើងដើម្បីបន្ស៊ីនូវចំនុចខុសគ្នាតូចៗ វាមិនស៊ីគ្នានឹងរូបភាពថតពីលើអាកាស ។ បញ្ហាបន្ទាប់មកទៀត គឺមានពតិមានខុសគ្នាច្រើនស្តីពីការផ្តល់ដីសម្បទាន ដែលបណ្តាលមកពីការពុំមានទិន្នន័យសមស្របស្តីពីដែនសាធារណៈ ។ ភ្នាក់ងារខុសៗគ្នា ប្រើប្រាស់វិធីផ្សេងៗគ្នាក្នុងការប្រគល់ដីសម្បទានកសិកម្ម ។ ជាលទ្ធផលទិន្នន័យមកពីប្រភពផ្សេងគ្នាអាចមិនស៊ីគ្នា ឬមិនអាចប្រៀបធៀបគ្នាតាមពេលវេលាពីឆ្នាំមួយទៅឆ្នាំមួយបានទេ ។ អវត្តមាននូវការិយាល័យកណ្តាលដែលអាចប្រមូល និងផ្តុំទិន្នន័យតាមលំដាប់ និងច្របាច់បញ្ចូលគ្នានូវកំរងទិន្នន័យផ្សេងៗ គឺជាបញ្ហាចំបងមួយ ។

៣. ដីភាគច្រើននៅក្នុងប្រទេសមិនទាន់បានចុះបញ្ជី និងកំណត់កម្មសិទ្ធិនៅឡើយ ។ នៅកំរិតតួលេខសរុបធំៗ មិនទាន់បានធ្វើនៅឡើយទេនូវការកំណត់ព្រំប្រទល់ រវាងផ្ទៃដីដែលស្ថិតនៅក្រោមការប្រើប្រាស់ខុសៗគ្នា ដូចជា ដីព្រៃ ដីកសិកម្ម តំបន់ទីក្រុង ។ល។ បន្ទាប់មកទៀត គេចាំបាច់ត្រូវកំណត់ព្រំខ័ណ្ឌសីមានៃស្រុក ឃុំ និងស្ថាប័នរដ្ឋបាលផ្សេងទៀត ។ សំរាប់ដីកាន់កាប់ជាឯកជន ក្នុងចំណោម ៤,៥លាននៃពាក្យសុំដែលមានបង្កាន់ដៃ គឺមានតែជាងកន្លះលានបន្តិចប៉ុណ្ណោះដែលគេបានចេញប័ណ្ណកម្មសិទ្ធិឱ្យ ។ ដូច្នេះការកកស្ទះក្នុងកិច្ចការនេះ វាមានទំហំធំធេងណាស់ ។

៤. តាមការប៉ាន់ស្មានក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ កម្ពុជាមានប្រជាជនសរុប ២.០៩៣.១៩២គ្រួសារ ក្នុងនេះ ១.៧៨២.៣៩០គ្រួសាររស់នៅតាមជនបទ ហើយអ្នកនៅសល់គឺជាប្រជាជនរស់នៅតាមតំបន់ទីប្រជុំជននានា ។ ប៉ុន្តែតួលេខនេះខុសពីតួលេខជំរឿនប្រជាជននៅឆ្នាំ១៩៩៨ ដែលបានកត់ត្រារហូតដល់ ២.១៨៨.៦៦៣គ្រួសារ ។ ដីកសិកម្មសរុបទាំងអស់មាន ៣,៩១លានហិកតារ នៅឆ្នាំ១៩៩៦-៩៧ ប៉ុន្តែគេមិនបានដឹងច្បាស់ថា តើដីទាំងអស់នេះត្រូវបានគេប្រើសំរាប់ដាំដុះជារៀងរាល់ឆ្នាំដែរឬទេ ។ គេប៉ាន់ស្មានថា ដីស្រែទាំងអស់មានប្រហែល ២,៧លានហិកតារ ហើយគេគិតថា ដីនៅសល់ គឺជាដីចំការ ដីដាំកៅស៊ូ និងដំណាំប្រចាំឆ្នាំដទៃទៀត ជាពិសេសដីសម្បទាន (ទោះជាមិនមែនទាំងអស់ក៏ដោយ) ។ ព្រៃឈើគ្របដណ្តប់ប្រហែល ៥៨-៥៩% នៃផ្ទៃដីទូទាំងប្រទេស ។ តាមការប៉ាន់ស្មាន ផ្ទៃដីព្រៃឈើពីឆ្នាំ១៩៩២/៩៣ ដល់ ១៩៩៦/៩៧ បានថយចុះបន្តិចបន្តួច ។ ប៉ុន្តែអ្នកតាមដាននិងត្រួតពិនិត្យ ព្រៃឈើបានគូសបញ្ជាក់ថា ការប៉ាន់ស្មាននេះមិនបានឆ្លុះបញ្ចាំងឱ្យឃើញពីគុណភាពនៃព្រៃឈើទេ ។

៥. ផ្ទៃដីសរុបដែលបានផ្តល់ជាដីព្រៃសម្បទាននាឆ្នាំ២០០១ មាន ៤,១ហិកតារ បើតាមបញ្ជីបែងចែកតាមឈ្មោះក្រុមហ៊ុននីមួយៗ ដែលអាចរកបានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្នុងឆ្នាំ១៩៩៩ ដីព្រៃសម្បទានមាន ៦,៣៩លានហិកតារ គឺខុសពីតួលេខនៃការសិក្សារបស់អង្គការ Oxfam ដែលបង្ហាញថាមានចំនួន ៨លានហិកតារ[1] ។ ភាពមិនស្របគ្នានេះ វាអាចទាក់ទងមួយចំណែកទៅនឹងហេតុផលដែលថា កំណត់ត្រារបស់រដ្ឋាភិបាល មិនអាចរកបានជានិច្ចកាលក្នុងរដ្ឋបាលសាធារណៈទេ ។ គេជឿថាផ្ទៃដីសម្បទានកសិកម្មមានប្រហែល ០,៧១លានហិកតាររ ឯផ្ទៃឡូត៍នេសាទសម្បទានមានប្រហែល ១លានហិកតារ ។ ដោយតួលេខមួយចំនួនជាតួលេខប្រហាក់ប្រហែល ដូច្នេះសំណូមពរដ៏ទទូចមួយគឺ គួរតែធ្វើបញ្ជីសារពើភ័ណ្ឌលើដីសម្បទានទាំងអស់ឡើងវិញ ។

៦. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ បង្ហាញថា ដីកសិកម្មសរុបមានប្រហែល ២,៨៨លានហិកតារ ។ តួលេខនេះមានន័យថា គ្រួសារនីមួយៗនៅក្នុងប្រទេសមានដី ១,៣៧ហិកតារ ។ ដីមួយប្លង់ៗជាមធ្យមមានទំហំតូចគឺត្រឹមតែ ០,៩០ហិកតារប៉ុណ្ណោះ ។ ចំនួនសរុបនៃដីលំនៅដ្ឋានគឺ ២.០២៩.១៦០ប្លង់ ក្នុងនេះមានទាំងដីមានកម្មសិទ្ធិ និងដីអាចមានទំនាស់ ។ អ្នកគ្មានផ្ទះសំបែងមានប្រហែល ៣% ។ ជាទូទៅ ដីផ្ទះមានទំហំជាមធ្យមប្រហែល ៨៨៨ម៉ែត្រការ៉េ (៩១៩ម៉ែត្រការ៉េនៅជនបទ និង ៦១៦ម៉ែត្រការ៉េនៅទីប្រជុំជន) ។ ទៅតាមប្រភពទិន្នន័យខុសៗគ្នា អ្នកគ្មានដីកសិកម្មមានប្រហែល ១២-១៥% ហើយការលំអៀងគ្នាខ្លះនេះ អាចជាប់ទាក់ទងនឹងស្ថានភាពខុសគ្នាទៅតាមក្រុម និងតំបន់គោលដៅនានា ។ នៅក្នុងវិស័យកសិកម្មគ្រួសារនីមួយៗមានដីជាមធ្យមប្រហែល ១-១,៣ហិកតារ ទៅតាមតំបន់ និងក្រុមគោលដៅខុសៗគ្នា ។ ការសិក្សាគំរូតាងស្ថិតិនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ បានបង្ហាញថា គ្រួសារភាគច្រើនមានដីទំហំ ១,៣៣ហិកតារ ប៉ុន្តែអាចមានមូលហេតុផ្សេងទៀតដែលអាចធ្វើឱ្យតួលេខនេះមានភាពលំអៀង ។ ទាំងប្រជាជននៅទីប្រជុំជន និងប្រជាជននៅជនបទ គឺមានដីកសិកម្មដូចគ្នា ។

៧. ប្រជាជនមានការយល់ច្រឡំច្រើនណាស់ពីភាពស្របច្បាប់នៃម្ចាស់ដី ។ ប្រជាជនភាគច្រើនយល់ថា បើគេកាន់កាប់ដីដោយគ្មានវិវាទ ដីនោះគឺជារបស់គេដោយស្របច្បាប់ ទោះបីគេមានឬគ្មានក្រដាសស្នាមបង្ហាញនូវ

[1] ប្រភពតួលេខនេះមិនអាចរកមកបញ្ជាក់បានទេ ។

សិទ្ធិជាម្ចាស់ជាផ្លូវការក៏ដោយ ។ នេះជាទស្សនៈជាប្រពៃណីរបស់ពួកគេ ។ ក្នុងចំណោមអង្កេតទាំងបួនដែលបានសាកសួរអំពីការមានក្រដាសស្នាមដីធ្លី មានតែអង្កេត PET-98 ប៉ុណ្ណោះដែលបានបង្ហាញឱ្យឃើញពីស្ថានភាពជាក់ស្តែង ។

៨. ការបែងចែកដីមានវិសមភាពយ៉ាងធំ ទោះបីជាផ្ទៃដីកសិកម្មគិតជាមធ្យមមិនធំក៏ដោយ ។ ការវិភាគរកវិសមភាពមេគុណជីនី (Gini coefficient of inequality) ដែលមានទំហំពី 0 ដល់ ១ គឺសំរាប់ស្ទើរតែគ្រប់អង្កេតទាំងអស់ វាធំលើសពី 0,៥0 ។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ បង្ហាញថា វិសមភាពនេះមានទំហំ 0,៥៧ នៅតំបន់ជនបទ ឯអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៧ បង្ហាញថា វិសមភាពនេះមាន ទំហំ 0,៦៦ ។ គំលាតនេះវាធំពេក ហើយគេជឿថាអង្កេតទាំងពីរមានទិន្នន័យលំអៀង ឬក៏ខុស ។

៩. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនានាដែលយកមកសិក្សាក្នុងឯកសារនេះ (ក្រៅពីការអង្កេត LADIT របស់ Oxfam ចេញដែលប្រមូលយកដោយចំៗនូវពត៌មានស្តីពីបុព្វហេតុនៃការអត់ដី) បានប្រមូលយកទិន្នន័យជាប់ទាក់ទងនឹងដីធ្លី ក្នុងលក្ខណៈជាពត៌មានបន្ថែមចំពោះកម្មវត្ថុចំបងរបស់ពួកគេប៉ុណ្ណោះ ។ ឧទាហរណ៍ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនានារបស់វិទ្យាស្ថានជាតិស្ថិតិ ផ្តោតជាសំខាន់លើការវាស់វែងកំរិតជីវភាព អង្កេតរបស់ UNICEF-WFP ផ្តោតលើបញ្ហាអាហារូបត្ថម្ភនិងសន្តិសុខស្បៀង ឯអង្កេតរបស់គណៈកម្មការទន្លេមេគង្គផ្តោតលើសមត្ថភាព និងសំភារៈនេសាទ ដែលមាននៅក្នុងបណ្តុំសហគមន៍នេសាទនានា ។ អង្កេតទាំងនេះក៏ធ្វើនៅតំបន់ខុសៗគ្នាផងដែរ ។ ជាលទ្ធផល គេសង្កេតឃើញមានភាពមិនស៊ីគ្នាយ៉ាងខ្លាំង រវាងតួលេខនានាដែលគណនាចេញពីកំរងទិន្នន័យជាប់ទាក់ទងនឹងដីធ្លីខុសៗគ្នាទាំងនេះ ។ ដូច្នេះការធ្វើអង្កេតមួយដែលផ្តោតតែទៅលើរឿងដីធ្លី គឺជាការចាំបាច់ណាស់ ។ នៅប្រទេសដទៃទៀត គេធ្វើអង្កេតបែបនេះយ៉ាងទៀងទាត់តាមពេលកំណត់ ។ មជ្ឈមណ្ឌលគ្រប់គ្រងដីធ្លី (Land Tenure Center) នៅសាកលវិទ្យាល័យ Wisconsin នៅសហរដ្ឋអាមេរិក បានកាន់កាប់បញ្ជីសារពើភ័ណ្ឌនៃអង្កេតបែបនេះ ដែលមានកត់ត្រាពីតំបន់ធ្វើអង្កេត ការជ្រើសរើសគំរូតាង... ។ រដ្ឋាភិបាល អាចចាត់ទុកជាការមានប្រយោជន៍ផងដែរនូវការបង្កើតឡើងនូវការិយាល័យស្ថិតិកណ្តាលមួយ ដែលមានតួនាទីមិនគ្រាន់តែប្រមូល និងផ្គុំប្រៀបធៀបនូវទិន្នន័យដែលទទួលបានពីស្ថាប័ននានាប៉ុណ្ណោះទេ ប៉ុន្តែក៏មានតួនាទីច្របាច់បញ្ចូលគ្នា និងបន្សុីគ្នានូវភាពខុសគ្នាខ្លះៗ ដែលអាចកើតមាននៅពេលដែលស្ថាប័នផ្សេងៗគ្នាប្រមូលទិន្នន័យទាំងនេះ ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| CASD | សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គម (Community Action for Social Development) |
| CDC | ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>(Cambodia Development Resource Institute) |
| CMAC | មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (Cambodia Mine Action Center) |
| COM | ក្រុមប្រឹក្សារដ្ឋមន្ត្រី (Council of Ministers) |
| DLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី<br>(Department of Land Management, Urban Planning, Construction and Cadastre) |
| DOF | នាយកដ្ឋានរុក្ខាប្រមាញ់ (Department of Forestry) |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម (Food and Agricultural Organization) |
| FinnMap | ទីភ្នាក់ងារសហការហ្វាំងឡង់ (Finnish Co-operation Agency) |
| GTZ | Deutsche Gesellschaft Fuer Technische Zusammenarbeit |
| IDP | អង្គការជនភៀសសឹកក្នុងស្រុក (Internally Displaced Person) |
| LADIT | ភាពគ្មានដីធ្លី និងការអភិវឌ្ឍន៍ (Landlessness and Development Information Tool) |
| LMAP | គំរោងរៀបចំ និងរដ្ឋបាលដីធ្លី (Land Management and Administration Project) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>(Ministry of Land Management, Urban Planning and Construction) |
| MRC | គណៈកម្មការទន្លេមេគង្គ (Mekong River Commission) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-governmental organisation) |
| NIS | វិជ្ជាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| OLMUPCL | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល<br>(Office of Land Management Urban Planning, Construction and Land ) |

| | |
|---|---|
| OXFAM-GB | អង្គការអុកស្វាមអង់គ្លេស (Oxford Famine-Great Britain) |
| PET | អង្កេតមុខសញ្ញាសង្គ្រោះបន្ទាន់រយៈពេលយូរ (Protracted Emergency Targets) |
| PFD | អង្គការដៃគូដើម្បីអភិវឌ្ឍន៍ (Partners for Development) |
| SES | ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (Socio-economic Survey) |
| UNICEF | មូលនិធិសំរាប់កុមារនៃអង្គការសហប្រជាជាតិ (United Nations Children's Fund) |
| WCARRD | សន្និសីទអន្តរជាតិស្តីពីកំណែទំរង់កសិកម្ម និងអភិវឌ្ឍន៍ជនបទ<br>(World Conference on Agrarian Reforms and Rural Development) |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក (World Food Programme) |

## បញ្ជីអង្កេតដែលបានពិភាក្សានៅក្នុងឯកសារ និងអក្សរកាត់

| ចំណងជើងអង្កេត | ឆ្នាំ | អក្សរកាត់ |
|---|---|---|
| មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា Cambodia Mining Action Center | 2001 | CMAC |
| កំណត់ត្រារបស់រដ្ឋាភិបាលស្តីពីសម្បទានជលផល | 2001 | - |
| កំណត់ត្រារបស់រដ្ឋាភិបាល ស្តីពីផ្ទៃដីដែលបានសម្បទានលើដីកសិកម្ម និងព្រៃឈើ | 1999; 2000 | - |
| កំណត់ត្រារបស់រដ្ឋាភិបាលស្តីពីការប្រើប្រាស់ដីធ្លី | 1992–93; 1996–97 | - |
| | | |
| **LADIT, OXFAM-GB** | **1999–2000** | **LADIT** |
| អង្កេតរបស់គណៈកម្មការទន្លេមេគង្គ | 1995–96 | MRC-95–96 |
| Protracted Emergency Target, WFP | 1998 | PET-98 |
| អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច, វិជ្ជាស្ថានជាតិស្ថិតិ | 1996 | SES-96 |
| អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច, វិជ្ជាស្ថានជាតិស្ថិតិ | 1997 | SES-97 |
| អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច, វិជ្ជាស្ថានជាតិស្ថិតិ | 1999 | SES-99 |
| អង្កេតតាមដានរបស់អង្គការយូនីសេហ្វ | 2000 | Follow-up-00 |
| អង្កេតមូលដ្ឋានរបស់អង្គការយូនីសេហ្វ និងអង្គការម្ហូបអាហារពិភពលោក | 1998 | Baseline–98 |

# សេចក្តីថ្លែងអំណរគុណ

ឯកសារនេះគឺជាលទ្ធផលមួយចំណែកនៃការស្រាវជ្រាវដ៏ធំមួយក្នុងបញ្ហាដីធ្លី ការិតជីវភាពនៅជនបទ និងសន្តិសុខស្បៀង, ដែល វបសអ មានកម្មវិធីអនុវត្តពីឆ្នាំ២០០១ ដល់ ២០០៣ ។ គោលដៅចំបងនៃកម្មវិធីនេះ គឺការកសាងទិន្នន័យច្បាស់លាស់ពីជីវភាពរស់នៅរបស់ប្រជាជននៅជនបទ ជាពិសេសប្រជាជនរស់នៅក្នុងស្រទាប់សង្គមដែលងាយរងគ្រោះ ។ ក្នុងគោលដៅនេះ កម្មវិធីស្រាវជ្រាវរបស់ វបសអ មានលក្ខណៈស្របគ្នានឹងអាទិភាពចំបងរបស់រដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ។ មកទល់ពេលនេះ វបសអ បានផ្តើមធ្វើការសិក្សាចំនួនបួនហើយ នៅក្នុងកិច្ចដំណើរការកម្មវិធី ។ ឯកសារនេះគឺជារបាយការណ៍នៃការសិក្សាទីពីរដែលនឹងត្រូវចប់សព្វគ្រប់ ។ ឯការសិក្សាទីមួយ គឺជា *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* ។

នៅខែឧសភា ឆ្នាំ២០០១ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (MLMUPC) បានស្នើឱ្យ វបសអ រៀបចំការសិក្សាមួយស្តីពីស្ថានភាពនៃការកាន់កាប់ដីធ្លីជាទូទៅនៅកម្ពុជា ដែលត្រូវក្លាយជាចំណែកមួយនៃកម្មវិធីគ្រប់គ្រងដីធ្លីរបស់ក្រសួង និងដែលបានទទួលមូលនិធិពី គំរោងអភិវឌ្ឍន៍គោលនយោបាយ និងធនធានមនុស្សរបស់ធនាគារពិភពលោក ក្នុងក្របខ័ណ្ឌនៃប្រាក់អំណោយរបស់ជប៉ុន ។ របាយការណ៍ដំបូងមួយនៃការសិក្សានេះ ត្រូវបានដាក់ជូនទៅ MLMUPC ។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ MLMUPC ដែលបានជួយរ៉ាប់រងចំណាយក្នុងការរៀបចំកំរងទិន្នន័យ និងជួយសំរួលឱ្យប្រើប្រាស់បាននូវកំរងទិន្នន័យមួយចំនួន ។

ក្រុមអ្នកនិពន្ធសូមអរគុណជាពិសេសចំពោះលោក ស៊ិក បូរ័ក្ស អតីតអ្នកស្រាវជ្រាវនៅ វបសអ ដែលបានជួយណែនាំបង្ហាញនូវមូលដ្ឋានទិន្នន័យស្តីពីដីធ្លីនៅកម្ពុជា ។ ជំពូក ៥ និង ៦ នៃឯកសារនេះ បានប្រើប្រាស់យ៉ាងច្រើននូវការស្រាវជ្រាវដែលលោក ស៊ិក បូរ័ក្ស បានធ្វើក្នុងរយៈពេលដែលគាត់បំរើការនៅ វបសអ ។ ក្រុមអ្នកនិពន្ធសូមអរគុណចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, វិជ្ជាស្ថានជាតិស្ថិតិ, និងអង្គការស្បៀងអាហារពិភពលោក, ដែលបានផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់កំរងទិន្នន័យរបស់ខ្លួន ។ ក្រុមអ្នកនិពន្ធសូមអរគុណផងដែរចំពោះអង្គការ Oxfam ដែលមិនគ្រាន់តែបានចែករំលែកនូវលទ្ធផលនៃអង្កេតផ្សេងៗដែលអង្គការបានធ្វើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ទិន្នន័យដើមនៃអង្កេត LADIT ឱ្យប្រើប្រាស់ទៀតផង ។ ក្រុមអ្នកនិពន្ធសូមអរគុណថែមទៀតចំពោះមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ដែលបានចែករំលែកទិន្នន័យរបស់ខ្លួនឱ្យប្រើប្រាស់ដែរ ។

ការសិក្សានេះ បានទទួលការជួយទ្រទ្រង់ច្រើនណាស់ពី លោកស្រី អេវ៉ា មីស្លីវិក ជានាយិកា និងលោក គិម-យាត ដារ៉ារិទ្ធ ជានាយករងនៃ វបសអ ដែលបានលើកទឹកចិត្តក្រុមអ្នកនិពន្ធឱ្យធ្វើការសិក្សានេះនៅក្នុងឆ្នាំ ២០០១

ទោះបីមានបញ្ហាចោទច្រើនខាងបុគ្គលិក និងពេលវេលាក៏ដោយ និងបានផ្តល់លទ្ធភាពឱ្យមានការបត់បែនបានចំពោះម៉ោងពេល និងជាពិសេសចំពោះលោកស្រី អេវ៉ា មីស្លីវិក ដែលបានជួយមតិដ៏មានប្រយោជន៍ជាច្រើននៅពេលកំពុងរៀបចំឯកសារនេះ ។

*ភ្នំពេញ, ខែសីហា ឆ្នាំ២០០១*

*ច័ន្ទ-សុផល ទេព-សាវ៉ារី និង* Sarthi Acharya

*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

# ជំពូក មួយ

# សេចក្តីផ្តើម

## ១.១. បុព្វកថា

ប្រជាជនកម្ពុជាជាងបីភាគបួន ត្រូវពឹងផ្អែកដោយផ្ទាល់លើកសិកម្ម និងសកម្មភាពនានាដែលពាក់ព័ន្ធនឹងដីធ្លី ដើម្បីចិញ្ចឹមជីវិតខ្លួន ។ ដូច្នេះដីធ្លី គឺជាទ្រព្យសម្បត្តិផលិតកម្មដ៏សំខាន់បំផុតរបស់អ្នកទាំងនេះ ។ វិធីប្រពៃណីដែលប្រជាជនកម្ពុជាទទួលបានដីគឺ *ការកាន់កាប់តាមគន្លងទន្ត័ល* ដែលក្នុងនេះអ្នកប្រើប្រាស់ដី ចាប់យកដីតាមទំហំដែលខ្លួនត្រូវការដើម្បីចិញ្ចឹមជីវិត ដោយមិនប៉ះពាល់ដល់សិទ្ធិកាន់កាប់រួមរបស់សហគមន៍ទេ ។ តាមទ្រឹស្តី ដីធ្លីទាំងអស់ គឺជាកម្មសិទ្ធិរបស់ស្តេច តែក្នុងការអនុវត្តន៍ជាក់ស្តែងវាជាកម្មសិទ្ធិរបស់អ្នកប្រើប្រាស់ដីដើម្បីធ្វើផលិតកម្ម (van Acker 1999)[១] ។ ក្នុងរយៈពេលជាង ១០០ឆ្នាំ ពីឆ្នាំ១៨៨៤ ដល់ ១៩៨៩ ដីធ្លីត្រូវស្ថិតនៅក្រោមរបបច្បាប់ជាច្រើន ជាកម្មវត្ថុនៃការធ្វើសហករភាវូបនីយកម្ម និងឯកជនភាវូបនីយកម្មច្រើនបែបយ៉ាង ។ ប៉ុន្តែកសិករ និងអ្នកប្រើប្រាស់ដីធ្លី មិនទាន់បានបោះបង់ការកាន់កាប់ និងគ្រប់គ្រងដីធ្លីតាមបែបប្រពៃណីនេះចោលទាំងស្រុងទេ ។ ជាមួយនឹងការធ្វើឯកជនភាវូបនីយកម្មដីធ្លីជាផ្លូវការក្នុងឆ្នាំ១៩៨៩ និងការកែលំអច្បាប់ភូមិបាលនានាឱ្យបានគ្រប់ជ្រុងជ្រោយ និងពេញលេញក្នុងពេលថ្មីៗនេះទៀត យើងអាចសន្មតថា ដំណាក់កាលជាក់លាក់មួយសំរាប់ការដាក់អនុវត្តគោលនយោបាយដីធ្លីដែលមានលក្ខណៈកាន់តែគ្រប់ជ្រុងជ្រោយថែមទៀត ត្រូវបានកំណត់ចេញហើយ ។ ក្នុងបរិបទនេះ ការស្វែងយល់ពីស្ថានការណ៍ដីធ្លីមានសារៈសំខាន់ណាស់ ដើម្បីជួយឱ្យការអនុវត្តន៍គោលនយោបាយស្តីពីដីធ្លីមានភាពរលូនល្អ ។ ប៉ុន្តែការតាក់តែងឯកសារនេះ វាស៊ីជំរៅជាងរឿងគោលនយោបាយដីធ្លីទៀត ពីព្រោះវាជាប់ទាក់ទងនឹងការយកចិត្តទុកដាក់របស់ វិបសអ អំពីបញ្ហាដីធ្លី និងសន្តិសុខស្បៀងនៅក្នុងប្រទេសកម្ពុជា ដែលជាចំណុចផ្តោតមួយដ៏ចំបងនៃកម្មវិធីស្រាវជ្រាវរបស់ វិបសអ ក្នុងឆ្នាំ២០០១-០៣ ។

## ១.២. គោលដៅនៃការសិក្សា

របាយការណ៍នេះមានបំណងកំនត់ ពិនិត្យពិច័យ ផ្តល់យោបល់លើគុណភាព និងភាពគ្រប់គ្រាន់នៃកំរងទិន្នន័យធំៗដែលមានស្រាប់ (ទទួលបានពីក្រសួងរដ្ឋាភិបាល អង្គការអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវនានា...) ហើយមានចុះពតិមានស្តីពីការប្រើប្រាស់/ការកាន់កាប់ដីធ្លី និងបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងដីធ្លី ។ បន្ទាប់មក មានការ

---

[១] បញ្ហាដ៏ស្មុគស្មាញនេះ ពុំមានការរើកញែកនៅក្នុងឯកសារនេះទេ តែទិដ្ឋភាពមួយចំនួនមានរៀបរាប់នៅក្នុងការសិក្សារបស់ វិបសអ ស្តីពី *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (So *et al.* 2001) ។

ធ្វើវិភាគទិន្នន័យដើម្បីកំណត់ពីចំណងទាក់ទងរវាងកំរិតជីវភាព/ភាពក្រីក្រ និងការកាន់កាប់ដីធ្លី ។ គោលដៅនៃការសិក្សានេះ គឺដើម្បីស្វែងរកទិន្នន័យមាំទាំនៅក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច និងអង្កេតស្តីពីការកាន់កាប់ដីធ្លីផ្សេងៗនៅកម្ពុជា ធ្វើការវាយតំលៃពីផលប្រយោជន៍នៃអង្កេតនានាសំរាប់ការស្វែងយល់ពីបញ្ហាផ្សេងៗដែលជាប់ទាក់ទិននឹងដីធ្លី និងផ្តល់មតិពីចំណុចខ្វះខាតនានាដែលត្រូវបំពេញក្នុងពេលអនាគត ។ ឯកសារមានគោលដៅត្រឹមតែធ្វើការប្រៀបធៀបទិន្នន័យដែលមានស្រាប់ប៉ុណ្ណោះ ដើម្បីទាញយកនូវសេចក្តីសន្និដ្ឋានផ្សេងៗ ។

គោលដៅជាក់លាក់មួយចំនួនមានដូចតទៅៈ

ក. គោលដៅទីមួយគឺ រៀបរាប់ពីការប្រើប្រាស់ដីធ្លី តាមបែបបទខុសគ្នា និងតាមប្រភេទនៃអ្នកប្រើប្រាស់, ធ្វើការប៉ាន់ស្មានពីផ្ទៃដីសម្បទាន, និងផ្តល់ការពិពណ៌នាសង្ខេបពីប្រភេទដីសម្បទានដែលបានផ្តល់ហើយរហូតមកដល់សព្វថ្ងៃ ។ ការអធិប្បាយពន្យល់ពីដីធ្លីដែលត្រូវបានបែងចែកសំរាប់ការប្រើប្រាស់ខុសៗគ្នា ក៏ជាចំណែកមួយនៃការសិក្សានេះដែរ ។ សរុបមក ជំពូកនេះមានចរិតជាការពិពណ៌នាជាសំខាន់ ។

ខ. គោលដៅទីពីរជាប់ទាក់ទងច្រើននឹងការវិភាគ ។ វាតម្រូវឱ្យធ្វើការគណនាទិន្នន័យដែលបានមកពីកំរងទិន្នន័យនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនានាឡើងវិញ ។ ក្នុងនេះមានការប្រឹងប្រែងរាប់ចំនួនដីធ្លីនៅកម្ពុជា ដោយមានការបំបែកចំនួនសរុបផ្សេងៗ នៅក្នុងកំរងទិន្នន័យទាំងនោះតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ទំហំជាមធ្យមនៃដីលំនៅដ្ឋាន ដីកសិកម្ម កំរិតនៃភាពគ្មានដីធ្លី និងវិសមភាពដីធ្លី ក៏ត្រូវបានគណនាផងដែរ ។ ចំណុចលំអិតដទៃទៀតស្តីពីដីធ្លី ដែលមាននៅក្នុងកំរងទិន្នន័យ ក៏ត្រូវបានយកមកពិនិត្យយ៉ាងល្អិតល្អន់ដូចគ្នា ។

គ. គោលដៅទីបីគឺ ការពិចារណាពីសំនួរដែលថា តើកម្មសិទ្ធិដីធ្លីមានសារៈសំខាន់ប៉ុណ្ណា ក្នុងការកំណត់កំរិតជីវភាព/ភាពក្រីក្រនៃគ្រួសារនីមួយៗ ។ សំរាប់គោលដៅនេះ ទិន្នន័យត្រូវបានយកមកគណនាឡើងវិញ ដើម្បីវាយតំលៃពីចំណងទាក់ទងរវាង កំរិតជីវភាព និងកម្មសិទ្ធិដីធ្លី ។ មានការខិតខំធ្វើវិភាគដោយមានអញ្ញាតច្រើន (multivariate analysis) ដើម្បីវិនិច្ឆ័យពីកំលាំងនៃចំណងទាក់ទងទាំងនេះ ។

## ១.៣. វិធីសាស្រ្ត

កំរងទិន្នន័យផ្សេងៗដែលបានយកមកធ្វើវិភាគមានដូចខាងក្រោមៈ

១. កំណត់ត្រារបស់រដ្ឋាភិបាលស្តីពីការប្រើប្រាស់ដីធ្លី, ឆ្នាំ១៩៩២-៩៣ និង ១៩៩៦-៩៧

២. កំណត់ត្រារបស់រដ្ឋាភិបាលស្តីពីផ្ទៃដីដែលបានប្រគល់ជាដីព្រៃសម្បទាន និងដីសម្បទានកសិកម្ម ឆ្នាំ១៩៩៩ និង ២០០១

៣. កំណត់ត្រារបស់រដ្ឋាភិបាលស្តីពីឡូត៍នៃសាទសម្បទានឆ្នាំ២០០១

៤. ទិន្នន័យនៃអង្កេតរបស់ CMAC ឆ្នាំ២០០១

៥. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៦

៦. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៧

៧. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៩

៨. អង្កេតរបស់គណៈកម្មការទន្លេមេគង្គ ឆ្នាំ១៩៩៥-៩៦ (MRC - 95-96)

៩. អង្កេតមូលដ្ឋានឆ្នាំ១៩៩៨ របស់អង្គការ WFP-UNICEF (Baseline-98)

១០. ការអង្កេតឡើងវិញក្នុងឆ្នាំ២០០០ របស់អង្គការ UNICEF (Follow-up-00)

១១. អង្កេតមុខសញ្ញាសង្គ្រោះបន្ទាន់រយៈពេលយូរ ឆ្នាំ១៩៩៨ (PET-98)

១២. អង្កេត LADIT ឆ្នាំ១៩៩៩-២០០០[២] ។

ទិន្នន័យដែលបានរៀបរាប់ខាងលើ ត្រូវបានប្រមែប្រមូលដោយប្រើវិធីសាស្ត្រផ្សេងៗគ្នា: រូបភាពថតពីលើអាកាស ប្រព័ន្ធពត៌មានភូមិសាស្ត្រ ការចរចាផ្នែករដ្ឋបាល (ឧទាហរណ៍ ការផ្តល់សម្បទាន) និងអង្កេតផ្ទាល់នៅតាមមូលដ្ឋាននានា ។ អង្កេតពីលេខ៥ ដល់ ១២ គឺជាការចុះសិក្សាតាមមូលដ្ឋាន ហើយក្នុងនេះមានតែអង្កេត SES បីទេ ដែលគ្របដណ្តប់ទូទាំងប្រទេស (លើកលែងតែតំបន់មួយចំនួនដែលត្រូវដកចេញដោយសារបញ្ហាសន្តិសុខ) ។ SES ទាំងបី គឺជាអង្កេតលើគំរូតាង ដូច្នេះពុំមានលទ្ធភាពបំបែកតួលេខបានច្រើនទេ ។ អង្កេត MRC-95-96 គ្របដណ្តប់លើ ៨ខេត្ត និងធ្វើតែនៅក្នុងសហគមន៍នេសាទ ។ អង្កេត Baseline-98, Follow-up-00 និង PET-98 បានផ្តោតដូចគ្នាតែលើចំណែកខ្លះនៃសង្គម និងតំបន់គោលដៅមួយចំនួនដែលអង្គការមានកម្មវិធីកំពុងដំណើរការ ។ LADIT គឺជាអង្កេតតែមួយគត់ដែលមានគោលដៅចំបងប្រមូលទិន្នន័យស្តីពីដីធ្លី ។ អង្កេតនេះបានគ្របដណ្តប់លើ ១៩ខេត្ត (១៨៣ភូមិ) ប៉ុន្តែទោះបីជាមានតំបន់គ្របដណ្តប់ធំដូច្នេះក៏ដោយ ក៏មិនអាចតំណាងឱ្យសភាពការណ៍ជាទូទៅបានដែរ ។ កំរងទិន្នន័យទាំង៨ អាចយកមកចងក្រងបានជារបាយការណ៍រួមដើម្បីបកស្រាយពីទិដ្ឋភាព (សេដ្ឋកិច្ច-សង្គមកិច្ច) មួយចំនួនដែលទាក់ទងនឹងដីធ្លីនៅក្នុងប្រទេសកម្ពុជា ។

ការបញ្ជាក់ពីចំណុចខ្សោយនៃការសិក្សានេះ មានសារៈសំខាន់ណាស់ ។ ការវិភាគទិន្នន័យអាចធ្វើបានគ្រប់ជ្រុងជ្រោយ និងពេញលេញ លុះត្រាតែទិន្នន័យដែលអាចរកបាន មានលក្ខណៈគួរទុកចិត្ត និងអាចតំណាងឱ្យប្រជាជនមុខសញ្ញាបាន ។ ដូចបានលើកឡើងហើយ ក្រៅពីការអង្កេត LADIT ចេញ ពុំមានការអង្កេតណាដែលផ្តោតទៅលើបញ្ហាដីធ្លីជាចំបង ។ សូម្បីតែក្នុងអង្កេត LADIT នេះ ក៏ពុំមានរៀបរាប់ពីទំហំដី និងស្ថានភាពកាន់កាប់ដីធ្លីដែរ ។ នៅក្នុងអង្កេតផ្សេងទៀត សំនួរទាក់ទងនឹងដីធ្លីត្រូវបានគេសាកសួរតាមរបៀបយកពត៌មានបន្ថែមក្នុងគំរូតាងនានាដែលគេកំពុងសិក្សា ។ ដូច្នេះហើយ សេចក្តីសន្និដ្ឋាននានានៅក្នុងរបាយការណ៍នេះ គឺគ្រាន់តែជាលទ្ធផលត្រួសៗ និងបណ្តោះអាសន្នប៉ុណ្ណោះ ។

## ១.៤. រចនាសម្ព័ន្ធរបាយការណ៍

ជំពូក១ ដែលជាសេចក្តីផ្តើមនេះ បានកំណត់គោលដៅ និងវិធីសាស្ត្រនៃការសិក្សា ។ ជំពូក២ ធ្វើការវិភាគពីការប្រើប្រាស់ដីធ្លី ដោយចែកចេញជាប្រភេទធំៗនៃការប្រើប្រាស់ដី ។ ជំពូក៣ គឺជាការរៀបរាប់លំអិតពីដីព្រៃសម្បទានដីកសិកម្មសម្បទាន និងឡូត៍នេសាទសម្បទាននានា ។ ជំពូក៤ ពិពណ៌នាពីរដ្ឋអំណាចដែលគ្រប់គ្រងដីធ្លី និងបញ្ហាចេញប័ណ្ណកម្មសិទ្ធិ និងអធិប្បាយលំអិតពីចំនួនប័ណ្ណកម្មសិទ្ធិដែលបានធ្វើរហូតមកដល់សព្វថ្ងៃ ។ ជំពូក៥ ផ្តល់ការពិពណ៌នាយ៉ាងខ្លីពីកំរងទិន្នន័យនៃអង្កេតគំរូតាងនានា ។ ជំពូក៦ ជាការវិភាគទិន្នន័យស្តីពីការកាន់កាប់ដីធ្លី

[២] កំរងទិន្នន័យនេះ ត្រូវបានវិភាគពីអ្វីដែលមានចុះក្នុងរបាយកាណ៍ផ្សាយដោយគំរោងសិក្សាពីដីធ្លីរបស់អង្គការ OXFAM ។ ដោយសារតែរបៀបទុកដាក់ទិន្នន័យនេះ ពុំមានការគណនាកំរងទិន្នន័យនេះឡើងវិញទេ ។ LADIT មានន័យថា ឧបករណ៍ស្រង់ពត៌មានពីភាពគ្មានដីធ្លី និងការអភិវឌ្ឍន៍ (Landlessness and Development Information Tool) ។

និងអញ្ញាត (variables) ពាក់ព័ន្ធនានា ។ ជំពូក៧ ជាការសាកល្បងធ្វើវិភាគមានអញ្ញាតច្រើន ដើម្បីស្វែងរកចំណង ទាក់ទងជាយថាហេតុ រវាងភាពក្រីក្រ និងការកាន់កាប់ដីធ្លី ។ ជំពូក៨ គឺជាសេចក្តីសន្និដ្ឋាននៃរបាយការណ៍ ។ ការ ពិពណ៌នា និងវិភាគក្នុងជំពូក ៥ និង ៦ គឺជាការពង្រីកនូវការវិភាគមួយដែលបានធ្វើដោយការសិក្សារបស់ វ៉បសអ កាលពីមុន (Sik 2000) ហើយកំរងទិន្នន័យបួនទៀត ត្រូវបានដាក់ចូលបន្ថែមនៅក្នុងការវិភាគលើកនេះ ។

# ជំពូក ពីរ

# ការប្រើប្រាស់ដីធ្លី

## ២.១. ចំណាត់ថ្នាក់ដីធ្លី

នៅកម្ពុជានាឆ្នាំថ្មីៗកន្លងទៅនេះ ពុំមានការធ្វើអង្កេតធំៗដើម្បីវាស់វែង និងគូរផែនទីដីទាំងអស់បានទេ ។ ព្រំសីមារដ្ឋបាល ក៏ដូចជាការកំណត់ព្រំដីដែលមានការប្រើប្រាស់ផ្សេងៗគ្នាដែរ គឺជាការស្មានៗ ។ ឧទាហរណ៍ ជានិច្ចកាល គេមិនបានកំណត់ខ័ណ្ឌសីមាដីព្រៃឈើ និងដីកសិកម្មឱ្យបានច្បាស់លាស់ទេ[១] ។ នៅតាមតំបន់ជនបទ គេនៅតែទទួលស្គាល់កម្មសិទ្ធិដីឯកជន និងការកំណត់ព្រំដី ដោយអនុលោមទៅតាមការឯកភាពគ្នានៅក្នុងសហគមន៍ ។ ការវិភាគទិន្នន័យផ្សេងៗ គឺត្រូវធ្វើឡើងនៅក្នុងបរិបទដូចបញ្ជាក់ខាងលើ ។

ក្នុងឆ្នាំថ្មីៗកន្លងមកនេះ រដ្ឋាភិបាលបានរៀបចំរបាយការណ៍ពីរ ព្រមទាំងផែនទី និងទិន្នន័យនានាស្តីពីការប្រើប្រាស់ដីធ្លីនៅកម្ពុជា គឺរបាយការណ៍មួយសំរាប់ឆ្នាំ១៩៩២-៩៣ និងមួយទៀតសំរាប់ឆ្នាំ១៩៩៦-៩៧ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចងក្រងរបាយការណ៍ទាំងពីរ ដោយមានជំនួយបច្ចេកទេសពីគណៈកម្មការទន្លេមេគង្គ ។ ការចងក្រងរបាយការណ៍ទាំងពីរ ផ្អែកលើរូបភាពថតពីអាកាស និងពីផ្កាយរណប ។

តារាង២.១ បង្ហាញទិន្នន័យក្រសួងកសិកម្មស្តីពីចំណាត់ថ្នាក់ និងការប្រើប្រាស់ដីសំរាប់ឆ្នាំ១៩៩២-៩៣ និង ១៩៩៦-៩៧ ។ តារាងនេះត្រូវបានធ្វើឡើងវិញក្នុងទំរង់ដូចគ្នានឹងច្បាប់ដើមដែលបានទទួលមក ដោយមិនមានការកែសំរួលអ្វីទេ ។ ទិន្នន័យសំរាប់ឆ្នាំ១៩៩២-៩៣ និង ១៩៩៦-៩៧ បង្ហាញថា ដីព្រៃឈើមានច្រើនជាងគេគឺប្រហែល ៥៨-៥៩% នៃផ្ទៃដី, ដីកសិកម្មនៅតូចនៅឡើយគឺប្រហែល ២០% ឯដីវាលស្មៅ ដីមានព្រៃគុម្ពោត ឬមានរុក្ខជាតិប្រហាក់ប្រហែល គឺមានប្រហែល ១៥-១៦% ។ ក្រៅពីនេះគឺជាតំបន់ភ្នំ ទីប្រជុំជន ផ្ទៃទឹក...[២] ។

---

[១] សេចក្តីថ្លែងការណ៍ដែលធ្វើនៅក្នុងកិច្ចប្រជុំរបស់បេសកជនធនាគារពិភពលោក ជាមួយនឹងក្រសួង MLMUPC នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០១ បានបញ្ជាក់រឿងនេះ ។

[២] រាជរដ្ឋាភិបាលកម្ពុជា (១៩៩៨) បានបង្ហាញតួលេខស្តីពីការប្រើប្រាស់ដីធ្លីដោយផ្អែកលើរូបភាពថតពីផ្កាយរណប (Landsat Satellite Imagery) ។ តួលេខនេះប្រហាក់ប្រហែលនឹងទិន្នន័យដែលចុះនៅក្នុងតារាង២.១ តែមិនដូចគ្នាទាំងស្រុងទេ ។ គេជឿថា ការប៉ាន់ស្មានទាំងពីរចេញមកពីប្រភពដូចគ្នា ប៉ុន្តែការបកស្រាយរូបភាពដែលបានមកពីផ្កាយរណប វាអាចខុសគ្នា ។

**តារាង២.១ ចំណាត់ថ្នាក់ការប្រើប្រាស់ដីធ្លី**

| | ១៩៩២.៣ (ha) | %នៃដីសរុប | ១៩៩៦/៧ (ha) | %នៃដីសរុប | បំរែបំរួលផ្ទៃដី 1992/3-1996/7 (ha) | % បំរែបំរួល 1992/3 - 1996/7 |
|---|---|---|---|---|---|---|
| **Wood Land ដីព្រៃ** | | | | | | |
| Evergreen Dense | 654,442 | 3.61 | 625,177 | 3.44 | -29,265 | -4.47 |
| Evergreen Disturbed | 3,255,533 | 17.93 | 3,183,395 | 17.54 | -72,138 | -2.22 |
| Evergreen Mosaic | 129,902 | 0.72 | 178,147 | 0.98 | 48,245 | 37.14 |
| Mixed Dense | 99,124 | 0.55 | 95,560 | 0.53 | -3,564 | -3.60 |
| Mixed Disturbed | 1,325,353 | 7.30 | 1,284,446 | 7.08 | -40,907 | -3.09 |
| Mixed Mosaic | 110,066 | 0.61 | 125,320 | 0.69 | 15,254 | 13.86 |
| Deciduous | 4,008,000 | 22.08 | 3,931,219 | 21.66 | -76,781 | -1.92 |
| Deciduous | 342,204 | 1.89 | 350,178 | 1.93 | 7,974 | 2.33 |
| Forest Re-growth | 435,618 | 2.40 | 374,197 | 2.06 | -61,421 | -14.10 |
| Inundated Forest Re-growth | 21,623 | 0.12 | 20,819 | 0.11 | -804 | -4.26 |
| Inundated Forest | 229,266 | 1.26 | 219,906 | 1.21 | -9,360 | -4.08 |
| Mangrove Forest | 77,669 | 0.43 | 72,835 | 0.40 | -4,834 | -6.22 |
| Forest Plantation | 72,307 | 0.40 | 82,425 | 0.45 | 10,118 | 13.99 |
| Inundated Forest Mosaic | 98,587 | 0.54 | 94,582 | 0.52 | -4,005 | -4.06 |
| **Sub-Total** | 10,859,694 | 59.82 | 10,638,206 | 58.60 | -221,488 | -2.04 |
| **Non-Wood Land (ដីមិនមែនព្រៃ)** | | | | | | |
| Wood/Shrub and Evergreen | 559,052 | 3.08 | 545,101 | 3.00 | -13,951 | -2.50 |
| Grassland | 476,804 | 2.63 | 488,643 | 2.69 | 11,839 | 2.48 |
| Bamboo | 32,224 | 0.18 | 33,730 | 0.19 | 1,506 | 4.67 |
| Wood/Shrub-land Dry | 1,267,770 | 6.98 | 1,165,377 | 6.42 | -102,393 | -8.08 |
| Wood/Shrub-land Inundated | 377,401 | 2.08 | 348,971 | 1.92 | -28,430 | -7.53 |
| Mosaic of Cropping (<30%) | 198,879 | 1.10 | 285,155 | 1.57 | 86,276 | 43.38 |
| Mosaic of Cropping (>30%) | 104,444 | 0.58 | 143,796 | 0.79 | 39,352 | 37.68 |
| **Agricultural Land (ដីកសិកម្ម)** | 3,692,356 | 20.34 | 3,901,869 | 21.49 | 209,513 | 5.67 |
| Barren Land | 15,090 | 0.08 | 18,136 | 0.10 | 3,046 | 20.19 |
| Rocks | 2,149 | 0.01 | 2,149 | 0.01 | 0 | - |
| Urban/Built-Over Areas | 26,625 | 0.15 | 27,615 | 0.15 | 990 | 3.72 |
| Water | 446,163 | 2.46 | 469,138 | 2.58 | 22,975 | 5.15 |
| Other | 1,756 | 0.01 | 1,756 | 0.01 | 0 | - |
| Wetland | 91,079 | 0.50 | 83,340 | 0.46 | -7,739 | -8.50 |
| Cloud | 1,497 | 0.01 | 1 | 0.00 | -1,496 | - |
| **Sub-Total** | 7,293,289 | 40.18 | 7,514,777 | 41.40 | 221,488 | 3.04 |
| **Grand-Total** | 18,152,983 | | 18,152,983 | | | - |

*ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។*

តាមទិន្នន័យទាំងនេះ ដីព្រៃបានថយចុះពី ១០,៨៦លានហិកតារ មក ១០,៦៤លានហិកតារ (ថយចុះប្រហែល ២,០៤%) ក្នុងរយៈពេលប្រាំឆ្នាំ ។ តំបន់ដែលបានកំនត់នៅក្នុងតារាងថាជាព្រៃឈើគ្របដណ្តប់ ៥៩,៨២% នៃផ្ទៃដីសរុបនៅក្នុងប្រទេសនាឆ្នាំ១៩៩២-៩៣ ហើយវាថយចុះមកនៅត្រឹម ៥៨,៦០% ក្នុងឆ្នាំ១៩៩៦-៩៧ ។ ទោះជាចំណាត់ថ្នាក់ព្រៃឈើមានលក្ខណៈលំអិតគួរសមក៏ដោយ ក៏តារាងមិនបានបង្ហាញពីការផ្លាស់ប្តូរគុណភាពព្រៃឈើទេ ។ ឧទាហរណ៏ ព្រៃឈើដែលគេបានចែកចេញជាប្រភេទ "ព្រៃបៃតងក្រាស់ (evergreen dense)" និង "ព្រៃបៃតងដោយអន្លើ (evergreen disturbed)" បានថយចុះអស់ ២៩.២៦៥ហិកតារ និង ៧២.១៣៨ហិកតារ ។ ប៉ុន្តែតើមានការកើនឡើងនូវដីព្រៃ "evergreen mosaic" ឬ "mixed mosaic" ឬក៏ដីផ្សេងៗទៀត ដែលជាលទ្ធផលនៃការថយចុះដីព្រៃឈើទាំងអស់នោះដែរឬទេ? ឬក៏ តើគុណភាពដីព្រៃបៃតងក្រាស់ (ឧទាហរណ៏ គិតជាដង់ស៊ីតេ

ឈើក្នុងមួយឯកតាផ្ទៃដី) មានការថយចុះដែរឬទេ? តារាងបានបង្ហាញថា ក្នុងចំណោមព្រៃឈើ ១៤ប្រភេទដែលបានធ្វើចំណាត់ថ្នាក់, មាន ១០ប្រភេទដែលបានថយចុះផ្ទៃក្រឡា ។ ប៉ុន្តែពុំមានចម្លើយចំពោះសំនួរដែលបានលើកឡើងទាំងនេះទេ ។ សំនួរទាំងនេះមានសារៈសំខាន់ណាស់ ពីព្រោះមានការអះអាងពីមជ្ឈដ្ឋានខ្លះថា មានការបាត់បង់ព្រៃឈើយ៉ាងឆាប់រហ័សនៅក្នុងទសវត្សរ៍១៩៩០[៣] ។

ផ្ទៃដីកសិកម្មកើនឡើងពី ៣.៦៩លានហិកតារ ទៅ ៣.៩១លានហិកតារក្នុងរយៈពេលនេះ ។ ចំនួននេះវាធំជាងតួលេខ ២.៩៨លានហិកតារ ដែលបានកត់ត្រាក្នុងឆ្នាំ១៩៦០ ។ ពិតហើយ មួយចំណែកនៃដីស្រែ ០.៩៣លានហិកតារដែលគេបានពង្រីកថែមដើម្បីដោះស្រាយតំរូវការរបស់ប្រជាជនដែលបានកើនឡើង និងកំណើននៃកសិដ្ឋានពាណិជ្ជកម្ម និងដំណាំឧស្សាហកម្ម វាកើតចេញពីការកាប់រានដីព្រៃ ។ គួរកត់សំគាល់ដែរថា ផ្ទៃដី "mosaic of cropping" ដែលស្ថិតក្នុងតំបន់មិនមែនព្រៃឈើ បានកើនឡើងជាង ៤១% ហើយស្ថានភាពនេះបង្ហាញថា ដីរួមកាន់តែត្រូវបានប្រើប្រាស់ច្រើនឡើងហើយ ដើម្បីដោះស្រាយការចិញ្ចឹមជីវិត ។ ផ្ទៃដីគ្មានជីជាតិដីនៅក្នុងតំបន់ប្រជុំជននានា និងផ្ទៃទឹក បានកើនឡើង តែដីសើមធ្លាក់ចុះ ១០% ។

ទិន្នន័យទាំងនេះអាចនាំឱ្យគេជឿថា ការប្រើប្រាស់ដីកំពុងតែទទួលរងនូវការផ្លាស់ប្តូរមួយចំនួន គឺថាដីព្រៃថយចុះបន្តិច រីឯដីកសិកម្មកើនឡើងបន្តិចដែរ ។ ជាការពិតហើយ គេមិនអាចធ្វើសេចក្តីសន្និដ្ឋាន ដោយពុំមានការធ្វើអង្កេតសុរិយោដីឱ្យបានល់អិតនោះទេ ។ ជាងនេះទៅទៀត តាំងពីឆ្នាំ១៩៩៧ មក ពុំមានការកត់ត្រាស្ថានការណ៍ខាងលើនេះនៅកំរិតជាតិទេ ។

## ២.២. ការប្រើប្រាស់ដីសំរាប់ដាំដំណាំផ្សេងៗ

តារាង២.២.ក បង្ហាញទិន្នន័យកាន់តែលំអិតថែមទៀត ស្តីពីដីធ្លីដែលស្ថិតក្រោមការប្រើប្រាស់ខុសៗគ្នា ។ ទិន្នន័យទាក់ទិននឹងឆ្នាំ១៩៩២-៩៣ បង្ហាញថា ក្នុងចំណោមដីដាំដុះប្រមាណ ៣.៩លានហិកតារ មានប្រហែល ២.៨លានហិកតារជាដីស្រែ និងជាង ១លានហិកតារបន្តិចជាដីសំរាប់ដំណាំផ្សេងៗ ។ ទិន្នន័យប្រហាក់ប្រហែលគ្នាសំរាប់ឆ្នាំ១៩៩៦-៩៧ ដែលមានចុះក្នុងតារាង២.២.ខ ក្នុងរូបភាពខុសគ្នាខ្លះៗ, គឺមិនអាចប្រៀបធៀបជាមួយទិន្នន័យមុនបានទេ ដោយសារមានចំណាត់ថ្នាក់ខុសគ្នា ។ តំបន់គ្របដណ្តប់ក្នុងឆ្នាំ១៩៩៦-៩៧ គឺតូចជាងមុន ព្រោះទិន្នន័យមិនអាចរកបានសំរាប់ភូមិភាគអគ្នេយ៍ (ខេត្តស្វាយរៀង និងមួយផ្នែកនៃខេត្តមណ្ឌលគិរី) និងប៉ែកនិរតី (ខេត្តកោះកុង និងមួយផ្នែកនៃខេត្តកំពត) ។ ទិន្នន័យឆ្នាំ១៩៩២-៩៣ គ្របដណ្តប់ប្រទេសទាំងមូល (១៨១.៥៣៥គ.ម$^{២}$) រីឯទិន្នន័យឆ្នាំ១៩៩៦-៩៧ គ្របដណ្តប់ផ្ទៃដីតែ ១៥០.៦០៩គ.ម$^{២}$ ប៉ុណ្ណោះ ។ ដូច្នេះហើយគេមិនអាចគណនាការផ្លាស់ប្តូរលំនាំនៃការដាំដុះ ឬការផ្លាស់ប្តូរការប្រើប្រាស់ដីកសិកម្មរវាងរយៈពេលទាំងពីរនេះបានទេ ។ ផែនទីបង្ហាញពីការប្រើប្រាស់ដីក្នុងឆ្នាំ១៩៩២-៩៣ និង ១៩៩៦-៩៧ មានចុះនៅក្នុងផែនទី១ និង ផែនទី២ នៃជំពូកនេះ ។ ផែនទីសំរាប់ឆ្នាំ១៩៩៦-៩៧ មិនពេញលេញទេ ព្រោះទិន្នន័យក្នុងតំបន់មួយចំនួនមិនអាចរកបាន ។ *មូលហេតុដែលយើងយកទិន្នន័យ និងផែនទីទាំងនេះ មកចុះនៅក្នុងឯកសារ គឺដើម្បីបង្ហាញថា មានទិន្នន័យតែប៉ុណ្ណោះទេដែលអាចរកបាននៅក្នុងវិស័យសាធារណៈ* ។ ឯពតិមានលំអិតផ្សេងទៀត ឬមួយគ្មាន ឬមួយគេមិនព្រមផ្តល់ឱ្យ ដូច្នេះហើយការប្រៀបធៀបលំអិតតាមពេលវេលា មានការពិបាក ។

---

[៣] ការប្រជុំផ្សេងៗរបស់អ្នកផ្តល់ជំនួយស្តីពីប្រធានបទនេះ និងរបាយការណ៍ច្រើនរាប់មិនអស់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ បានបញ្ជាក់អះអាងពីរឿងនេះ។

**តារាង ២.២.ក ការប្រើប្រាស់ដីធ្លីនៅកម្ពុជាឆ្នាំ១៩៩២-៩៣**

| ល.រ. | ចំណាត់ថ្នាក់ដី | ក្រឡាផ្ទៃ គ.ម² |
|---|---|---|
| 1 | Urban cities (ទីប្រជុំជន) | 45 |
| 2 | Paddy fields (ដីស្រែ) | 26,097 |
| 3 | Receding rice fields (ដីស្រូវប្រដេញទឹក) | 293 |
| 4 | Up land Crops (ដីលើសំរាប់ដំណាំចំការ) | 4,665 |
| 5 | Swidden agriculture (ដីកសិកម្មពនេចរ) | 1,856 |
| 6 | Orchards (ដីចំការ) | 188 |
| 7 | Plantation (ដីចំការកៅស៊ូ... ។ល។) | 746 |
| 8 | Field crops (ដីដំណាំផ្សេងៗ) | 5,299 |
| 9 | Evergreen forest | 47,633 |
| 10 | Coniferous forest | 98 |
| 11 | Deciduous forest | 43,012 |
| 12 | Mixed forest | 9,773 |
| 13 | Secondary forest | 5,170 |
| 14 | Flooded forest (ដីព្រៃលិចទឹក) | 3,707 |
| 15 | Flooded secondary forest | 2,598 |
| 16 | Mangrove forest (ដីព្រៃកោងកាង) | 851 |
| 17 | Woodlands | *6,563* |
| 18 | Natural shrub-lands | 13,501 |
| 19 | Abandoned shrub-lands | 2,528 |
| 20 | Marshes | 14 |
| 21 | Grasslands | 24 |
| 22 | Grass savannan | 468 |
| 23 | Flooded grasslands | 849 |
| 24 | Abandoned grasslands | 1,095 |
| 25 | Marshes | 15 |
| 26 | Water surfaces (ផ្ទៃទឹក) | 4,111 |
| 27 | Barren lands | 336 |
| | **Total Area (ផ្ទៃដីសរុប)** | **181,535*** |

**តួលេខនេះមិនច្បាស់លាស់ទេ ។ វាមានចំនួនខ្ពស់ជាងផ្ទៃដីសរុប ១៨១.០៣៥គ.ម² នៃប្រទេសកម្ពុជា ។ ប្រភព: ក្រសួងកសិកម្ម ។*

តំបន់អភិរក្ស និងតំបន់ការពារ អាចចែកចេញជាឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារ និងតំបន់ពហុគ្រប់គ្រង និងប្រើប្រាស់ ។ ចំណាត់ថ្នាក់ដីធ្លីលំអិតសំរាប់ឆ្នាំ១៩៩២-៩៣ មានបង្ហាញក្នុងតារាង២.៣ ។ តំបន់ការពារដែលសំដៅជាចំបងដល់តំបន់ព្រៃអភិរក្ស ដែនជម្រកសត្វព្រៃ ឧទ្យានជាតិ និងសណ្ឋានដីដទៃទៀត ដូចជាតំបន់អង្គរវត្តជាដើម មានប្រហែល ៣.៣លានហិកតារ ឬ ១៨.៣% នៃផ្ទៃដីទូទាំងប្រទេស ។ ការសំភាសន៍ជាមួយនឹងអាជ្ញាធរនានានៅក្រសួងកសិកម្មបានបង្ហាញថា តំបន់រក្សាទុកជាព្រៃបំរុង នឹងកើនឡើងដោយសារព្រៃសម្បទានរបស់ក្រុមហ៊ុនមួយចំនួនត្រូវបានលុបចោល ហើយដីទាំងនេះមិនត្រូវបានប្រគល់ឱ្យទៅក្រុមហ៊ុនដទៃទៀតទេ ។ ការប្រៀបធៀបតាមឆ្នាំមិនអាចធ្វើទៅបានទេ ពីព្រោះគេមិនអាចរកទិន្នន័យដែលស៊ីគ្នាបាន សំរាប់ផ្ទៃដីព្រៃបំរុងនាឆ្នាំ១៩៩៦-៩៧ ។

តារាង២.៤ ផ្តល់ការបែងចែកដីព្រៃឈើតាមខេត្ត ។ តួលេខសរុបនៃដីនៅក្នុងតារាងនេះ មិនអាចប្រៀបធៀបនឹងតួលេខដែលមាននៅក្នុងតារាង២.១ ទេ ដូច្នេះហើយការប្រៀបធៀបរវាងតារាង២.១ និង តារាង២.៤ អាចជាការមិនល្អ ។ ទោះជាយ៉ាងណាក៏ដោយ ការប្រៀបធៀបបានបង្ហាញថា ទំហំផ្ទៃដីព្រៃបានថយចុះក្នុងគ្រប់ខេត្តក្នុងរយៈពេលប្រាំឆ្នាំនេះ ។

## តារាង ២.២.ខ ការប្រើប្រាស់ដីធ្លីឆ្នាំ១៩៩៦-៩៧

| ល.រ. | ចំណាត់ថ្នាក់ដី | ផ្ទៃគ.ម² |
|---|---|---|
| 1 | Agricultural plantation (rubber, tea, coffee, etc.) ដំណាំកសិកម្ម (កៅស៊ូ តែ កាហ្វេ.... ។ល។) | 68 |
| 2 | Bamboo forest (ព្រៃឫស្សី) | 218 |
| 3 | Barren land | 126 |
| 4 | City, town and build-up areas (ទីប្រជុំជន ទីក្រុង និងតំបន់សាងសង់) | 1,745 |
| 5 | Closed evergreen forest | 3,075 |
| 6 | Coniferous forest (pure) | 49 |
| 7 | Deciduous forest; continuous cover | 36,798 |
| 8 | Deciduous wood and shrub-land, including thicket | 14,186 |
| 9 | Evergreen wood and shrub-land | 616 |
| 10 | Field crop (ដីសំរាប់ដាំដំណាំ) | 2,003 |
| 11 | Flooding forest (ដីព្រៃលិចទឹក) | 3,051 |
| 12 | Flooding secondary forest | 1,054 |
| 13 | Forest plantation | 493 |
| 14 | Grassland (dry land and flooded) | 5,090 |
| 15 | Mangrove forest (ព្រៃកោងកាង) | 0.1 |
| 16 | Marsh and swamp (inland) | 447 |
| 17 | Mixed coniferous forest with broadleaf trees | 2 |
| 18 | Mosaic of closed and opened evergreen forest | 997 |
| 19 | Mosaic of deciduous forest blocks | 2,535 |
| 20 | Mosaic of semi-evergreen forest blocks | 929 |
| 21 | Open/disturbed evergreen forest | 23,978 |
| 22 | Other | 452 |
| 23 | Permanent paddy flew (single & narks sops) | 23,025 |
| 24 | Receding and floating paddy field (ដីស្រូវប្រដេញទឹក និងដីស្រូវឡើងទឹក) | 390 |
| 25 | Secondary forest | 4,840 |
| 26 | Semi-evergreen forest, closed cover | 1,063 |
| 27 | Semi-evergreen forest; open/disturbed cover | 11,446 |
| 28 | Shifting cultivation (ដីកសិកម្មពនេចរ) | 4,698 |
| 29 | Swamp forest | 2,227 |
| 30 | Upland and perennial crop | 135 |
| 31 | Water (lake, pond) ផ្ទៃទឹក (បឹង ត្រពាំង) | 4,269 |
| 32 | Village and build-up areas (ដីភូមិ និងតំបន់សាងសង់) | 605 |
| | **Total (excluding a few provinces) (មិនរាប់បញ្ចូលខេត្ត ពីរ-បី)** | **150,609** |

*កំណត់សំគាល់: តំបន់គ្របដណ្តប់នៃទិន្នន័យនៅក្នុងតារាងនេះមិនពេញលេញទេ ។ ប្រភព: ក្រសួងកសិកម្ម ។*

ផែនទី១: ប្រភេទនៃការគ្របដណ្តប់លើផ្ទៃដីកម្ពុជា

## ផែនទី២: ការប្រើប្រាស់ដីនៅប្រទេសកម្ពុជា (១៩៩៧)

**តារាង២.៣. ការបង្កើត និងការកំណត់តំបន់អភិរក្ស**

| តំបន់អភិរក្ស | ក្រឡាផ្ទៃ (ហិកតារ) | ទីតាំង |
|---|---|---|
| **ឧទ្យានជាតិ** | | |
| - គីរីរម្យ | 35.000 | កោះកុង |
| - ភ្នំបូកគោ | 140.000 | កំពត |
| - កែប | 5.000 | កំពត |
| - រាម | 21.000 | កំពង់សោម |
| - បុទុមសាគរ | 171.250 | កំពត និងកំពង់សោម |
| - ភ្នំគូលេន | 37.500 | សៀមរាប |
| - វីរៈជ័យ | 332.500 | រតនគីរី និងស្ទឹងត្រែង |
| **ដែនជម្រកសត្វព្រៃ** | | |
| - ឱរ៉ាល់ | 253,750 | កោះកុង ពោធិសាត់ កំពង់ឆ្នាំង កំពង់ស្ពឺ |
| - បឹងព័រ | 242,500 | កំពង់ធំ |
| - ពាមក្រសោប | 23,750 | កោះកុង |
| - ភ្នំសំកុស | 333,750 | កោះកុង |
| - រនាមដូនសំ | 178,750 | បាត់ដំបង |
| - គូលែនព្រំទេព | 402,500 | សៀមរាប ព្រះវិហារ |
| - លំផាត់ | 250,000 | រតនគីរី និងមណ្ឌលគីរី |
| - ភ្នំព្រិច | 222,500 | មណ្ឌលគីរី |
| - ភ្នំណាមលី | 47,500 | មណ្ឌលគីរី |
| - ស្នួល | 75,000 | ក្រចេះ |
| **តំបន់អភិរក្ស** | | |
| - អង្គរ | 10,800 | សៀមរាប |
| - បន្ទាយឆ្មា | 81,200 | បន្ទាយមានជ័យ |
| - ព្រះវិហារ | 5,000 | ព្រះវិហារ |
| **តំបន់គ្រប់គ្រងប្រើប្រាស់ចំរុះ** | | |
| - ដងពែង | 27,700 | កោះកុង |
| - សំឡូត | 60,000 | បាត់ដំបង |
| - ទន្លេសាប | 316,250 | កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប កំពង់ធំ |
| **សរុប** | **3,273,200** | |

*ប្រភព: ព្រះរាជក្រឹត្យ ស្តីពីការបង្កើត និងការគូរប្លង់តំបន់ការពារចុះនៅថ្ងៃ០១ ខែតុលា ឆ្នាំ១៩៩៣ ។ កំណត់ចំណាំ: តារាងនេះត្រូវបានធ្វើឡើងវិញតាមច្បាប់ដើម ដោយមិនមានការកែសំរួលទេ ។*

## ២.៣. ផ្ទៃដីដែលមានមីន

តំបន់មានមីនពិតជាមិនអាចចាត់ចូលជាការប្រើប្រាស់ដីធ្លីទេ តែវាបញ្ជាក់ថា ដីមីនមានចំនួន ១០៩.៧៧៥ ហិកតារនៅក្នុងប្រទេសកម្ពុជា ។ របាយការណ៍របស់ CMAC (CMAC 2001) បញ្ជាក់ថាមានមីនច្បាស់លាស់នៅលើផ្ទៃដី ១០៩.៧៧៥ហិកតារ ។ ប៉ុន្តែតួលេខនេះប្រហែលមិនមែនជាការប៉ាន់ស្មានពីផ្ទៃសរុបនៃតំបន់មានមីននៅក្នុងទូទាំងប្រទេសជាក់លាក់ប៉ុន្មានទេ ពីព្រោះគេរកឃើញតំបន់ថ្មីៗផ្សេងទៀតដែលមានមីនជាបន្តបន្ទាប់ ។ តាមពិត CMAC បានរាយការណ៍ថា មានដី ១៩៩.៩៧៤ហិកតារដែលនៅត្រូវការសកម្មភាពសំអាតមីន ។ ទោះបីផ្ទៃដី ១០៩.៧៧៥ហិកតារ មើលទៅហាក់ដូចជាមិនធំប៉ុន្មាន តែមីនគឺជាកត្តាគ្រោះថ្នាក់ខ្លាំងណាស់ (ប្រជាជនរាប់ពាន់នាក់

ទទួលគ្រោះថ្នាក់ ឬត្រូវស្លាប់ដោយសារមីនក្នុងមួយឆ្នាំ៧) ដែលធ្វើឱ្យតំបន់មានមីន ក្លាយជាចំណុចកង្វល់មួយយ៉ាងធំ ។ ដូចមានចុះក្នុងផែនទី៣ តំបន់មានមីននៅរាយប៉ាយពាសពេញផ្ទៃប្រទេស ដែលធ្វើឱ្យបញ្ហាកាន់តែពិបាកដោះស្រាយថែមទៀត ។ ទិន្នន័យប៉ាន់ស្មានស្តីពីតំបន់ដែលសង្ស័យថាមានមីន និងតំបន់ដែលបញ្ជាក់ច្បាស់ថា មានមីនគឺបានទទួលមកពី CMAC និងមានចុះនៅក្នុងតារាង២.៥ ។

**តារាង ២.៤. តំបន់ព្រៃឈើ ឆ្នាំ១៩៩២-៩៣ និង ១៩៩៦-៩៧ បែងចែកតាមខេត្ត**

| ខេត្ត | 1992-93 | 1996-97 | ការប្រែប្រួល | ផ្ទៃដីសរុប | % នៃព្រៃឈើ ១៩៩៦-៩៧ |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | 199,889 | 175,122 | -24,767 | 671,476 | 26.08 |
| បាត់ដំបង | 588,499 | 581,349 | -7,150 | 1,244,621 | 46.71 |
| កំពង់ចាម | 266,097 | 265,174 | - 923 | 942,466 | 28.14 |
| កំពង់ឆ្នាំង | 173,829 | 172,305 | -1,524 | 529,095 | 32.57 |
| កំពង់ស្ពឺ | 356,375 | 339,147 | -17,228 | 681,773 | 49.74 |
| កំពង់ធំ | 647,594 | 633,898 | -13,696 | 1,244,748 | 50.92 |
| កំពត | 239,416 | 233,292 | - 6,124 | 468,582 | 49.79 |
| កណ្តាល | 21,363 | 20,890 | - 473 | 357,112 | 5.85 |
| កោះកុង | 1,079,154 | 1,048,454 | -30,700 | 1,238,532 | 84.65 |
| ក្រចេះ | 908,370 | 904,291 | -4,079 | 1,197,278 | 75.53 |
| មណ្ឌលគិរី | 1,132,455 | 1,125,913 | -6,542 | 1,366,385 | 82.40 |
| ភ្នំពេញ | 1,118 | 1,118 | - | 37,313 | 3.00 |
| ព្រះវិហារ | 1,252,260 | 1,242,088 | -10,172 | 1,401,540 | 88.62 |
| ព្រៃវែង | 9,076 | 7,607 | -1,469 | 481,553 | 1.58 |
| ពោធិសាត់ | 811,255 | 807,597 | -3,658 | 1,159,674 | 69.64 |
| រតនគិរី | 1,012,241 | 985,339 | -26,902 | 1,189,730 | 82.82 |
| សៀមរាប | 617,415 | 596,120 | -21,295 | 1,196,390 | 49.83 |
| ក្រុងព្រះសីហនុ | 88,186 | 85,937 | -2,249 | 139,125 | 61.77 |
| ស្ទឹងត្រែង | 1,067,283 | 1,055,410 | -11,873 | 1,189,669 | 88.71 |
| ស្វាយរៀង | 5,026 | 4,641 | -385 | 285,626 | 1.62 |
| តាកែវ | 15,600 | 5,218 | -10,382 | 349,389 | 1.49 |
| ឧត្តរមានជ័យ | 360,756 | 340,858 | -19,898 | 511,349 | 66.66 |
| ក្រុងកែប | 3,273 | 3,273 | - | 14,704 | 22.26 |
| **សរុប** | **10,856,530** | **10,635,041** | **-221,489** | **17,898,130** | **59.42** |

*ប្រភព: ក្រសួងកសិកម្ម ។*

**តារាង២.៥ តំបន់ដែលសង្ស័យថាមានមីន និងតំបន់ដែលបានបញ្ជាក់ច្បាស់ថាមានមីន ឆ្នាំ២០០១**

| **ខេត្ត** | សង្ស័យថាមានមីន (ហិកតារ) | បញ្ជាក់ថាមានមីន (ហិកតារ) |
|---|---|---|
| បាត់ដំបង | 29,065 | 27,056 |
| ឧត្តរមានជ័យ | 27,223 | 16,028 |
| កំពត | 10,361 | 15,017 |
| បន្ទាយមានជ័យ | 6,923 | 11,408 |
| កំពង់ស្ពឺ | 3,873 | 8,236 |
| ប៉ៃលិន | 2,448 | 7,678 |
| កំពង់ចាម | 1,915 | 5,205 |
| ព្រះវិហារ | 1,751 | 5,178 |
| សៀមរាប | 1,251 | 4,095 |
| កំពង់ធំ | 1,193 | 2,274 |
| ស្វាយរៀង | 1,174 | 2,038 |
| ពោធិសាត់ | 1,098 | 1,427 |
| កែប | 897 | 1,382 |
| តាកែវ | 701 | 658 |
| ក្រុងព្រះសីហនុ | 284 | 575 |
| កោះកុង | 35 | 561 |
| ក្រចេះ | 0 | 507 |
| កំពង់ឆ្នាំង | 0 | 444 |
| ស្ទឹងត្រែង | 0 | 0 |
| រតនគិរី | 0 | 0 |
| ព្រៃវែង | 0 | 0 |
| ភ្នំពេញ | 0 | 0 |
| មណ្ឌលគិរី | 0 | 0 |
| កណ្ដាល | 0 | 0 |
| **សរុប (ទូទាំងប្រទេសកម្ពុជា)** | 90199 | 109775 |

*ប្រភព:* CMAC ។

ផែនទី៣ ដីមានគ្រោះថ្នាក់គ្រាប់មីននៅក្នុងប្រទេសកម្ពុជា ( កក្កដា ២០០១)

# ជំពូក ទី

# ដីសម្បទាន

## ៣.១ ប្រព័ន្ធផ្តល់សម្បទាន

គេគួររំលឹកថា ដីព្រៃសម្បទានត្រូវបានប្រគល់ឱ្យទៅក្រុមហ៊ុនអន្តរជាតិ និងក្រុមហ៊ុនជាតិ សំរាប់កាប់យកឈើតាមលក្ខណៈវិទ្យាសាស្ត្រ, ដីសម្បទានកសិកម្មត្រូវបានផ្តល់ឱ្យក្រុមហ៊ុនសំរាប់ធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម និងដើម្បីបង្កើតផលិតផលកសិកម្មសំរាប់ទីផ្សារអន្តរជាតិ និងក្នុងស្រុក, រីឯឡូត៍នេសាទសម្បទានត្រូវបានអនុវត្តដើម្បីបង្កើនផលិតផលត្រីឱ្យបានលើសសំរាប់ទីផ្សារ ។ កិច្ចសន្យាសម្បទានទាំងអស់គឺសំដៅបង្កើនចំណូលរដ្ឋ ។ ប្រព័ន្ធផ្តល់សម្បទាននៅក្នុងប្រទេសកម្ពុជា ជាពិសេសសម្បទានឡូត៍នេសាទ បានចាប់អនុវត្តតាំងពីដើមសតវត្សរ៍ទី ២០ មកម្លេះ ។

## ៣.២. ការផ្តល់ព្រៃសម្បទាន

ប្រព័ន្ធផ្តល់សម្បទានព្រៃឈើមានដូចតទៅ:

ក) ក្រុមហ៊ុនដាក់ពាក្យសុំដោយផ្ទាល់ទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខ) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្គុំ និងពិនិត្យមើលពាក្យសុំទាំងអស់

គ) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បញ្ជាឱ្យនាយកដ្ឋានរុក្ខាប្រមាញ់ ពិនិត្យផ្នែកបច្ចេកទេស

ឃ) ដោយមានរបាយការណ៍ពីនាយកដ្ឋានរុក្ខាប្រមាញ់ ក្រសួងកសិកម្មធ្វើសំណើ និងបញ្ជូនសំណើទៅកាន់ក្រុមប្រឹក្សារដ្ឋមន្ត្រីដើម្បីសំរេច

ង) ក្រុមប្រឹក្សារដ្ឋមន្ត្រីធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន

ច) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញអាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនដើម្បីប្រើប្រាស់ព្រៃសម្បទាន

ឆ) ក្រុមហ៊ុននឹងត្រូវធ្វើផែនការមេមួយ ជាមួយនឹងនាយកដ្ឋានរុក្ខាប្រមាញ់ និងក្រសួងកសិកម្ម ។

តាមទិន្នន័យបានមកពីក្រសួងកសិកម្មសំរាប់ឆ្នាំ១៩៩៩, រហូតមកដល់ឆ្នាំនោះ មាន ៣០ក្រុមហ៊ុនដែលបានទទួលដីព្រៃសម្បទាន ។ គេជឿថា ពុំមានការផ្តល់សម្បទានព្រៃឈើថែមទៀតទេតាំងពីពេលនោះមក ។ បញ្ជីឈ្មោះក្រុមហ៊ុនទាំង៣០ និងផ្ទៃដីព្រៃសម្បទានមានចុះក្នុងតារាង៣.១ ។ តារាងនេះបង្ហាញថា ដីព្រៃសម្បទានទាំងអស់មាន ៦.៣៧០.០៩៩ហិកតារ គឺ ១,៦៣លានហិកតារតិចជាងតួលេខ ៨លានហិកតារដែលរបាយការណ៍

Oxfam រកឃើញថា ជាទំហំព្រៃសម្បទានក្នុងឆ្នាំ១៩៩៨ (Williams 1999: Table 2)[១] ។ ការសិក្សារបស់ Oxfam បានលើកផែនការសកម្មភាពបរិស្ថានជាតិរបស់រដ្ឋាភិបាល (National Environment Action Plan: RGC 1999:5) ដើម្បីអះអាងពីតួលេខនេះ ។ ប៉ុន្តែឯកសាររដ្ឋាភិបាលនេះបញ្ជាក់ថា ដីព្រៃសម្បទានមាន "ជាង ៦លានហិកតារ" ។ សម្បទានព្រៃឈើអាចមានរយៈពេលវែងដល់ប្រហែល ៣០ឆ្នាំ ។ ក្រុមស្រាវជ្រាវមិនអាចពិនិត្យកិច្ចសន្យានីមួយៗ ដើម្បីសិក្សាពីរយៈពេល ពាក្យពេចន៍ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាទេ ។

ក្នុងតារាង៣.១ ក្រុមហ៊ុននានាត្រូវបានគេចែកចេញជាបីក្រុម: សម្បទានដែលបានធ្វើបញ្ជីសារពើភ័ណ្ឌ និងបានដំណើរការហើយ, សម្បទានដែលកំពុងធ្វើសារពើភ័ណ្ឌ តែមិនទាន់មានសកម្មភាព, និងសម្បទានមិនទាន់ធ្វើសារពើភ័ណ្ឌ ។ បើតាមច្បាប់សម្បទាន មានតែក្រុមហ៊ុនប្រភេទទី១ទេ ដែលត្រូវអនុញ្ញាតឱ្យធ្វើអាជីវកម្ម ។ តាមគោលការណ៍នេះ អាជីវកម្មពាណិជ្ជកម្មក្នុងឆ្នាំ១៩៩៩ មិនគួរធំជាង ២,២លានហិកតារទេ ។ បើសិនយកតួលេខដែលបានកត់ត្រានេះជាបានការ ចំនួនអាជីវកម្មព្រៃឈើក្នុងឆ្នាំ១៩៩៩ មិនទាន់ឡើងហួសកំរិត ២/៣ នៃដីព្រៃឈើដែលបានចុះកិច្ចសន្យាទាំងអស់ទេ ។ ទិន្នន័យនេះវាមិនស្របគ្នានឹងការយល់ឃើញជាទូទៅនៅចុងទសវត្សរ៍១៩៩០ ដែលថា បើសិនជាការកាប់បំផ្លាញព្រៃឈើនៅតែបន្តនៅក្នុងកំរិតនេះទៀត ឆ្នាំ២០០៣ ខាងមុខនឹងពុំមានព្រៃឈើនៅសល់ទេនៅ ។ តារាងនេះបង្ហាញទៀតថា សម្បទានព្រៃឈើធំៗ ប្រមូលផ្តុំនៅខាងភាគឦសាននៃប្រទេសនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងក្នុងខេត្តខ្លះទៀតនៅភាគខាងលិច (កោះកុង ពោធិសាត់ និងកំពង់ស្ពឺ) ។ ខេត្តទាំងអស់នេះគឺជាខេត្តមានព្រៃឈើក្រាស់ និងមានប្រជាជនតិចរស់នៅរាយប៉ាយ ។ ជាទូទៅ សម្បទានព្រៃឈើនីមួយៗមានទំហំធំ គឺលើសពី ១០០.០០០ហិកតារ ។

សម្បទានរបស់ក្រុមហ៊ុនមួយចំនួនត្រូវបានលុបចោល និងក្នុងករណីយខ្លះមានការផ្ទេរទៅឱ្យក្រុមហ៊ុនដទៃហើយក្រោយមកត្រូវលុបចោលទៀត ។ តាមតួលេខបណ្តោះអាសន្ន (គ្មានចុះក្នុងឯកសារនេះទេ) បានបង្ហាញថា សកម្មភាពផ្ទេរ ឬលុបចោលសម្បទាន បានកើនល្បឿនគួរសមក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ។ ការលុបចោលសម្បទានសរុបនៅក្នុងឆ្នាំ២០០១ មានទំហំប្រហែល ២,១៦លានហិកតារ (ជាងមួយភាគបីនៃដីព្រៃសម្បទានទាំងអស់) ហើយដីព្រៃសម្បទាននៅសល់មានប្រហែល ៤,១២លានហិកតារ ។ សម្បទានមួយចំនួនដែលត្រូវបានលុបចោលគឺមានទំហំធំ: ទិន្នន័យរបស់ក្រសួងកសិកម្ម (មិនបានចុះក្នុងឯកសារនេះទេ) បង្ហាញថា ដីព្រៃសម្បទានដែលធំជាងគេបំផុត (១,៤លានហិកតារ) ឥឡូវនេះត្រូវបានលុបចោលហើយ ។ កិច្ចសន្យាមួយចំនួនត្រូវបានលុបចោលដោយសារការរំលោភលើកិច្ចព្រមព្រៀង និង/ឬ ការមិនបានប្រើប្រាស់ធនធាន ។ ការផ្ទៀងផ្ទាត់ដាច់ស្រេចនូវទិន្នន័យក្នុងតារាង៣.១ វាជាការមានប្រយោជន៍ណាស់ ដើម្បីបំបាត់ចោលនូវចំណាប់អារម្មណ៍ខុសឆ្គងនានាក្នុងស្រទាប់មហាជនស្តីពីការប្រើប្រាស់ព្រៃឈើក្នុងប្រទេសកម្ពុជាត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។ មួយចំណែកទៀត ការផ្សព្វផ្សាយបញ្ជីឈ្មោះក្រុមហ៊ុនមានព្រៃសម្បទាន និងតំបន់គ្រប់គ្រងរបស់ពួកគេជាទៀងទាត់ដោយអាជ្ញាធរមានសមត្ថកិច្ចអាចជួយបញ្ជៀសបាននូវការប្រកែកប្រណាំងគ្នាដោយគ្មានមូលដ្ឋាននៅពេលអនាគត ក៏ដូចជាជួយបង្កើនចំណូលពីព្រៃឈើឱ្យបានខ្ពស់បំផុតទៅឱ្យរដ្ឋ និងសង្គមផងដែរ ។

---

[១] គេដឹងមិនច្បាស់ដែរថា ហេតុអ្វីបានជាតួលេខ ៨លានហិកតារនេះត្រូវបានយកទៅប្រើប្រាស់នៅក្នុងកិច្ចប្រជុំមួយចំនួនរបស់អ្នកផ្តល់ជំនួយ ។

### ផែនទី៤ : ព្រៃឈើ និង ដីសម្បទាន នៅឆ្នាំ១៩៩៦-៩៧

**តារាង ៣.១ សម្បទានព្រៃឈើ**

| | ក្រុមហ៊ុន | ១៩៩៩ ក្រឡាផ្ទៃ (ហិកតារ) | ២០០១* ក្រឡាផ្ទៃ (ហិកតារ) | ទីតាំង |
|---|---|---|---|---|
| I. | សម្បទានដែលបានចុះបញ្ជីសារពើភ័ណ្ឌ និងធ្វើអាជីវិកម្ម | | | |
| 1 | GAT International Co., Ltd | 215,720 | 215,720 | កោះកុង និងពោធិសាត់ |
| | | 149,780 | 149,780 | កំពង់ធំ ក្រចេះ |
| 2 | Colexim Enterprise | 147,187 | 147,187 | កំពង់ធំ |
| 3 | Casotim Co., Ltd | 131,380 | 131,380 | ក្រចេះ |
| 4 | Samling Cooperation, SDN. BHD. | 467,484 | 467,484 | ក្រចេះ កំពង់ចាម មណ្ឌលគិរី |
| | | 298,598 | 298,598 | កំពង់ស្ពឺ និងកោះកុង |
| 5 | Mieng Ly Heng Investment Co., Ltd | 198,500 | 198,500 | កំពង់ធំ ព្រះវិហារ កំពង់ចាម |
| 6 | Long Day Machinary Industry Co., Ltd | 98,000 | | កំពត និងកំពង់ស្ពឺ |
| 7 | Pheapimex Funchan Cambodia Co., Ltd | 358,725 | 358,725 | ក្រចេះ ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ |
| 8 | Lang Song Interantional Co., Ltd | 132,000 | | ព្រះវិហារ |
| | **សរុបរង** | **2,197,374** | **1,967,374** | |
| II. | សម្បទានបានចុះបញ្ជីសារពើភ័ណ្ឌ តែមិនទាន់ធ្វើអាជីវកម្ម | | | |
| 9 | Hero Taiwan Co. | 60,150 | 60,150 | រតនគិរី |
| 10 | Lang Song International Co., Ltd | 119,300 | | កំពង់ធំ |
| 11 | king Wood Industry Pte ., Ltd | 301,200 | 301,200 | ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី |
| 12 | Cambodia Chender Plywood MFG Co., Ltd | 103,300 | 103,300 | ព្រះវិហារ |
| 13 | Som Rong Wood Industry Pte ., Ltd | 200,050 | 200,050 | សៀមរាប |
| 14 | Evenbright CIG Wood Co., Ltd | 136,376 | 136,376 | ក្រចេះ ស្ទឹងត្រែង |
| 15 | Super Wood IPEP Ltd | 94,419 | 94,419 | ពោធិសាត់ កំពង់ស្ពឺ |
| 16 | Talam Resource SDN BHD | 111,500 | | កំពង់ស្ពឺ កោះកុង |
| 17 | Timas Resources Ltd | 161,450 | 161,450 | កំពង់ចាម ក្រចេះ ព្រះវិហារ |
| 18 | Silverroad wood Product Ltd | 10,000 | 10,000 | កោះកុង |
| | | 215,460 | | កោះកុង ពោធិសាត់ |
| | **សរុបរង** | **1,513,205** | **1,066,945** | |
| III. | សម្បទានមិនទាន់ចុះបញ្ជីសារពើភ័ណ្ឌ | | | |
| 19 | Chung Shing Cambodia Co., Ltd | 374,350 | | ក្រចេះ ព្រះវិហារ មណ្ឌលគិរី |
| 20 | Pacific Craft Co., Ltd | 24,537 | | ស្ទឹងត្រែង |
| 21 | Thai Boon Rong | 119,700 | | មណ្ឌលគិរី |
| | | 297,000 | | ក្រចេះ មណ្ឌលគិរី |
| 22 | Mekong Sawmitt Furniture and Particles Boads Enterprise Pty ., Ltd | 99,400 | | សៀមរាប ព្រះវិហារ |
| 23 | Samling Cooperation, SDN. BHD. | 218,059 | 218,059 | មណ្ឌលគិរី |
| 24 | YouRysaco Co. | 214,000 | 214,000 | ពោធិសាត់ បាត់ដំបង |
| 25 | TPP Cambodia Timber Products Pte., Ltd | 395,900 | 395,900 | សៀមរាប ព្រះវិហារ ពោធិសាត់ |
| 26 | Woot Tee Teanich Import Export Co., Ltd | 63,050 | | កោះកុង |
| 27 | Chang Ling Lumber Co., Ltd | 236,500 | | ស្ទឹងត្រែង |
| 28 | North Eastern Forest Devt. Ltd | 232,100 | | រតនគិរី ស្ទឹងត្រែង |
| 29 | Phearpionex Fuchan Cambodia Co., Ltd | 350,000 | 350,000 | ស្ទឹងត្រែង រតនគិរី |
| 30 | Camboda Timber Product Pty., Ltd | 34,924 | | កំពត |
| | **សរុបរង** | **2,659,520** | **1,177,959** | |
| | **សរុបទាំងអស់** | **6,370,099** | **4,212,278** | |

** យោងតាមពត៌មានផ្តល់ឱ្យដោយមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ សម្បទានមួយចំនួនដែលនៅសល់ ត្រូវបានកាត់បន្ថយ តែមិនទាន់មានទិន្នន័យនៅឡើយទេ ។ ប្រភព: នាយកដ្ឋានផែនការ និងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ១៩៩៩ ។*

## ៣.៣. សម្បទានកសិកម្ម

និតិវិធីដែលបានអនុវត្តក្នុងការផ្តល់សម្បទានកសិកម្មមិនមែនតែមួយដូចគ្នានោះទេ ។ និតិវិធីមួយដែលត្រូវបានអនុវត្តជាញឹកញាប់មានដូចតទៅ:

ក) ក្រុមហ៊ុនទាក់ទងជាមួយរដ្ឋអំណាចមូលដ្ឋាន (ឃុំ ស្រុក និង/ឬ ខេត្ត) សំរាប់ដីធ្លី

ខ) ក្រុមហ៊ុនធ្វើសំណើទៅក្រសួងកសិកម្ម ដោយមានភ្ជាប់ជាមួយនូវកិច្ចព្រមព្រៀងពីអាជ្ញាធរមូលដ្ឋាន

គ) ក្រសួងកសិកម្មសិក្សាពីលក្ខណៈភូមិសាស្ត្រ និងលទ្ធភាពអាចធ្វើបាននៃតំបន់ដែលស្នើសុំសម្បទាន

ឃ) បន្ទាប់ពីបានសិក្សាលទ្ធភាពអាចធ្វើបាន ក្រសួងកសិកម្មលើកសំណើទៅកាន់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដោយបញ្ជាក់លំអិតពីគោលដៅរបស់ក្រុមហ៊ុន និងសុំ "ការឯកភាពជាគោលការណ៍" ពីក្រុមប្រឹក្សារដ្ឋមន្ត្រី

ង) ក្រុមប្រឹក្សារដ្ឋមន្ត្រីឯកភាពតាមសំណើក្រសួងកសិកម្ម

ច) ដោយមានការឯកភាពជាគោលការណ៍ពីក្រុមប្រឹក្សារដ្ឋមន្ត្រីនៅក្នុងដៃ ក្រសួងកសិកម្មធ្វើសំណើទៅក្រុមប្រឹក្សារដ្ឋមន្ត្រីម្តងទៀត ដើម្បីសុំសិទ្ធិសម្បទាន

ឆ) បើសិនក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ព្រម ក្រសួងកសិកម្មធ្វើកិច្ចសន្យាជាមួយនឹងក្រុមហ៊ុន ។ បន្ទាប់មកក្រុមហ៊ុនត្រូវបង់ប្រាក់កក់ឱ្យក្រសួងកសិកម្ម ។ កិច្ចសន្យាពិតប្រាកដ គឺផ្អែកលើការសិក្សាលំអិតមួយទៀតដែលធ្វើរួមគ្នាជាមួយនឹងមន្ត្រីបច្ចេកទេសរបស់ក្រសួងកសិកម្ម ។ ដីណាដែលកាន់កាប់ដោយកសិករ/អ្នករស់នៅទីនោះ ឬមានអ្នកកាន់កាប់ហើយ ត្រូវកាត់ចេញពីដីផ្តល់សម្បទាន មុននឹងចុះហត្ថលេខាលើកិច្ចសន្យាបញ្ចប់ ។

ជ) នៅទីបញ្ចប់ ក្រុមហ៊ុនធ្វើផែនការមេមួយដើម្បីដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រួតពិនិត្យ សំរាប់ធ្វើសមកាលកម្ម (synchronisation) ជាមួយកិច្ចសន្យា ។

និតិវិធីដទៃទៀតដែលត្រូវបានអនុវត្តផងដែរគឺក្រុមហ៊ុនទាក់ទងទៅក្រុមប្រឹក្សារដ្ឋមន្ត្រីដោយផ្ទាល់ ដើម្បីសុំគោលការណ៍ឯកភាពជាពីខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីបញ្ជូនសំណុំបែបបទទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ។ បន្ទាប់មក CDC រៀបចំការប្រជុំជាមួយនឹងក្រសួងពាក់ព័ន្ធនានាដើម្បីពិនិត្យឱ្យច្បាស់ថាដីនោះអាចធ្វើសម្បទានបានដោយគ្មានបញ្ហា ។ បន្ទាប់ពីមានការបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះដីនោះពីអង្គប្រជុំអន្តរក្រសួងមក CDC លើកសំណើទៅកាន់ក្រុមប្រឹក្សាមន្ត្រីដើម្បីអនុម័តសំរេចប្រគល់សម្បទាន ។ វិធីមួយទៀតនៃការផ្តល់សម្បទាន គឺជាដំបូងក្រុមហ៊ុនទាក់ទងសុំទៅ CDC ។ បន្ទាប់មក CDC បញ្ជូនពាក្យសុំនេះទៅក្រសួងកសិកម្មដើម្បីបញ្ជាក់ផ្អែកបច្ចេកទេស ។ ក្នុងវិធីពីរចុងក្រោយ គេធ្វើរំលងរដ្ឋអំណាចមូលដ្ឋាន ។ ការឆ្លងកាត់អាជ្ញាធរមូលដ្ឋានទំនងជាចំណាយពេលច្រើន និងប្រាក់ច្រើន ។ ប៉ុន្តែវាជាមធ្យោបាយមួយដ៏មានប្រសិទ្ធិភាព បើតាមមតិរបស់មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការធ្វើរំលងរដ្ឋអំណាចមូលដ្ឋានដោយក្រុមហ៊ុនម្តងហើយម្តងទៀត បានធ្វើឱ្យរដ្ឋអំណាចមូលដ្ឋានខូចទឹកចិត្ត និងធ្វើឱ្យសហគមន៍ទទួលរងគ្រោះ (So *et al.* 2001) ។

តារាង៣.២ បង្ហាញថា ផ្ទៃដីសម្បទានកសិកម្មនៅឆ្នាំ១៩៩៩ មានទំហំសរុប ៦៦២.៤៩៦ហិកតារ និងបានប្រគល់ទៅឱ្យ ៤៦ក្រុមហ៊ុន ។ ពតិមានអំពីការបែងចែកសម្បទានទាំងនេះបង្ហាញថា សម្បទានមានទីតាំងនៅក្នុងតំបន់ព្រៃ មិនមែនតំបន់ដីស្រែទេ ។ សម្បទានកសិកម្មស្ទើរតែទាំងអស់សំរាប់ដាំដំណាំឧស្សាហកម្ម និងដំណាំប្រចាំ

ឆ្នាំផ្សេងៗ ហើយមានតែបួនប៉ុណ្ណោះដែលសំរាប់ផលិតកម្មស្រូវ ។ ដីសម្បទានកសិកម្មស្ទើរតែទាំងអស់មានផ្ទៃដីធំៗ ហើយសម្បទានមួយចំនួនធំលើសពី ១០.០០០ហិកតារ (ដែលរដ្ឋចង់កំណត់យកជាទំហំអតិបរមា បើតាមសំដីមន្ត្រីដែលបានឆ្លើយសំភាសន៍ក្នុងឆ្នាំ២០០១) ។ ដីសម្បទានធំបំផុតជារបស់ក្រុមហ៊ុន Pheapimex និងមានទំហំ ៣១៥.០០០ហិកតារ (តារាង៣.២) ។ ដីសម្បទានកសិកម្មអាចមានរយៈពេលរហូតដល់៧០ឆ្នាំ ។

ការសំភាសន៍ជាមួយនឹងមន្ត្រីក្រសួងកសិកម្មក្នុងខែកក្កដាឆ្នាំ២០០១ និងទិន្នន័យដែលផ្សព្វផ្សាយចុងក្រោយបង្អស់បានបង្ហាញថា ចំនួនដីសម្បទានកសិកម្មបានកើនឡើងដល់ ៥៥ មុននឹងធ្លាក់ចុះមកត្រឹម ៣៩ ដូចមានចុះក្នុងតារាង៣.៣ ។ ១៦សម្បទានកសិកម្ម ត្រូវបានលុបចោល ឬដកហូតមកវិញនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយ ។ ៣៩ក្រុមហ៊ុនដែលនៅសល់ កំពុងកាន់កាប់ដីសរុប ៧០៥.៣៩៤ហិកតារ ។ មានក្រុមហ៊ុនពីរ-បី ប្រហែលនឹងត្រូវបាត់បង់ដីសម្បទានរបស់ខ្លួន ឬត្រូវដកហូតយកដីសម្បទានមកវិញ (ក្រុមហ៊ុនពីរកំពុងតែស្ថិតក្នុងដំណើរការដកហូតដីសម្បទានវិញ) ។ ជាថ្មីម្តងទៀត មានការខុសគ្នាខ្លះរវាងតួលេខចុងក្រោយបង្អស់ (តារាង៣.៣) និងទិន្នន័យឆ្នាំ ១៩៩៩ (តារាង៣.២) ដែលអាចកើតចេញពីការរៀបចំឡើងវិញនៃសម្បទានកសិកម្ម ឬក៏ភាពត្រឹមត្រូវនៃកំរងទិន្នន័យ ។ ដូច្នេះ ចាំបាច់ត្រូវធ្វើអង្កេតឱ្យបានល្អិតល្អន់ដើម្បីរកឃើញការពិត ។

អ្នកកាន់កាប់សម្បទានកសិកម្ម គឺមានទាំងជនបរទេស (ពិសេសចិន និងម៉ាឡេស៊ី) និងជនជាតិកម្ពុជា ។

**តារាង ៣.២ សម្បទានកសិកម្ម ឆ្នាំ១៩៩៩**

| ល.រ | ឈ្មោះ | ក្រឡាផ្ទៃ (ហិកតារ) | ទីតាំង | ដំណាំ |
|---|---|---|---|---|
| 1 | Pheapimex | 315,000 | កំពង់ឆ្នាំង | ស្វាយចន្ទី |
| 2 | Talam Plantation Holding SDN BHD | 36,700 | កោះកុង | កៅស៊ូ និងដូងប្រេង |
| 3 | Cambodia Haining Group | 23,000 | កំពង់ស្ពឺ | ដំឡូង |
| 4 | Angkor Industrial Crop Development | 20,000 | កំពង់ស្ពឺ | អំពៅ និងវាលស្មៅ (សំរាប់ចិញ្ចឹមសត្វ) |
| 5 | Mensarun Friendship & Rama Khmer | 20,000 | រតនគីរី | ដូងប្រេង |
| 6 | Unique International Commerce | 20,000 | មណ្ឌលគីរី | កៅស៊ូ និងកាហ្វេ |
| 7 | Chiel Jadang | 18,300 | កំពង់ស្ពឺ | ដំឡូងជ្វា |
| 8 | Un Borin Trading & Agr. Devt. | 16,600 | កំពង់ស្ពឺ | ដំឡូងបារាំង |
| 9 | Cambodia Palm Oil | 15,200 | កោះកុង | ដូងប្រេង |
| 10 | M . Consolidated Plan | 12,700 | កំពង់ស្ពឺ | ដំឡូងមី និងស្រូវ |
| 11 | Development of Industrial Crop | 12,506 | កំពង់ស្ពឺ | ស្វាយចន្ទី |
| 12 | Cambo Came | 11,400 | កំពង់ធំ | ស្រូវ |
| 13 | Mong Rithy | 11,000 | ក្រុងព្រះសីហនុ | ដូងប្រេង |
| 14 | Maca Plantation | 10,800 | កំពង់ស្ពឺ | ដំណាំកសិកម្ម |
| 15 | Cambodia Eversky | 10,000 | កំពង់ធំ | ដំណាំកសិកម្ម |
| 16 | Shing Yue Commercial | 10,000 | កំពត | កៅស៊ូ និងដូងប្រេង |
| 17 | Sokimex | 9,900 | កំពង់ចាម | កៅស៊ូ |
| 18 | China National Coecld | 8,000 | កំពង់ស្ពឺ | ដំណាំកសិឧស្សាហកម្ម |
| 19 | China Cambodia State Farm 999 Int . | 7,500 | កោះកុង | វាលស្មៅ (ចិញ្ចឹមសត្វ) |
| 20 | Potato Powder Ltd. | 7,400 | ស្ទឹងត្រែង | ស្វាយចន្ទី |
| 21 | Sin Thai Kampot | 5,700 | កំពត | ស្វាយចន្ទី និងធូរេន |
| 22 | Cambodia Tapioca Ent. | 5,100 | កំពត | ដូងប្រេង |
| 23 | Bopha Angkorimex Trankong | 5,000 | កំពង់ចាម | កៅស៊ូ |

| | | | | |
|---|---|---|---|---|
| 24 | Henan Economic | 4,200 | កំពង់ស្ពឺ | ដំណាំកសិកម្ម |
| 25 | Asia Golden Dragon | 4,000 | កំពង់ចាម | ដំឡូងមី |
| 26 | China Evergreen Cambodia Agr. Devt. | 4,000 | កំពត | ដំណាំកសិឧស្សាហកម្ម |
| 27 | S.K. Chamreung Devt. | 4,000 | រតនគិរី | កៅស៊ូ |
| 28 | Cambodia Shan Shoei | 3,830 | កោះកុង | ចំការ |
| 29 | Yea Jan Trading Co. | 3,800 | កំពត | ដំឡូងមី |
| 30 | Mieng Ly Heng | 3,000 | កំពង់ចាម | កៅស៊ូ |
| 31 | Ratana Visal Devt. | 3,000 | ពោធិសាត់ | ស្វាយចន្ទី |
| 32 | Wat Vanny | 3,000 | កំពង់ធំ | ស្រូវ |
| 33 | Agrostar | 2,400 | កំពង់ចាម | ស្វាយចន្ទី |
| 34 | Hur Hong Investment | 2,040 | កំពង់ស្ពឺ | ដំណាំកសិកម្ម |
| 35 | Nacorice | 2,000 | បាត់ដំបង | ស្រូវ |
| 36 | Tay Seng Import-Export | 2,000 | រតនគិរី | កៅស៊ូ |
| 37 | Chung Shing Cambodia | 1,600 | កោះកុង | ដូងប្រេង |
| 38 | Khem Len Imp . Exp . | 1,600 | កំពត | ដូងប្រេង |
| 39 | Sor Uth | 1,550 | កំពង់ស្ពឺ | តែ និងកាហ្វេ |
| 40 | TTY | 1,070 | កំពង់ចាម | កៅស៊ូ |
| 41 | Lim Kry | 1,050 | តាកែវ | ស្រូវ |
| 42 | Chung Thai Investment | 550 | កោះកុង | ដំឡូងមី និងឈើហូបផ្លែ |
| 43 | Family Agr . Devt . Community | 500 | កំពង់ចាម | កៅស៊ូ |
| 44 | Heng Savath | 500 | កំពង់ចាម | ស្វាយចន្ទី |
| 45 | Ly Seng | 500 | តាកែវ | ស្វាយចន្ទី |
| 46 | Sour Kear | 300 | ពោធិសាត់ | ស្វាយចន្ទី |
| 47 | Ford Thai | 200 | មណ្ឌលគិរី | កសិកម្ម |
| **សរុប** | | **662,496** | | |

*ប្រភព: នាយកដ្ឋានផែនការស្ថិតិឆ្នាំ១៩៩៩ ។*

**តារាង៣.៣ ស្ថិតិ និងសកម្មភាពក្រុមហ៊ុនវិនិយោគលើដីសម្បទានសុំតាមរយៈក្រសួងកសិកម្ម (31/01/2001)**

| ល.រ | ឈ្មោះក្រុមហ៊ុន | ទីតាំង | ទំហំដី (ហិកតារ) | ប្រភេទដំណាំ | ថ្ងៃខែ កិច្ចសន្យា | កំណត់សំគាល់ |
|---|---|---|---|---|---|---|
| 1 | Agrostar | កំពង់ចាម | 2,400 | ស្វាយចន្ទី | ០៩/០១/៩៥ | បាននិងកំពុងដាំដុះ |
| 2 | សហគមន៍គ្រួសារ ហេង សាវ៉ាត់ | កំពង់ចាម | 500 | ស្វាយចន្ទី | ២៣/០១/៩២ | បាត់ទំនាក់ទំនង |
| 3 | Sokimex Invest-ment on rubber | កំពង់ចាម | 9,900 | កៅស៊ូ | ២៧/០៥/៩៨ | ត្រៀមចុះកំនត់ចំនុចគោលដីសម្បទាន |
| 4 | TTY Company | កំពង់ចាម | 1,070 | កៅស៊ូ | ០២/០៥/00 | បាត់ទំនាក់ទំនង |
| 5 | CAMBODA EVERSKY | កំពង់ធំ | 10,000 | ដំណាំឧស្សាហកម្ម | ០៣/១១/៩៨ | ក្រុមការងារខេត្ត កំពុងស្រង់ស្ថិតិ |
| 6 | Cam Chi International Agri. Dev. | កំពង់ធំ | 26,500 | ដំឡូងមី | ០៣/០៣/00 | ក្រុមការងារខេត្ត កំពុងស្រង់ស្ថិតិ |
| 7 | លាងហួរហុង អភិវ. ឧស្សា. និងកែច្នៃ | បាត់ដំបង | 8,000 | អំពៅ ដំឡូងបារាំង | ០៧/០៦/00 | ក្រុមការងារខេត្ត កំពុងស្រង់ស្ថិតិ |
| 8 | RATANA VISAL Co | ពោធិសាត់ | 3,000 | ស្វាយចន្ទី ល្ហុងប្រេង | ១៥/១០/៩៩ | បាត់ទំនាក់ទំនង |
| 9 | PHEAPIMEX Co | ពោធិសាត់ | | ដាំដើមឈើ | | ក្រសួងកំពុងជួយ |

| | | | | | | |
|---|---|---|---|---|---|---|
| | LTD | និងកំពង់ចាម | 315,028 | រោងចក្រក្រដាស | ០៨/០១/០០ | អន្តរាគមន៍ទៅខេត្ត |
| 10 | Mong Rithy Investment CAMBODIA OIL PALM Co LTD | ក្រុងព្រះសីហនុ | 11,000 | ដូងប្រេង | ០៩/០១/៩៥ | បាននិងកំពុងដាំដុះ |
| 11 | ម៉ុង រិទ្ធី វិនិយោគ ដំឡូងមី កម្ពុជា | ក្រុងព្រះសីហនុ | 1,800 | ដំឡូងមី | ១៨/០៣/០០ | បាត់ទំនាក់ទំនង |
| 12 | China Cambodia State Farm 999 International | កោះកុង | 7,500 | ដំណាំកសិកម្ម ចិញ្ចឹមសត្វ | ០៦/១០/៩៨ | ក្រសួងកំពុងជួយ អន្តរាគមន៍ទៅខេត្ត |
| 13 | TALAM Plantation Holding SDN BHD | កោះកុង | 36,700 | កៅស៊ូ ដូងប្រេង | ០៥/១០/៩៨ | ក្រុមការងារខេត្ត កំពុងស្រង់ស្ថិតិ |
| 14 | The Green Rich Co; LTD | កោះកុង | 60,200 | ដូងប្រេង អាកាស្យា | ២៥/១១/៩៨ | សុំពន្យាកុងត្រា, ត្រូវបង់ប្រាក់ធានា |
| 15 | HENAN (Cambo dia) Economic & Trade Dev. Zone | កំពង់ស្ពឺ | 4,100 | ដំណាំឧស្សាហកម្ម ចិញ្ចឹមសត្វ | ២៩/០៧/៩៩ | ក្រុមការងារខេត្ត កំពុងស្រង់ស្ថិតិ |
| 16 | Cambodia Haining Group Co,Ltd | កំពង់ស្ពឺ | 23,000 | ដំឡូងមី ដូងប្រេង | ២៣/០៧/៩៩ | បានធ្វើអន្តរាគមន៍ ទៅ MLMUPC |
| 17 | Corporation C J Cambodia Ltd | កំពង់ស្ពឺ | 3,000 | ដំឡូងមី | ១៥/១១/៩៩ | សជណ ឱ្យ កសក ចុះកុងត្រាតែម័ពធ្វើ |
| 18 | ផលិតម្សៅដំឡូងមី ចំកាត់ | ស្ទឹងត្រែង | 7,400 | តែ កាហ្វេ | ១៣/១១/៩៩ | ក្រសួងកំពុងសិក្សា ប្តឹងមេក្រុមហ៊ុន |
| 19 | មិត្តភាពម៉ែន សារុន និងរាម៉ាខ្មែរ | រតនគិរី | 20,000 | ដូងប្រេង | ២១/១២/៩៩ | បាត់ទំនាក់ទំនង |
| 20 | CHINA NATIONAL. COECLD Co; LTD | កំពង់ស្ពឺ | 8,000 | ដំណាំកសិឧស្សាហកម្ម | ២៦/០៩/០០ | ត្រៀមចុះកំនត់ចំនុច គោលដីសម្បទាន |
| 21 | KIMSVILLE CORP | កំពង់ស្ពឺ | 3,200 | ដំឡូងមី | ២៤/១០/០០ | កំណត់ចំណុចដីសម្បទាន កំពុងស្រង់ស្ថិតិ |
| 22 | Keim Lein Imp-Exp | កំពត | 16,400 | ដូងប្រេង | ២៦/១០/០០ | បាត់ទំនាក់ទំនង |
| 23 | FORD THAI | មណ្ឌលគិរី | 200 | កសិកម្ម | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 24 | Shing Yui Commercial | កំពត | 10,000 | កៅស៊ូ ដូងប្រេង | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 25 | China Evergret Ca mbodia Agri. Dev. | កំពត | 4,000 | កៅស៊ូ ដូងប្រេង | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 26 | បុប្ផអង្គរីម៉ិចត្រង់កុង | កំពង់ចាម | 5,000 | កៅស៊ូ | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 27 | Cambo Victor & In-vesting Developing | កំពង់ស្ពឺ | 28,500 | ដំណាំកសិកម្ម | ពុំទាន់ចុះកុងត្រា | មានសិទ្ធិប្រទាន កំពុង តវ៉ាទីតាំង ជាន់គ្នា |
| 28 | Ouk Khun Industrial Crop Development | កំពង់ស្ពឺ | 12,506 | ស្វាយចន្ទី | ពុំទាន់ចុះកុងត្រា | កំពុងសុំចុះហត្ថលេខាលើកិច្ចសន្យា |
| 29 | Hour Hong Invest. | កំពង់ស្ពឺ | 2,040 | ដំណាំកសិកម្ម | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 30 | Unborin Trade Agriculture Dev. | កំពង់ស្ពឺ | 16,600 | ដំឡូងបារាំង | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |

| | | | | | | |
|---|---|---|---|---|---|---|
| 31 | Tai Seng Im-Export | រតនគិរី | 2,000 | កៅស៊ូ | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 32 | Meang Ly Heng Investment | កំពង់ចាម | 3,000 | កៅស៊ូ | ពុំទាន់ចុះកុងត្រា | បានប្រជុំត្រៀមចុះពិនិត្យទីតាំងសារថ្មី |
| 33 | Lim Kry Agricultural Development | តាកែវ | 1,050 | ដាំស្រូវ | ពុំទាន់ចុះកុងត្រា | បានប្រជុំត្រៀមចុះពិនិត្យទីតាំងសារថ្មី |
| 34 | Sour Kea Co, LTD | ពោធិសាត់ | 300 | ស្វាយចន្ទី | ពុំទាន់ចុះកុងត្រា | |
| 35 | Cambodia Tapioca Enter | កំពត | 5,100 | ដំឡូងមី | ពុំទាន់ចុះកុងត្រា | អន្តរាគមន៍ទៅគណៈកម្មការបាតុភាពដីធ្លីខេត្ត/ក្រុង |
| 36 | Sin Thai Kampot Co Ltd | កំពត | 5,700 | ស្វាយចន្ទី ធូរេន | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 37 | Chung Shing Cambodia | កោះកុង | 16,000 | ដូងប្រេង | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 38 | M. Consolidated Plantation | កំពង់ស្ពឺ | 12,700 | ដំឡូងបារាំង ស្រូវ | ពុំទាន់ចុះកុងត្រា | សុំសិទ្ធិប្រទាន |
| 39 | NACO Rice | បាត់ដំបង | 2,000 | ស្រូវ | ពុំទាន់ចុះកុងត្រា | បាត់ទំនាក់ទំនង |
| 40 | Angkor Industrial Crop Development | កំពង់ស្ពឺ | 20,000 | អំពៅ ដំណាំចំណីសត្វ | លុបកុងត្រា | ប្រកាសលេខ ៤០៦ ប្រក.កសក.ផ.ផក. ចុះ ១៥/០៩/៩៨ |
| 41 | សរ អ៊ុត | កំពង់ស្ពឺ | 1,550 | កាហ្វេ តែ | លុបកុងត្រា | |
| 42 | Ly Seng Import Export | តាកែវ | 500 | ស្វាយចន្ទី | លុបកុងត្រា | ៤៤២ សជណ.កស. ចុះថ្ងៃ ២០/៣/០០ |
| 43 | Yean Jan Trading Co Ltd, Cambodia Tapioca Corp. Ltd | កំពត | 3,800 | ស្វាយចន្ទី | លុបកុងត្រា | ៤៤២ សជណ.កស. ចុះថ្ងៃ ២០/៣/០០ |
| 44 | Chel Jadang (C & J Cambodia) | កំពង់ស្ពឺ | 18,300 | ដំឡូងមី | លុបកុងត្រា | ៤៤២ សជណ.កស. ចុះថ្ងៃ ២០/៣/០០ |
| 45 | អេស ខេ ចំរើន អភិវឌ្ឍន៍ | រតនគិរី | 4,000 | កៅស៊ូ | លុបកុងត្រា | ៤៤២ សជណ.កស. ចុះថ្ងៃ ២០/៣/០០ |
| 46 | យូនីកឯកភាពពាណិជ្ជអន្តរជាតិ | មណ្ឌលគិរី | 20,000 | កៅស៊ូ កាហ្វេ | លុបកុងត្រា | ៤៤២ សជណ.កស. ចុះថ្ងៃ ២០/៣/០០ |
| 47 | Asia Golden Dragon | កំពង់ចាម | 4,000 | កៅស៊ូ | លុបកុងត្រា | ៣៣៣ប្រក.កសក.ផ. ផកចុះ៣១/០៥/០០ |
| 48 | គ.ឈ. ហៀស៊ីន សហគ្រាស | កំពង់ចាម | 6,250 | ដំឡូងមី | លុបកុងត្រា | ៣៣៣ប្រក.កសក.ផ. ផកចុះ៣១/០៥/០០ |
| 49 | Cambodia Palm Oil | កោះកុង | 15,200 | ដូងប្រេង | លុបកុងត្រា | ៣៣៣ប្រក.កសក.ផ. ផកចុះ៣១/០៥/០០ |
| 50 | សមាគមន៍អភិវឌ្ឍន៍កសិកម្ម | កំពង់ចាម | 500 | កៅស៊ូ | កិច្ចសន្យាត្រូវលុបចោល | ១៣៨១សជណ.សរ ចុះ១៤/០៨/០០ |
| 51 | វ៉ាត វ៉ាន់នី | កំពង់ធំ | 3,000 | ស្រូវ | លុបកុងត្រា | ១៣៨១សជណ.សរ ចុះ១៤/០៨/០០ |
| 52 | Cambo Can Co LTD | កំពង់ធំ | 11,400 | ស្រូវឡើងទឹក | លុបកុងត្រា | ១៣៨១សជណ.សរ ចុះ១៤/០៨/០០ |
| | | | | | | ១៣៨១សជណ.សរ |

| | | | | | | |
|---|---|---|---|---|---|---|
| 53 | Maca Plantation | កំពង់ស្ពឺ | 10,800 | កៅស៊ូ | លុបកុងត្រា | ចុះ១៤/០៨/00 |
| 54 | Chung Thai Investment | កោះកុង | 550 | ដំឡូងមីឈើហូបផ្លែ | លុបកុងត្រា | ១៣៨១សជណ.សរ ចុះ១៤/០៨/00 |
| 55 | Cambodia Shan Shoei | កោះកុង | 3,830 | ឈើហូបផ្លែ ចិញ្ចឹមសត្វ | លុបកុងត្រា | ១៣៨១សជណ.សរ ចុះ១៤/០៨/00 |
| | **សរុបទូទាំងប្រទេស** | | **829,074** | | | |

*ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។*

## ៣.៤. តួនាទីរបស់យោធាក្នុងការផ្តល់ដីសម្បទាន

ក្នុងឆ្នាំ១៩៩៤ រដ្ឋាភិបាលបានពង្រីកសិទ្ធិឱ្យយោធាដើម្បីគ្រប់គ្រងផ្នែកខ្លះនៃព្រៃឈើ និងដីផ្សេងទៀត ដោយសារតែហេតុផលខាងសន្តិសុខ ។ ជាលទ្ធផល យោធាបានចាប់ផ្តើមគ្រប់គ្រងដីធ្លីដ៏ច្រើនសន្ធឹក ។ បន្ទាប់ពីការស្តារសន្តិភាពក្នុងឆ្នាំ១៩៩៧ យោធាបានបន្តកាន់កាប់ផ្ទៃដីដែលមានទំហំមិនច្បាស់លាស់ ហើយមួយផ្នែកនៃដីធ្លីទាំងនេះ បានប្រគល់ជាសម្បទានទៅឱ្យក្រុមហ៊ុន ។ យោធាមានផែនទីផ្ទាល់ខ្លួនសំរាប់ដីសម្បទានដែលខុសគ្នាពីផែនទីដែលក្រសួងកសិកម្មមាន ។ យោធាជាញឹកញាប់ធ្វើរំលងក្រសួងកសិកម្មក្នុងការផ្តល់ដីសម្បទានកសិកម្ម ដូច្នេះហើយក្រសួងកសិកម្មមិនបានរាយការណ៍ទេពីកិច្ចសន្យាមួយចំនួនដែលត្រូវបានធ្វើ និងប្រគល់ដោយយោធា ។ ប៉ុន្តែខាងយោធាក៏បានសុំសេចក្តីព្រមព្រៀងពីនាយករដ្ឋមន្ត្រីដែរ ។ ក្នុងករណីមួយចំនួន យោធាក៏បានពិគ្រោះយោបល់ជាមួយរដ្ឋអំណាចមូលដ្ឋាន និងក្រសួងកសិកម្មដែរ ។ យោធាមិនបានផ្តល់ និងមិនផ្តល់ដី សម្បទានព្រៃឈើទេ បើតាមសំដីរបស់មន្ត្រីក្រសួងកសិកម្ម ។

## ៣.៥. មូលហេតុដែលក្រុមហ៊ុនមិនអនុវត្តកិច្ចសន្យា

មានមូលហេតុមួយចំនួនដែលធ្វើឱ្យក្រុមហ៊ុននានាមិនអាចអនុវត្តកិច្ចសន្យា ។ មូលហេតុចំបងមួយ គឺមានភាគីច្រើននាក់ដែលទាមទារសិទ្ធិជាម្ចាស់លើដីមុខសញ្ញា ។ រឿងដែលឧស្សាហ៍កើតមានគឺថា បន្ទាប់ពីក្រុមហ៊ុនធ្វើការសិក្សាពីលទ្ធភាពដោយខ្លួនឯង និងបានទទួលការយល់ព្រមពីក្រុមប្រឹក្សារដ្ឋមន្ត្រី និងក្រសួងកសិកម្មរួចមក មានអ្នកផ្សេងទៀតបានចាប់យក និងព័ទ្ធរបងលើដីនោះ ។ គេទទួលស្គាល់ថា ការសិក្សាលទ្ធភាពមួយចំនួន មិនបានធ្វើត្រឹមត្រូវទេ ហើយក្រុមហ៊ុនមួយចំនួន មិនបានដឹងពីប្រព័ន្ធគ្រប់គ្រងដីធ្លីនៅក្នុងមូលដ្ឋាន ។ ក្នុងករណីខ្លះ ពួកអ្នកមានឥទ្ធិពលនៅមូលដ្ឋានបានរំលោភយកដី ។ បញ្ហារឹតតែស្មុគស្មាញឡើង នៅពេលជនទាំងនេះ អាចទទួលបានក្រដាសស្នាមសំរាប់ដីធ្លីជាប់ទាក់ទិន ។ ក្នុងករណីមួយចំនួនទៀត ក្រុមហ៊ុនបានដកខ្លួនចេញវិញ ពីព្រោះពួកគេបានប៉ាន់ស្មានចំណូលដែលអាចទទួលបានពីការធ្វើអាជីវកម្មលើស ។ ហើយក៏មានគេរាយការណ៍ពីក្រុមហ៊ុនមួយចំនួនដែលបានទិញដីទុកលក់យកចំណេញ ជាជាងសំរាប់ប្រើប្រាស់ធ្វើផលិតកម្ម ។

## ៣.៦. ឡូត៍នេសាទសម្បទាន

ប្រទេសកម្ពុជាមានធនធានទឹកសាបយ៉ាងធំ: គេប៉ាន់ស្មានថា ប្រហែល ១០% នៃផ្ទៃប្រទេសត្រូវលិចទឹករបូត ឬលិចច្រើនខែ[២] ។ ក្នុងន័យនេះ កម្ពុជាជាប្រទេសមានធនធានទឹកសាបប្រសើរជាងគេបំផុតក្នុងទ្វីបអាស៊ី (World Bank 2001) ។ បរិស្ថានទឹកនៅក្នុងតំបន់បឹងទន្លេសាបដែលជាតំបន់នេសាទត្រីទឹកសាបដ៏ធំ គឺមានលក្ខណៈ

[២] តារាង២.១ បង្ហាញតួលេខត្រឹមតែ ០.៩លានហិកតារប៉ុណ្ណោះដែលគ្របដណ្តប់ដោយផ្ទៃទឹក ។ តួលេខនេះប្រហែលជាតំបន់ដែលលិចទឹកជានិច្ចកាលតែប៉ុណ្ណោះ ។

ពិសេសខុសគេ ។ ទន្លេសាបនាំទឹកហូរចេញពីបឹងធំ ទៅជួបប្រសព្វជាមួយនឹងទន្លេមេគង្គនៅត្រង់ទីក្រុងភ្នំពេញ រួចហូរឆ្ពោះទៅទិសខាងត្បូងតាមទន្លេមេគង្គក្រោម និងទន្លេបាសាក់ ។ នៅរដូវវស្សា ទឹកទន្លេមេគង្គឡើងខ្ពស់ហើយរុញទឹកឱ្យហូរបញ្ច្រាសចូលក្នុងបឹងទន្លេសាប ។ នៅរដូវប្រាំងទឹកហូរចេញពីបឹងធំឆ្ពោះទៅទន្លេមេគង្គក្រោមវិញ។ ចរន្តទឹកនេះបានបង្កើតលក្ខខណ្ឌបរិស្ថានប្រសើរបំផុតសំរាប់សកម្មភាពជីវសាស្ត្រនៅក្នុងទឹកៈ ត្រីក៏ដូចជាដំណាំនិងរុក្ខជាតិផ្សេងៗលូតលាស់បានល្អ ។ ទោះជាកម្ពុជាមានផ្ទៃដីតូចក៏ដោយ ក៏មានចំណាត់ថ្នាក់ខ្ពស់ក្នុងពិភពលោកចំពោះទំហំផលិតផលត្រីទឹកសាប ។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំចុងក្រោយ ប្រព័ន្ធជលផលកម្ពុជាបានទទួលរងការខូចខាតដោយសារការដុះដីល្បប់ធ្វើឱ្យទឹករាក់ ការបំផ្លាញព្រៃឈើដ៏ធ្ងន់ធ្ងរ និងដោយសារធារទឹកមានលក្ខណៈមិនទៀងទាត់ ។ ដូច្នេះហើយ គេពិបាកនឹងកំណត់ទំហំផ្ទៃដីលិចទឹកឱ្យបានពិតប្រាកដនៅក្នុងតំបន់មួយចំនួន ។

កិច្ចសន្យានេសាទធ្វើសំរាប់រយៈពេលពី ១-៤ឆ្នាំ ។ ឡូត៍នេសាទមានបីប្រភេទៈ ខ្នាតធំ មធ្យម និងតូច ។ គេប៉ាន់ថា ផ្ទៃទឹកសរុប ១.០០០.០០០ហិកតារត្រូវបានគេដាក់ឱ្យដេញថ្លៃ និងផ្តល់កិច្ចសន្យានេសាទជារៀងរាល់ឆ្នាំ (កំណត់ត្រារដ្ឋាភិបាល) ។ ឡូត៍នេសាទធំៗមានចំនួន ១៦៨ ។ សម្បទានឡូត៍នេសាទបែងចែកតាមទំហំឡូត៍ មានចុះនៅក្នុងតារាង៣.៤ ហើយផែនទី និងទីតាំងឡូត៍នេសាទក្នុងទូទាំងប្រទេសមានបង្ហាញក្នុងផែនទី៥ ។ តារាងបង្ហាញថា កិច្ចសន្យានីមួយៗមានទំហំមិនធំណាស់ណាទេ បើធៀបនឹងទំហំដែលមាននៅក្នុងកិច្ចសន្យាព្រៃសម្បទាន និងដីសម្បទានកសិកម្ម ។ វាបង្ហាញផងដែរពីការផ្តល់សម្បទាននេសាទឱ្យធ្វើអាជីវកម្ម ទាំងនៅតាមដងទន្លេសាប និងតាមដងទន្លេមេគង្គ[៣] ។

នាយកដ្ឋានជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ជាអ្នកកសាងច្បាប់ស្តីពីការនេសាទ និងគ្រប់គ្រងតំបន់លិចទឹកទាំងអស់ ។ ចាប់តាំងពីឆ្នាំ១៩៩៣ មក មានព្រះរាជក្រឹត្យការពារផ្ទៃទឹកសាបទាំងអស់ ។ អ្នកធ្វើអាជីវកម្មមានបីប្រភេទៈ អាជីវករធុនធំដែលគេគិតថា តែងប្រកបអាជីវកម្មតាមតំបន់ឡូត៍សម្បទាននេសាទជាក់លាក់ដែលបានចុះហត្ថលេខា (ច្បាប់អនុញ្ញាតរយៈពីរឆ្នាំ) អាជីវករធុនមធ្យមដែលធ្វើអាជីវកម្មក្នុងតំបន់ចំហទូទៅ ក៏ដូចជាក្នុងតំបន់មានព្រំប្រទល់កំណត់ជាក់លាក់ ហើយមានអាជ្ញាប័ណ្ណ និងអ្នកនេសាទខ្នាតតូច (គ្រួសារ) ដែលធ្វើការនេសាទត្រឹតែតាមតំបន់ចំហប៉ុណ្ណោះ ។

នាឆ្នាំថ្មីៗកន្លងទៅនេះ បណ្តាសហគមន៍ដែលរស់នៅតាមមាត់ទឹក មានសិទ្ធិនេសាទលើផ្ទៃទឹកកាន់តែតូចទៅៗ ដោយសារតំបន់នេសាទរបស់អាជីវករខ្នាតធំ និងមធ្យមកាន់តែរីកធំឡើងៗ ។ ជាងនេះទៅទៀត ដោយសារសម្ពាធប្រជាជន មានការកាប់រានព្រៃលិចទឹកនានា យកដីធ្វើកសិកម្មនៅតាមតំបន់ជុំវិញទន្លេសាប និងតំបន់រងទឹកភ្លៀងនានា ។ ADB (2001) រាយការណ៍ថា កាកសំណល់ពីវាលស្រែ (ដែលអាចមានដូចជា ល្បាប់ម៉ដ្ឋ ជីគីមី និងថ្នាំពុលផ្សេងៗ) អាចមានឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរដល់សក្តានុពលនេសាទនៃតំបន់បឹងទន្លេសាប ។ គេគិតថាការបូមភក់ពីបាតទន្លេ ឬបឹង មិនអាចធ្វើទៅកើតទេ ។

កាលពីឆ្នាំ២០០០ រដ្ឋាភិបាលបានប្រកាសលុបចោលឡូត៍នេសាទមួយចំនួន ដែលមានប្រសិទ្ធិភាពចាប់ពីខែមិថុនា ឆ្នាំ២០០១ ។ សេចក្តីសំរេចនេះនឹងពង្រីកតំបន់នេសាទចំហនានា ហើយគឺជាជំហានដ៏ល្អមួយសំដៅពង្រឹងសន្តិសុខស្បៀងនៅក៏រិតគ្រួសារ នៅតាមតំបន់ទាំងឡាយ ។

---

[៣] គេមិនផ្តល់សម្បទាននេសាទនៅក្នុងទន្លេទេ ។ សម្បទាននេសាទធ្វើនៅតាមព្រែក បឹង និងផ្ទៃទឹកនានា ។

ផែនទី៥: ឡូត៍នៃសាទ និងតំបន់ទ្រនាប់ ១០គម

**តារាង៣.៤. ទំហំ និងចំនួនឡូត៍នេសាទ ឆ្នាំ២០០០**

| ទំហំឡូត៍នេសាទ គ.ម២ | ចំនួនឡូត៍នេសាទ | ភាគរយនៃឡូត៍នីមួយៗធៀបនឹងផ្ទៃឡូត៍នេសាទទាំងអស់ |
|---|---|---|
| <10 | 39 | 23 |
| 10 - <20 | 20 | 12 |
| 20 - <40 | 33 | 20 |
| 40 - <60 | 18 | 11 |
| 60 - <80 | 19 | 11 |
| 80 - <100 | 8 | 5 |
| 100 - <150 | 17 | 10 |
| >150 | 14 | 8 |
| **ផ្ទៃសរុប = 9,634 km²** | **សរុប = 168** | **100** |

*ប្រភព: នាយកដ្ឋានជលផល ឆ្នាំ២០០១ ។*

## ៣.៧. ឧសង្រេះស្ដីពីការគ្រប់គ្រងដីធ្លី

ការវែកញែកខាងលើបានបង្ហាញថា ដី ៤.១២លានហិកតារគឺជាព្រៃសម្បទាន និង ៣.២០លានហិកតារជាដីព្រៃបំរុង ។ តាមការប្រៀបធៀបជាមួយទិន្នន័យក្នុងតារាង២.១ គេឃើញថា ដីព្រៃជាកម្មសិទ្ធិរដ្ឋ *ដែលមិនមែនជាដីសម្បទាន ឬតំបន់អភិរក្ស* មានចំនួន ៣.៣២លានហិកតារ ។ ឡូត៍នេសាទមានប្រហែល ១លានហិកតារ ដីដាំដុះរបស់កសិករមាន ២.៧១លានហិកតារ និងដីកសិកម្មគ្រប់គ្រងដោយម្ចាស់សម្បទានមានប្រហែល ០.៨៣លានហិកតារ ។ តំបន់ទីប្រជុំជន ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវទឹកនានា... គ្របដណ្ដប់ផ្ទៃដីប្រហែល ១លានហិកតារ ហើយដីប្រហែល ០.១លានហិកតារជាតំបន់មីន ។ ដូច្នេះវាមានន័យថា ដីព្រៃល្បោះ ដីដែលគ្មានដើមឈើ ដីមានកូនឈើតូចៗ និងតំបន់មិនប្រើប្រាស់ប្រហាក់ប្រហែលគ្នានេះ ដែលមិនទាន់បានប្រកាសថា សំរាប់ការប្រើប្រាស់អ្វីជាក់លាក់ ឬស្ថិតក្រោមកម្មសិទ្ធិ ឬការគ្រប់គ្រងរបស់អ្នកណាមួយក្រៅពីរដ្ឋ គឺមានប្រហែល ១.៧៣លានហិកតារ យោងតាមទិន្នន័យដែលបានវិភាគហើយ ។ ដីនេះអាចយកទៅប្រើប្រាស់ ធ្វើជាដីឡូត៍ផ្ដល់ឱ្យអ្នកគ្មានដីធ្លី កសាងមជ្ឈមណ្ឌលឧស្សាហកម្ម ធ្វើទីក្រុង ឬពង្រីកដំណាំពាណិជ្ជកម្ម ដោយ*គ្មានប៉ះពាល់អ្វីដល់ការប្រើប្រាស់ដីក្នុងពេលបច្ចុប្បន្ន* ។ ប៉ុន្តែត្រូវប្រុងប្រយ័ត្នលើចំណុចសំខាន់មួយៈ ដីនេះមួយចំណែកប្រហែលជាខាងយោធាបានផ្ដល់ជាសម្បទានរួចទៅហើយ ដូច្នេះត្រូវដកវាចេញពីចំនួន ១.៧៣លានហិកតារ ក្នុងការគណនាផ្សេងៗអំពីការបែងចែកដីនៅសល់ ។

## ជំពូក បួន

# រដ្ឋបាលដីធ្លីៈ ការទទួលខុសត្រូវ និងការផ្តល់ប័ណ្ណកម្មសិទ្ធិ

### ៤.១. សាវតារ

មុននឹងពិភាក្សាលំអិតពីរដ្ឋបាលដីធ្លី និងប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិ យើងគួររំលឹកពីការបែងចែកដីនៅឆ្នាំ ១៩៨៩ ជាមុនសិន ។ ការបែងចែកដីនៅចុងទសវត្សរ៍១៩៨០ គឺជាការទទួលស្គាល់ស្ថានភាពជាក់ស្តែងមួយនៃដីធ្លី ដែលប្រជាជនបានគ្រប់គ្រងរួចហើយតាម*ប្រព័ន្ធក្រុមសាមគ្គី* ប៉ុន្តែក៏មានការបែងចែកដីថ្មីខ្លះដែរ ។ កម្ពុជាទើបតែងើបចេញពីរបបធ្វើសហករកសិកម្ម និងកសិកម្មសមូហភាពអស់រយៈពេលមួយទសវត្សរ៍កន្លះ ហើយប្រជាជន និងរដ្ឋបាល មិនបានទទួលស្គាល់ ឬអនុវត្តទស្សនៈនៃទ្រព្យសម្បត្តិឯកជនឱ្យបានឯកភាពគ្នានៅឡើយ ។ ទោះបីជាដីត្រូវបានបែងចែក និងក្លាយជាកម្មសិទ្ធិឯកជនក៏ដោយ ក៏មិនទាន់បានកំណត់ព្រំដីនីមួយៗឱ្យបានច្បាស់លាស់ជាផ្លូវការនៅឡើយ ។ គេមិនបានបំពាក់សំភារៈ និងមធ្យោបាយឱ្យអាជ្ញាធរ សំរាប់ធ្វើកិច្ចការនេះទេ[១] ឯកសិករក៏មិនយកចិត្តទុកដាក់លើបញ្ហានេះដែរ ពីព្រោះគេទាំងអស់គ្នាស្គាល់អ្នកជិតខាង និងព្រំប្រទល់ដីខ្លួនហើយ ។ ម្យ៉ាងវិញទៀត កសិករភាគច្រើនក៏មិនសូវចេះអក្សរ និងមិនសូវបានដឹងពីច្បាប់ ដូច្នេះហើយក៏ធ្វើការគ្រប់គ្រងដីធ្លីរបស់ខ្លួនតាមប្រព័ន្ធប្រពៃណី និងមិនចាប់អារម្មណ៍ពីក្រដាសស្នាមផ្លូវការនោះទេ ។

ប្រព័ន្ធចុះបញ្ជីដីធ្លី និងធ្វើប័ណ្ណកម្មសិទ្ធិនៅក្នុងប្រទេសកម្ពុជា គឺខុសគ្នាពីប្រព័ន្ធនៅក្នុងប្រទេសជាច្រើនទៀត ។ ឧទាហរណ៍ អាជ្ញាធរតែមួយទទួលខុសត្រូវ និងធ្វើការចុះបញ្ជីទាំងដីកសិកម្ម និងដីលំនៅដ្ឋាន នៅក្នុងតំបន់ជនបទក៏ដូចជានៅទីប្រជុំជននានា ។ ក្នុងឆ្នាំ១៩៨៩-៩៤ នាយកដ្ឋានសុរិយោដីស្ថិតនៅក្រោមក្រសួងកសិកម្ម ។ មន្ត្រីសុរិយោដីខេត្ត និងស្រុកនៃនាយកដ្ឋានសុរិយោដី ទទួលអនុវត្តការងារ ហើយអភិបាលខេត្តគឺជាអាជ្ញាធរចុងក្រោយបង្អស់ក្នុងការចេញប័ណ្ណសំរាប់ទាំងដីកសិកម្ម និងដីលំនៅដ្ឋាន ។ ក្នុងឆ្នាំ១៩៩៥-៩៨ នាយកដ្ឋានសុរិយោដីត្រូវបានផ្ទេរឱ្យទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ។ សិទ្ធិសំរេចចុងក្រោយ ក៏បានប្តូរពីអភិបាលខេត្ត ទៅប្រធាននាយកដ្ឋានសុរិយោដី ។ នៅឆ្នាំ១៩៩៨ នាយកដ្ឋានសុរិយោដី (បច្ចុប្បន្នហៅថា អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ត្រូវផ្ទេរម្តងទៀត ទៅនៅក្រោមក្រសួងដែលទើបបង្កើតថ្មីឈ្មោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ តួនាទីចំបងមួយរបស់ក្រសួងនេះ គឺធ្វើអង្កេតដ៏ទូលាយមួយ ធ្វើផែនទី និងចុះបញ្ជីដីធ្លីទាំងអស់ក្នុងប្រទេស ។

[១] ការិយាល័យសុរិយោដីមជ្ឈិមបានបញ្ជាក់ពីបញ្ហានេះ ។

## ៤.២. ការចុះបញ្ជីចោះៗ (Sporadic Registration)

យន្តការផ្លូវការនៃការផ្តល់ប្លង់ដី និងការចុះបញ្ជីនៅក្នុង *ប្រព័ន្ធចុះបញ្ជីចោះៗ* ដោយយោលទៅតាមគោលនយោបាយបច្ចុប្បន្ន មានដូចតទៅ :

ក. អ្នកស្នើសុំ ធ្វើពាក្យសុំតាមគំរូស្តង់ដាមួយ ដាក់ជូនទៅប្រធានឃុំរបស់ខ្លួន ។ ពាក្យសុំដែលបានបំពេញសព្វគ្រប់ ត្រូវបានចុះបញ្ជាក់ដោយប្រធានឃុំ និងបញ្ជូនទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល (OLMUPCL) នៅថ្នាក់ស្រុក ។ ម្ចាស់ដីបានទទួលបង្កាន់ដៃមួយ ចំពោះការដាក់ពាក្យសុំរបស់ខ្លួន ។

ខ. អនុគណៈកម្មការមួយត្រូវបានបង្កើតឡើងដែលមានប្រធានឃុំជាប្រធាន ប្រធានភូមិ (នៃភូមិអ្នកដាក់ពាក្យសុំ) មន្ត្រីម្នាក់ ឬពីរនាក់នៃ OLMUPCL (ថ្នាក់ស្រុក) និងចាស់ព្រឹទ្ធាចារ្យម្នាក់ដែលមកពីសហគមន៍ និងដែលមានចំណេះដឹង ហើយមានគេគោរពរាប់អាននៅក្នុងភូមិជាប់ពាក់ព័ន្ធ ។

គ. ដោយមានការពិគ្រោះជាមួយអ្នកដាក់ពាក្យសុំ អនុគណៈកម្មការកំណត់កាលបរិច្ឆេទសំរាប់ធ្វើអធិការកិច្ច ។ ម្ចាស់ដីដែលនៅជិតខាងអ្នកដាក់ពាក្យសុំក៏ត្រូវបានអញ្ជើញមកបញ្ជាក់ និងឯកភាពទៅវិញទៅមកអំពីព្រំដី នៅក្នុងដំណើរការវាស់វែង ។

ឃ. មុនពេលចុះទៅពិនិត្យ មានសេចក្តីប្រកាសមួយ (ធ្វើឡើងដោយអភិបាលស្រុក) អំពីគោលបំណងរបស់បេក្ខជនដាក់ពាក្យសុំ ដើម្បីសុំប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់ខ្លួន ។ សេចក្តីប្រកាសទុករយៈពេល ១០-១៥ថ្ងៃ សំរាប់ឱ្យភាគីមានជាប់ទាក់ទិនណាមួយ ដើម្បីធ្វើការជំទាស់ ឬប្រឆាំងនឹងពាក្យសុំ ។ សេចក្តីប្រកាសនេះត្រូវបានបិទផ្សាយនៅទីតាំងដី ឬនៅជិតទីនោះ (ឧទាហរណ៍ ក្នុងភូមិ ឬនៅការិយាល័យឃុំ ឬការិយាល័យស្រុកដែលពាក់ព័ន្ធ) ។

ង. នៅក្នុងអំឡុងពេលចុះពិនិត្យ បេក្ខជនត្រូវដោតបង្គោលនៅត្រង់កន្លែងសមស្រប ដើម្បីកំណត់ព្រំដី និងកំណត់ទំរង់ដីរបស់ខ្លួន ។ ក្នុងដំណាក់កាលនេះ អ្នកជិតខាងអាចលើកការជំទាស់បាន ប្រសិនបើមាន ។ អង្កេតដីធ្លីត្រូវបានបញ្ចប់នៅពេលដែលមានការពេញចិត្តលើការដៅព្រំដី ។ មានគំរូពាក្យមួយដែលត្រូវបំពេញ ហើយត្រូវបញ្ជាក់ដោយអ្នកជិតខាង និងសមាសភាពនៅក្នុងអនុគណៈកម្មការ ។ មានការកត់ត្រាសាវតាបេក្ខជន ពតិមានលំអិតអំពីគ្រួសារ និងវិធីនៃការបានទទួលដីមកកាន់កាប់ (ឧទាហរណ៍ បន្តមរតក ទិញ) ។ មានការកត់ត្រាដំណាំ ឬសំណង់លើដីនោះផងដែរ ។ ក្នុងករណីដែលមានអ្នកជិតខាងមួយ ឬច្រើនជាស្ថាប័នរដ្ឋ ត្រូវអញ្ជើញអ្នកតំណាងនៃស្ថាប័ននោះមកចូលរួមធ្វើអធិការកិច្ចព្រំដី ។

ច. ក្នុងករណីមានទំនាស់ជាប់ទាក់ទងនឹងពាក្យសុំរបស់បេក្ខជន កិច្ចការខាងលើត្រូវផ្អាកសិន រហូតទាល់តែមានដំណោះស្រាយរួចរាល់ ។ ប្រសិនបើគ្មានទំនាស់ទេ គំរូពាក្យនោះត្រូវបានចុះហត្ថលេខាដោយប្រធានឃុំក្នុងសមត្ថកិច្ចខ្លួនជាប្រធាន ហើយបញ្ជូនទៅកាន់ OLMUPCL ថ្នាក់ស្រុក ដោយមានអនុសាសន៍សុំឱ្យចេញវិញ្ញាបនប័ត្រ ។ បន្ទាប់មកឯកសារពាក់ព័ន្ធត្រូវបានបញ្ជូនទៅអភិបាលស្រុក ។

ឆ. ក្នុងករណីដីកសិកម្ម អភិបាលស្រុកអាចផ្តល់ការឯកភាពឱ្យចេញវិញ្ញាបនប័ត្រ ប្រសិនបើខ្លួនពេញចិត្តហើយ ។ អភិបាលស្រុក អាចកោះហៅឱ្យមានការបញ្ជាក់ពីអ្នកពាក់ព័ន្ធ បើសិនមានការចាំបាច់ ។ នៅក្នុងករណីដីលំនៅដ្ឋាន ប្រធានការិយាល័យសុរិយោដីថ្នាក់ស្រុក លើកអនុសាសន៍ជូនអភិបាលស្រុកសំរាប់

ពិនិត្យផ្ទៀងផ្ទាត់ ហើយអភិបាលស្រុកបញ្ជូនករណីនោះ ទៅកាន់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (DLMUPCC) ថ្នាក់ខេត្ត ។ មន្ទីរនេះដាក់ឯកសារបញ្ជូនទៅអភិបាលខេត្ត ដើម្បីសុំការឯកភាពជាចុងក្រោយ និងចេញវិញ្ញាបនប័ត្រ ។

ជ. ដំណើរការមិនមែនចប់នៅត្រឹមនេះទេ។ នៅក្នុងករណីដីកសិកម្ម OLMUPCLថ្នាក់ស្រុក បញ្ជូនសំណុំរឿងទៅកាន់ អាជ្ញាធរថ្នាក់មជ្ឈិម (ការិយាល័យសុរិយោដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី) ដើម្បីពិនិត្យមើលភាពស្របច្បាប់ ហើយពិនិត្យមើលថាតើនីតិវិធីទាំងឡាយត្រូវបានប្រតិបត្តិតាមត្រឹមត្រូវដែរឬទេ ។ ក្នុងករណីដីលំនៅដ្ឋាន អាជ្ញាធរខេត្តបញ្ជូនសំណុំបែបបទមកកាន់អាជ្ញាធរមជ្ឈិម ដើម្បីត្រួតពិនិត្យពីនីតិវិធី និងភាពស្របច្បាប់ដូចគ្នា ។ នៅក្នុងករណីទាំងពីរនេះ ប័ណ្ណកម្មសិទ្ធិត្រូវបានចេញឱ្យនៅក្រោយពេលដែលការិយាល័យសុរិយោដីកណ្តាល បានផ្ទៀងផ្ទាត់នីតិវិធី និងលក្ខណៈស្របច្បាប់ រួចចុះពត៌មានលំអិតនៃករណីនោះនៅក្នុងបញ្ជីកម្មសិទ្ធិអចលនទ្រព្យ ។ សំណុំឯកសារមួយត្រូវបានបង្កើតឡើងនៅការិយាល័យសុរិយោដីកណ្តាល សំរាប់ដីនីមួយៗ ដែលមានចេញប័ណ្ណកម្មសិទ្ធិ ។

## ៤.៣. ការចុះបញ្ជីជាប្រព័ន្ធ (Systematic Registration)

ក្នុងករណីនៃការចុះបញ្ជីជាប្រព័ន្ធ ដែលជាប្រព័ន្ធមួយត្រូវបានដាក់អនុវត្តកន្លងមកដោយមានជំនួយបច្ចេកទេសពី GTZ និង FinnMap នីតិវិធីពឹងផ្អែកលើរូបថតពីអាកាសសំរាប់ការគូរផែនទី ។ កន្លងមកប្រព័ន្ធនេះ ត្រូវបានអនុវត្តនៅផ្នែកខ្លះនៃក្រុងព្រះសីហនុ តាកែវ កណ្តាល កំពត និងកំពង់ធំ ។ នីតិវិធីមានបង្ហាញក្នុងក្រាហ្វិក១ ។

លក្ខណៈខុសគ្នាជាមូលដ្ឋានអំពីប្រព័ន្ធចុះបញ្ជីដីធ្លីដោយចោះៗ គឺថា នៅក្នុងប្រព័ន្ធចុះបញ្ជីដីធ្លីជាប្រព័ន្ធ កសិករមិនគ្រាន់តែពឹងផ្អែកលើការវាស់វែងរូបវ័ន្តដោយការប្រើម៉ែត្រសំរាប់វាស់វែងប៉ុណ្ណោះទេ ប៉ុន្តែមានការប្រើប្រាស់យ៉ាងទូលំទូលាយនូវផែនទីលំអិតដែលគូរចេញមកពីរូបថតពីលើអាកាស ។ មួយចំណែកទៀត ដំណើរការពិគ្រោះយោបល់មានភាពធំទូលាយជាង និងត្រូវបានធ្វើវិមជ្ឈការ ។ មិនតែប៉ុណ្ណោះ ការចុះបញ្ជីជាប្រព័ន្ធមានតំលៃថោកជាង បើគណនាសំរាប់ការធ្វើប័ណ្ណកម្មសិទ្ធិនីមួយៗ (នាយកដ្ឋានសុរិយោដីមជ្ឈិម បានផ្តល់ពត៌មានឱ្យនៅពេលជួបពិភាក្សាជាមួយគ្នា) ។

ចំនួនប័ណ្ណកម្មសិទ្ធិដែលបានចេញឱ្យរហូតមកដល់ពេលនេះ មានបង្ហាញនៅក្នុងតារាង៤.១ ។ ក្នុងនេះគេអាចឃើញច្បាស់ថា ការផ្តល់ប័ណ្ណកម្មសិទ្ធិគិតតាមខេត្ត មានការខុសគ្នាខ្លាំងណាស់ ។

## នីតិវិធីបង្កើតផែនទីសន្ទស្សន៍សុរិយោដី និងបញ្ជីដីធ្លី (ការកាត់ក្តីព្រំដីជាប្រព័ន្ធ)



ចំនួនប័ណ្ណកម្មសិទ្ធិដែលបានផ្តល់នៅក្នុងខេត្តកណ្តាល តាកែវ កំពត បណ្តាខេត្តមានប្រជាជនជាច្រើនទៀត នៅភាគខាងត្បូងនៃប្រទេស និងនៅខេត្តសៀមរាប មានសមាមាត្រខ្ពស់ហួសគេជាខ្លាំង ។ លក្ខណៈផ្ទុយគ្នាមួយដែលគួរឱ្យចាប់អារម្មណ៍ គឺពុំមានការចេញប័ណ្ណកម្មសិទ្ធិសោះនៅខេត្តមណ្ឌលគិរី ។ តារាងក៏បានបង្ហាញដែរថា ក្នុងឆ្នាំ១៩៨៩-៩៥ មានការចេញប័ណ្ណបញ្ជាក់កម្មសិទ្ធិឱ្យច្រើនជាងក្នុងឆ្នាំ១៩៩៥-២០០០ ។ ទោះបីជាពុំមានហេតុផលជាផ្លូវការសំរាប់បញ្ជាក់រឿងនេះក្តី ក៏គេគិតថា ប្រហែលមកពីករណីងាយស្រួលនានាត្រូវបានបញ្ចប់យ៉ាងលឿនតាំងពីដើមដំបូងមកម្លេះ ។ ទំនាស់កាន់តែកើនឡើងនៅក្រោយឆ្នាំ១៩៩២-៩៣ ហើយលក្ខណៈភូមិសាស្ត្រដ៏លំបាក និងកង្វះខាតសំភារៈនិងបុគ្គលិក គឺជាកត្តាមួយចំនួនដែលរាំងស្ទះដល់ការចេញប័ណ្ណកម្មសិទ្ធិ ។ ចំណុចចុងក្រោយដែលគួរចាប់អារម្មណ៍ គឺប័ណ្ណកម្មសិទ្ធិដែលបានផ្តល់ហើយ ទាំងក្នុងដំណើរការចុះបញ្ជីដោយចោះ។ និងជាលក្ខណៈប្រព័ន្ធមានទាំងអស់តែជាងកន្លះលានប៉ុណ្ណោះ ធៀបនឹងបង្កាន់ដៃចំនួន ៤.៥លានដែលបានចេញរួចហើយ ។ ជាសង្ខេបប្រហែល ១២% នៃពាក្យសុំត្រូវបានពិនិត្យ និងឯកភាពចេញជាប័ណ្ណឱ្យ ។

**តារាង៤.១ ការរីកចំរើនក្នុងការចុះបញ្ជីដីធ្លី** (ចាប់ពីឆ្នាំ១៩៨៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០០)

| ខេត្ត/ក្រុង | ក. ប័ណ្ណកម្មសិទ្ធិ (១៩៨៩-៩៥) | ខ. ប័ណ្ណកម្មសិទ្ធិ (១៩៩៥ ដល់ចុង ២០០០) | សរុប ក និង ខ |
|---|---:|---:|---:|
| កណ្តាល | 109,749 | 9,675 | 119,424 |
| កំពត | 54,462 | 1,668 | 56,130 |
| តាកែវ | 43,336 | 2,770 | 46,106 |
| ស្វាយរៀង | 38,530 | 1,808 | 40,338 |
| ព្រៃវែង | 36,884 | 2,061 | 38,945 |
| សៀមរាប | 28,098 | 5,041 | 33,139 |
| កំពង់ឆ្នាំង | 25,981 | 3,291 | 29,272 |
| កំពង់ស្ពឺ | 22,469 | 4,204 | 26,673 |
| បាត់ដំបង | 19,432 | 6,683 | 26,115 |
| កំពង់ចាម | 16,618 | 6,505 | 23,123 |
| ក្រុងព្រះសីហនុ | 11,659 | 5,779 | 17,438 |
| បន្ទាយមានជ័យ | 13,641 | 3,745 | 17,386 |
| ពោធិសាត់ | 10,857 | 4,140 | 14,997 |
| កោះកុង | 6,490 | 2,756 | 9,246 |
| កំពង់ធំ | 4,973 | 2,152 | 7,125 |
| ភ្នំពេញ | 1,028 | 4,621 | 5,649 |
| ក្រចេះ | 3,064 | 1,261 | 4,325 |
| រតនគិរី | 436 | 1,056 | 1,492 |
| កែប | 570 | 783 | 1,353 |
| ស្ទឹងត្រែង | 00 | 128 | 128 |
| ព្រះវិហារ | 00 | 104 | 104 |
| ឧត្តរមានជ័យ | 00 | 95 | 95 |
| ប៉ៃលិន | 00 | 31 | 31 |
| មណ្ឌលគិរី | 00 | 00 | 00 |
| សរុប | 448,277 | 70,357 | 518,258 |

*កំណត់ចំណាំៈ ទិន្នន័យទាក់ទងទាំងការចុះបញ្ជីដោយចោះ។ និងការចុះបញ្ជីជាប្រព័ន្ធ ។ ប្រភពៈ MLMUPC ។*

# ជំពូក ប្រាំ

# ការពិពណ៌នាពីទិន្នន័យដែលទាក់ទងនឹង ការកាន់កាប់ និងគ្រប់គ្រងដីធ្លី [១]

នៅពេលនេះ យើងចាំបាច់ត្រូវរំលឹកថា កំរងទិន្នន័យនានាដែលនឹងពិពណ៌នានៅខាងក្រោម គឺបានមកពីប្រភពផ្សេងៗគ្នា ។ ទិន្នន័យទាំងនេះមិនបានគ្របដណ្តប់ប្រជាជនដូចគ្នាទេ ហើយអង្កេតនានាក៏ត្រូវបានធ្វើឡើងដោយមានគោលដៅខុសៗគ្នាដែរ ។ ដូច្នេះ វាមានការលំបាកណាស់ក្នុងការប្រៀបធៀបលទ្ធផលនៃអង្កេតមួយទៅនឹងអង្កេតមួយទៀត ។ ជាការពិតហើយ ការប្រៀបធៀបច្បោលៗអាចធ្វើទៅបានរវាងគំរូតាងទាំងអស់ ។ តាមនេះ គេអាចប្រៀបធៀបខ្លះៗ រវាងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ចំនួន ៣ និងប្រៀបធៀបលំអិតរវាងអង្កេតមូលដ្ឋានឆ្នាំ១៩៩៨ (Baseline-98) និងអង្កេតតាមដាននៅឆ្នាំ២០០០ (Follow-up-00) ។ ប៉ុន្តែអង្កេត PET-98 អង្កេត MRC-95-96 និងអង្កេត LADIT-00 មិនអាចប្រៀបធៀបនឹងអង្កេតឯទៀតបានទេ ។ ការវិភាគដូចខាងក្រោម ត្រូវបានធ្វើឡើងដោយមានការយល់ដឹងយ៉ាងច្បាស់ពីរឿងនេះ ។ ការវិភាគបែបនេះ តាមបែបបទរបស់វាត្រូវមានការសិក្សាយ៉ាងលំអិតនូវរបាយការណ៍ជំរឿនកសិកម្ម កំណត់ត្រាដីធ្លី និងអង្កេតដីធ្លីនៅទីក្រុងជាបន្ថែមទៅលើអង្កេតដោយប្រើគំរូតាងពិសេសៗ ប៉ុន្តែនៅកម្ពុជាមិនទាន់មានទិន្នន័យដូច្នេះនៅឡើយទេ ។ នៅខាងក្រោម គឺជាការពិពណ៌នាកំរងទិន្នន័យទាំង៨ ដោយសង្ខេបម្តងមួយៗ ។

## ៥.១. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ ក្នុងសហគមន៍នេសាទរបស់គណៈកម្មការទន្លេមេគង្គនៅឆ្នាំ១៩៩៥-៩៦ (MRC-95-96)

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច គ្រួសារនៃបណ្តាសហគមន៍នេសាទនៅកម្ពុជា ត្រូវបានធ្វើដោយគណៈកម្មការទន្លេមេគង្គ (MRC) នៅក្នុងគំរោង ការគ្រប់គ្រងការនេសាទត្រីទឹកសាបនៅកម្ពុជា ។ គោលបំណងចំបងនៃអង្កេត គឺការវាយតំលៃលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមកិច្ចនៃគ្រួសាររស់នៅតាមបណ្តាឃុំដែលពឹងផ្អែកលើការនេសាទ ដើម្បីផ្តល់ពតិមានចាំបាច់ និងទស្សនៈសមស្រប សំរាប់គ្រប់គ្រងការនេសាទត្រីទឹកសាបឱ្យមានចីរភាពនៅកម្ពុជា ។

ការសិក្សានេះជ្រើសរើសយក ៨ខេត្ត (សៀមរាប បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កណ្តាល ភ្នំពេញ កំពង់ចាម និងកំពង់ធំ) ដែលមានប្រជាជនប្រហែល ៤.១៩លាននាក់រស់នៅក្នុងសហគមន៍នេសាទទឹកសាប ។ ក្នុងខេត្តទាំង៨ គំរូតាង ៥.១១៧គ្រួសារដែលគ្របដណ្តប់ ៨៣ឃុំ នៅក្នុង ៥១ស្រុកនេសាទ ត្រូវបានជ្រើសរើសតាម

[១] ការពិពណ៌នាពីទិន្នន័យបួនក្នុងចំណោមកំរងទិន្នន័យទាំង៨ ត្រូវបានដកស្រង់ចេញពីខ្លឹមសារអត្ថបទលោក ស៊ិក (២០០០) ។

វិធីចៃដន្យ (randomly selected) ដើម្បីតំណាងឱ្យ ៣២៨ឃុំនេសាទ ។ ឃុំជ្រើសរើសទាំងនេះគ្របដណ្តប់ប្រព័ន្ធទឹកពីរធំៗដែលទាក់ទិននឹងការនេសាទត្រីទឹកសាបៈ ប្រព័ន្ធបឹងទន្លេសាប និងទន្លេសាប, និងប្រព័ន្ធទន្លេមេគង្គ-បាសាក់ និងប្រព័ន្ធដីលិចទឹក ។

## ៥.២. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា ឆ្នាំ១៩៩៦ (SES-96)

SES-96 ជាអង្កេតធ្វើដោយវិជ្ជាស្ថានជាតិស្ថិតិ ដែលពិនិត្យបញ្ហាខាងប្រជាសាស្ត្រ និងពលកម្មជាសំខាន់ ។ អង្កេតប្រើវិធីជ្រើសគំរូតាងដោយចៃដន្យជាពីរដំណាក់ ដោយយកភូមិធ្វើជាឯកតាគំរូតាងនៅដំណាក់ទី១ និងយកគ្រួសារធ្វើជាឯកតាគំរូតាងនៅដំណាក់ទី២ ។ ៩.០០០គ្រួសារគំរូតាង ត្រូវបានជ្រើសចេញពី ៧៥០ភូមិគំរូតាង ដែលត្រូវគ្របដណ្តប់លើប្រទេសទាំងមូល ប៉ុន្តែជាក់ស្តែងមាន ២ខេត្ត និងច្រើនភូមិនៅក្នុងខេត្តឯទៀត ដែលត្រូវកាត់ចោលដោយសារហេតុផលខាងសន្តិសុខ ។ អង្កេតនេះផ្តល់ពត៌មានខាងដីធ្លីតិចតួចណាស់ ដូច្នេះហើយមិនសូវមានលើកឡើងក្នុងឯកសារនេះទេ ហើយបើមានលើកខ្លះៗក៏ច្រើនតែនៅក្នុងកំណត់បញ្ជាក់ប៉ុណ្ណោះ ។

## ៥.៣. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា ឆ្នាំ១៩៩៧ (SES-97)

វិជ្ជាស្ថានជាតិស្ថិតិ (NIS) បានធ្វើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ដែលជាអង្កេតគ្រួសារខ្នាតធំទី១ មានពហុគោលដៅ នៅចន្លោះខែឧសភា និងមិថុនា ឆ្នាំ១៩៩៧ ។ អង្កេតមានគោលដៅចំបងប្រមូលទិន្នន័យសំរាប់វាស់វែងកំរិតជីវភាព និងសំរាប់ធ្វើការតាមដាននិងវិភាគភាពក្រីក្រ ។ អង្កេតត្រូវធ្វើឡើងតាមវិធីជ្រើសគំរូតាងចៃដន្យជាពីរដំណាក់ ដោយយកភូមិធ្វើជាឯកតាគំរូតាងដំបូង និងគ្រួសារជាឯកតាគំរូតាងទីពីរ ។ គំរោងកាត់ខ្លី (truncated frame) ដែលប្រើប្រាស់សំរាប់ធ្វើអង្កេត បានគ្របដណ្តប់ភូមិនានាបាន ១០០% នៅភ្នំពេញ ៩១,២% នៅតាមទីប្រជុំជនដទៃទៀត និង ៨៦,៣% នៅតាមជនបទ ។ ដោយសារហេតុផលខាងសន្តិសុខ ខេត្តពីរ និងឃុំមួយចំនួននៅក្នុង ១៥ខេត្តផ្សេងទៀត មិនបានរាប់បញ្ចូលក្នុងគំរោងអង្កេតទេ ។ សមាមាត្រនៃគ្រួសារដែលមិនបានរាប់បញ្ចូល មានចំនួនតិចតួចប្រហែលតែ ៤,៨% នៃគ្រួសារទាំងអស់នៅក្នុង "តំបន់ទីប្រជុំជនផ្សេងទៀត" និង ១,៦% នៃគ្រួសារនៅក្នុងតំបន់ជនបទ ។

ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខាងលើ ៦.០១០គ្រួសារត្រូវបានជ្រើសរើសសំរាប់សំភាសន៍ ដោយមានការបែងចែកដូចខាងក្រោមៈ

| | |
|---|---|
| ទីក្រុងភ្នំពេញ | ភូមិគំរូតាង ១២០ និង គ្រួសារគំរូតាង ១.២០០ |
| ទីប្រជុំជនដទៃទៀត | ភូមិគំរូតាង ១០០ និង គ្រួសារគំរូតាង ១.០០០ |
| តំបន់ជនបទ | ភូមិគំរូតាង ២៥៤ និង គ្រួសារគំរូតាង ៣.៨១០ |
| សរុប | ភូមិគំរូតាង ៤៧៤ និង គ្រួសារគំរូតាង ៦.០១០ |

## ៥.៤. អង្កេតមូលដ្ឋាននៅកម្ពុជាឆ្នាំ១៩៩៨ សំរាប់គំរោងសកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គម (CASD) និងតំបន់គោលដៅរបស់ WFP (Baseline-98)

អង្កេតមូលដ្ឋានរួមគ្នារបស់អង្គការ WFP និង UNICEF ត្រូវបានធ្វើឡើងក្នុងខែឧសភា-មិថុនាឆ្នាំ១៩៩៨ ។ អង្កេតនេះមានគោលបំណងចំបងប្រមូលពត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ សំរាប់យកទៅប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ ការកំណត់គោលដៅ និងការវាយតំលៃ កម្មវិធីពីររបស់អង្គការ គឺ ១-កម្មវិធីសកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍

សង្គម (CASD) ដែលផ្តោតទៅលើបញ្ហាសុខភាព និងអាហារូបត្ថម្ភ និង ២-កម្មវិធីរបស់ WFP ក្នុងវិស័យសន្តិសុខស្បៀង និងភាពងាយទទួលរងគ្រោះ ។ អង្កេតផ្តោតលើខេត្តមួយចំនួន ដោយជ្រើសរើសយកភូមិដែលមានគំរោង CASD និង WFP ។ អង្កេតកំណត់យកជាគំរូតាងតែគ្រួសារណាដែលមានកុមារអាយុក្រោមប្រាំឆ្នាំ ១នាក់យ៉ាងតិច ។

អង្កេតផ្អែកលើវិធីជ្រើសគំរូតាងចៃដន្យមានច្រើនថ្នាក់ ដោយយកភូមិជាឯកតាគំរូតាងគោល ។ ភូមិប្រហែល ៥០ ត្រូវបានជ្រើសរើសដោយចៃដន្យពីខេត្តគោលដៅចំនួន ៦ ដែលមានកម្មវិធី CASD-UNICEF ។ បន្ថែមលើនេះ ១៣ភូមិផ្សេងទៀតរបស់កម្មវិធី CASD-PFD ត្រូវបានជ្រើសរើសតាមវិធីចៃដន្យពីខេត្តក្រចេះ និងស្ទឹងត្រែង ។ ៦២ភូមិគំរូតាងផ្សេងទៀតត្រូវបានជ្រើសចេញពី ៥តំបន់សេដ្ឋកិច្ចស្បៀងរបស់ WFP ដោយផ្អែកលើការបែងចែកភូមិនានាជាតំបន់នៅកំរិតជាតិ ។ សរុបមកគេបានជ្រើសយក ១២៥ភូមិសំរាប់ធ្វើអង្កេត ។

នៅក្នុងភូមិគំរូតាងទាំងនេះ គ្រួសារមានកូនអាយុក្រោមប្រាំឆ្នាំ ត្រូវបានជ្រើសយកជាក្រុមគោលតាមវិធីចៃដន្យ ។ ចំនួនគ្រួសារជ្រើសយកវាអាស្រ័យទៅតាមទំហំភូមិ គឺក្នុងករណីខ្លះមានរហូតដល់ ៣០០គ្រួសារ និងក្នុងករណីខ្លះទៀតមានត្រឹម ៥០គ្រួសារ ។ អង្កេតបានកំណត់ធ្វើសំភាសន៍តែ ៨គ្រួសារបើសិនភូមិមានប្រជាជនសរុបតែ ៨០គ្រួសារ, ១០គ្រួសារបើសិនភូមិមានប្រជាជន ៨០-១២០គ្រួសារ, និង ១២គ្រួសារបើភូមិមានប្រជាជនច្រើនជាង ១២០គ្រួសារ ។ សរុបមកមាន ១.២៣០គ្រួសារត្រូវបានជ្រើសរើសសំរាប់ធ្វើសំភាសន៍ ។

### ៥.៥. អង្កេតមុខសញ្ញាសង្គ្រោះរយៈពេលយូរឆ្នាំ១៩៩៨ (PET-98)

អង្កេត PET ត្រូវបានធ្វើឡើងដោយ WFP នៅខែធ្នូ ឆ្នាំ១៩៩៨ ។ គោលបំណងចំបងនៃអង្កេត គឺដើម្បីផ្តល់ពត៌មានជាមូលដ្ឋានមួយចំនួន ដូចជា លក្ខខណ្ឌសង្គម ស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជនមាតុភូមិនិវត្តន៍ និងជនភៀសសឹកក្នុងស្រុក (IDP)[២] ដើម្បីយកមកប្រៀបធៀប និងវាស់វែងពីផលប៉ះពាល់នៃកម្មវិធីជំនួយក្នុងឆ្នាំ២០០០ ។ ដូចក្នុងអង្កេតមូលដ្ឋានដែរ អង្កេត PET ផ្តោតតែលើចំណែកខ្លះនៃខេត្តជ្រើសរើស ហើយក្នុងនេះ ភូមិធ្វើអង្កេតត្រូវបានជ្រើសចេញពីឃុំគោលដៅរបស់ PET តាមវិធីចៃដន្យ ។ គ្រួសារគោលដៅ គឺគ្រួសារទាំងឡាយណាដែលមានកូនអាយុក្រោមប្រាំឆ្នាំយ៉ាងតិច ១នាក់ ដែលមានម្តាយនៅជាមួយ ។

ផ្អែកលើការបែងចែកជាក្រុមតាមតំបន់ តាមលក្ខណៈដូចគ្នានៃស្ថានភាពសង្គម និងប្រភពដើមនៃជនភៀសសឹកក្នុងស្រុក គំរូតាងត្រូវបានបែងចែកជាបួនតំបន់ ហើយវិធីចៃដន្យមានពីរដំណាក់ ត្រូវបានប្រើប្រាស់ដើម្បីជ្រើសគំរូតាង ។ ក្នុងដំណាក់ទី១ ឃុំប្រាំត្រូវបានជ្រើសចេញពីតំបន់នីមួយៗរបស់ PET តាមវិធីចៃដន្យ ។ ក្នុងដំណាក់ទី២ ក្នុងឃុំនីមួយៗ ភូមិពីរដែលស្របតាមលក្ខណៈវិនិច្ឆ័យរបស់ WFP ត្រូវបានជ្រើសយក រីឯភូមិណាដែលមិននៅក្នុងគោលដៅរបស់ PET ត្រូវបានជំរុះចោល ។ ការជ្រើសរើសភូមិ ត្រូវបានធ្វើឡើងដោយប្រើតារាងចៃដន្យ ។ ប៉ុន្តែឃុំ និងភូមិទាំងឡាយណាដែលមានគ្រោះថ្នាក់ខ្លាំងពេកដោយសារគ្រាប់មីន ដូចជាមានមីននៅតាមផ្លូវចូលទៅឃុំជាដើម គឺត្រូវបានដកចេញពីគំរូតាង ។

ដើម្បីយកឱ្យបាន ១.០៤០គ្រួសារ, ២៦គ្រួសារគំរូតាងត្រូវបានជ្រើសចេញពីភូមិគំរូតាងនីមួយៗ ។ គ្រួសារដែលស្របនឹងលក្ខណៈវិនិច្ឆ័យរបស់ PET ដែលយ៉ាងហោចណាស់មានកូនម្នាក់អាយុក្រោមប្រាំឆ្នាំដែលមានម្តាយនៅជាមួយ ត្រូវបានគេជ្រើសរើសតាមវិធីចៃដន្យ និងតាមវិធីសាស្ត្រជ្រើសរើសមានចន្លោះ (interval selection) ។

---

[២] WFP-Cambodia បានឱ្យនិយមន័យជនភៀសសឹកថា "ជនទាំងឡាយណាដែលត្រូវបានជន្លៀសចេញពីកន្លែងរស់នៅធម្មតារបស់ពួកគេ ដោយសារតែការប្រយុទ្ធគ្នាចាប់តាំងពីក្នុងអំឡុងឆ្នាំ១៩៨៩" (Helmers and Kenefick 1999:12) ។

ក្នុងករណីតិចតួចដែលភូមិមានប្រជាជនតិចពេក គឺពុំមានម្តាយ-កូនគ្រប់ចំនួន ដើម្បីជ្រើសយក ២៦គ្រួសារស្រប តាមលក្ខណៈវិនិច្ឆ័យ គេជ្រើសយកភូមិទីបីមួយទៀតដោយចៃដន្យ ហើយជ្រើសយកគ្រួសារពីភូមិទីបីនោះថែម ដើម្បីបង្គ្រប់ចំនួនដែលត្រូវបញ្ចូលទៅក្នុងអង្កេត ។

## ៥.៦. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជាឆ្នាំ១៩៩៩ (SES-99)[៣]

អង្កេត SES-99 ជ្រើសរើសគំរូតាងតាមវិធីចៃដន្យមានពីរដំណាក់ ដោយជ្រើសយកភូមិគំរូតាងជាឯកតា នៅដំណាក់ទី១ និងគ្រួសារគំរូតាងជាឯកតានៅដំណាក់ទី២ ។ ដោយសារហេតុផលខាងសន្តិសុខ គេបានប្រើប្រាស់ ក្របខ័ណ្ឌកាត់ខ្លី (truncated frame) នៃការជ្រើសរើស ដោយកាត់ភូមិចេញអស់ ៤,៥% ពីព្រោះមានការលំបាកធ្វើ អង្កេតនៅក្នុងភូមិដែលមានអសន្តិសុខ ។ អង្កេត SES-99 គ្របដណ្តប់ ៦.០០០គ្រួសារ ដែលចែកចេញជា ៦០០ភូមិ នៅក្នុងប្រទេស ។ អង្កេតបានធ្វើឡើងជា ២វគ្គ ដើម្បីប្រមូលពតិមានពីការផ្លាស់ប្តូរតាមរដូវកាល ។ វិធីជ្រើសរើស គំរូតាងបែបនេះ អនុញ្ញាតឱ្យធ្វើការប៉ាន់ស្មានផ្សេងៗបាន ទាំងសំរាប់ទីប្រជុំជន ជនបទ និងទីក្រុងភ្នំពេញ, និង សំរាប់តំបន់អេកូឡូស៊ីទាំង៤ គឺមាន វាលទំនាប ទន្លេសាប មាត់សមុទ្រ ខ្ពង់រាប និងតំបន់ភ្នំ ។

*របទាសម្ព័ន្ធគំរូតាង*

| | |
|---|---|
| ភ្នំពេញ | ភូមិគំរូតាង ១២០ និង គ្រួសារគំរូតាង ១.២០០ |
| ទីប្រជុំជនដទៃទៀត | ភូមិគំរូតាង ១៧២ និង គ្រួសារគំរូតាង ១.៧២០ |
| តំបន់ជនបទ | ភូមិគំរូតាង ៣០៨ និង គ្រួសារគំរូតាង ៣.០៨០ |

ទិន្នន័យត្រូវបានប្រមូលតាមរយៈការចុះជួបគ្រួសារគំរូតាងដោយអ្នកចុះអង្កេត ដើម្បីធ្វើសំភាសន៍សមាជិក មួយចំនួននៃគ្រួសារនោះ ។ ការចុះអង្កេតវគ្គ១ ធ្វើឡើងនៅចន្លោះខែមករា-មីនា ឆ្នាំ១៩៩៩ ឯអង្កេតវគ្គ២ នៅ ចន្លោះខែមិថុនា-កញ្ញា ឆ្នាំ១៩៩៩ ។ ខាងអាជ្ញាធរបានអះអាងថា អង្កេតនេះបានផ្តល់ទិន្នន័យយ៉ាងទូលំទូលាយ និង ពេញលេញស្តីពីចំណូលនិងចំណាយ ។ ហើយនេះគឺជាគំរូតាងដែលអាចយកជាតំណាងបាន ដូច្នេះគេអាចធ្វើការ គណនាសំរាប់ប្រជាជនទាំងអស់ ដោយប្រើប្រាស់មេគុណសមស្រប (multipliers) ។

ដូចក្នុងអង្កេតមុនដែរ (SES-97), ចំណែកនៃអង្កេតដែលស្រង់ពតិមានពីដីធ្លីនៅមានទំហំតូចនៅឡើយ ទោះ ជាមានសំនួរចំៗទាក់ទងនឹងដីកសិកម្មនៅក្នុងបញ្ជីសំនួរខុសពីមុនក៏ដោយ ។ ក្នុងឆ្នាំ១៩៩៩ សន្លឹកពតិមានដាច់ ដោយឡែកត្រូវបានផ្តល់ឱ្យសំរាប់ស្រង់ពតិមានស្តីពីដីលំនៅដ្ឋាន និងដីកសិកម្ម ។ បញ្ជីសំនួរទាក់ទងនឹងដីធ្លីសំរាប់ អង្កេត SES-99 មានចុះក្នុងឧបសម្ព័ន្ធនៃឯកសារនេះ[៤] ។

---

[៣] ផ្នែកនេះដែលដកស្រង់ចេញពីឯកសារ RGC (2000) បកស្រាយយ៉ាងច្បាស់ថា គោលដៅចំបងនៃអង្កេតគឺដើម្បីទទួលបាន នូវការប៉ាន់ស្មានពីចំណូល និងចំណាយ ។ ទិន្នន័យដីធ្លីត្រូវបានប្រមូលជាពតិមានបន្ថែមប៉ុណ្ណោះ ។

[៤] ចំពោះអង្កេតទាំង៨, សំនួរទាក់ទិននឹងដីធ្លីដែលស្រង់ចេញពីបញ្ជីសំនួរសំរាប់អង្កេត SES-96, SES-99, និង LADIT-00, មាន ចុះនៅក្នុងឧបសម្ព័ន្ធ ។ សំរាប់អង្កេត Follow-up-00 បញ្ជីសំនួរគឺដូចគ្នានឹង Baseline-98 ដែរ ។ សំរង់ចេញពីបញ្ជីសំនួរ សំរាប់អង្កេតបួនផ្សេងទៀត មានចុះនៅក្នុងឯកសាររបស់លោក ស៊ិក (២០០០) ។

## ៥.៧. អង្កេតតាមដានឆ្នាំ២០០០ (Follow-up-00)

ឧបករណ៍អង្កេតដែលប្រើប្រាស់នៅក្នុងអង្កេត Follow-up-00 គឺដូចគ្នានឹងសំនួរដែលបានប្រើប្រាស់ក្នុងអង្កេត Baseline-98 ដែលបានបង្ហាញខាងលើ ។ របៀបអង្កេតក្នុង Follow-up-00 ក៏ដូចគ្នានឹង Baseline-98 ដែរ ដូច្នេះហើយ វាជាកំរងទិន្នន័យទីពីរបន្ទាប់ពី SES ដែលអនុញ្ញាតឱ្យមានចំនុចប្រៀបធៀបពីរ ។ អង្កេតនេះមាន ១.២៩៨គ្រួសារ បានមកពី ១២៤ភូមិ: ៥៩ភូមិមកពីឃុំ WFP, ៥២ភូមិមកពីឃុំ CASD, និង ១៣ភូមិមកពីខេត្តក្រចេះ និងស្ទឹងត្រែង ។ បន្ទាប់ពីសំអាតទិន្នន័យរួចហើយ មាន ១.១៦៤ឯកតាអង្កេត ដែលអាចប្រើប្រាស់បាន ។

## ៥.៨. ការអង្កេតភាពគ្មានដីធ្លី និងអភិវឌ្ឍន៍ (LADIT-00)[៥]

អង្កេតនេះត្រូវបានធ្វើឡើងនៅក្នុង ១៨៣ភូមិនៃ ១៩ខេត្ត ក្នុងឆ្នាំ១៩៩៩-២០០០ ។ គំរូតាងដំបូងចំនួន ១៤៦ភូមិ (ប្រហែល ១% នៃភូមិទាំងអស់ក្នុងប្រទេសកម្ពុជា) ត្រូវបានស្រាវជ្រាវក្នុងអំឡុងពេលពីខែកញ្ញា ឆ្នាំ១៩៩៩ ដល់ខែមេសា ឆ្នាំ២០០០ ។ គំរូតាងទាំងនេះមិនមែនជ្រើសរើសដោយមានបំណង ឬដោយចៃដន្យទេ ។ ទោះបីគេបានខិតខំគ្របដណ្តប់បណ្តាខេត្តនៅតាមតំបន់ទំនាបឱ្យបានច្រើនតាមអាចធ្វើបាន ប៉ុន្តែការជ្រើសរើសភូមិគឺផ្អែកទាំងស្រុងទៅលើកន្លែងដែលដៃគូស្រាវជ្រាវរបស់ Oxfam កំពុងធ្វើការ ។ ក្នុងខែកក្កដា ឆ្នាំ២០០០ មន្ត្រីអភិវឌ្ឍន៍ជនបទ មកពីក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តនានា បានទទួលការបំពាក់បំប៉នពីរបៀបស្រាវជ្រាវ LADIT ។ បន្ទាប់មកពួកគេបានពង្រីកការស្រាវជ្រាវទៅក្នុង ៣៧ភូមិផ្សេងទៀត នៅក្នុង ១៨ ខេត្ត ។

LADIT ដែលមានន័យថា ឧបករណ៍ស្រង់ពត៌មានពី *ភាពគ្មានដីធ្លី និងការអភិវឌ្ឍន៍* (Ladlessness and Development Information Tool) គឺជាដំណើរការស្រាវជ្រាវមួយដែលអង្គការ Oxfam-GB កសាងឡើងដោយសហការជាមួយនឹង NGOs កម្ពុជា មួយចំនួន ។ LADIT មានគោលដៅស្វែងយល់ពីមូលហេតុនៃភាពគ្មានដីធ្លី និងប្រសិទ្ធិភាពនៃការងារអភិវឌ្ឍន៍ចំពោះជនក្រីក្រ ។ អង្កេត LADIT ត្រូវបានរចនាឡើងដើម្បីជួយសំរួលការពិភាក្សារវាងអ្នកស្រាវជ្រាវ និងអ្នកភូមិ ។ ប៉ុន្តែគេបានបញ្ជាក់ពីចំណុចមួយដែលត្រូវប្រុងប្រយ័ត្នគឺថា ឧបករណ៍នេះត្រូវបានកសាងឡើងសំរាប់តំបន់ទំនាបតាមជនបទក្នុងប្រទេសកម្ពុជា ដូច្នេះវាពុំមានប្រសិទ្ធិភាពសំរាប់តំបន់ទីប្រជុំជនទេ ពីព្រោះវាផ្តោតទៅលើដីកសិកម្ម ហើយវាក៏គ្មានប្រសិទ្ធិភាពដែរសំរាប់តំបន់ខ្ពង់រាបដែលជាកន្លែងមានលំនាំកាន់កាប់ និងប្រើប្រាស់ដីធ្លីដ៏ស្មុគស្មាញ ។

"អង្កេត LADIT នីមួយៗ ផ្តល់ពត៌មានស្តីពីវិសាលភាព មូលហេតុនៃភាពគ្មានដីធ្លី និងពីផលប៉ះពាល់នៃសកម្មភាពអភិវឌ្ឍន៍ទៅលើភាពគ្មានដីធ្លីនៅក្នុងភូមិណាមួយ" (Biddulph 2000) ។ អ្នកស្រាវជ្រាវប្រមូលទិន្នន័យដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម:

- សំភាសន៍ជាមួយប្រធានភូមិ
- អង្កេតពីផ្ទះមួយទៅផ្ទះមួយនៃគ្រួសារដែលគ្មានដីធ្លីទាំងអស់នៅក្នុងភូមិ ដើម្បីស្រង់ពត៌មានពីពេលណា និងមូលហេតុអ្វី ដែលពួកគេបានក្លាយជាអ្នកគ្មានដីធ្លី និង
- ក្រុមពិភាក្សារបស់ LADIT (អ្នកភូមិ ១២នាក់: ប្រុស ៦នាក់ ស្ត្រី ៦នាក់ - មនុស្សចាស់ ៤នាក់ ចាស់ព្រឹទ្ធាចារ្យ ៤នាក់ និងតំណាងគ្រួសារគ្មានដីធ្លី ៤នាក់) ។

---

[៥] សេចក្តីលំអិតដែលបានបង្ហាញនៅទីនេះ ដកស្រង់ចេញពីអត្ថបទរបស់ Biddulph (2000) ។

ការពិនិត្យជារួមថា តើកំរងទិន្នន័យទាំងនេះមានន័យយ៉ាងដូចម្តេចចំពោះការវិភាគពីដីធ្លី មានចុះនៅក្នុងតារាង៥.១ ។ តារាងនេះបង្ហាញថា មិនមែនកំរងទិន្នន័យទាំងអស់សុទ្ធតែអនុញ្ញាតឱ្យធ្វើការសិក្សាពីដីធ្លីយ៉ាងពេញលេញបាននោះទេ ។ អង្កេត SES-99, SES-97, និង PET-98, ហាក់ដូចគ្របដណ្តប់ចំណុចផ្សេងៗបានទូលំទូលាយជាងគេ ។ អង្កេត SES នានា មានសារៈសំខាន់ថែមមួយក៏រិតទៀត ដោយសារវាតំណាងឱ្យប្រទេសទាំងមូល ។

**តារាង ៥.១. ការពិនិត្យជារួម នូវទិន្នន័យស្តីពីដីធ្លីដែលអាចរកបានពីកំរងទិន្នន័យផ្សេងៗ**

| ប្រភេទ | SES-97 | SES-99 | MRC-95-96 | Baseline-98 | Followup-00 | PET-98 | LADIT-00 |
|---|---|---|---|---|---|---|---|
| ចំនួនក្បាលដី | | + | | | | | |
| ចំនួនម្ចាស់កម្មសិទ្ធិ | + | + | | | | | |
| ប្រភេទម្ចាស់កម្មសិទ្ធិ | + | + | + | + | + | + | |
| ការទទួលបានដី | | | | | | + | |
| ទំហំក្បាលដី | + | + | + | + | + | + | |
| ការសុំសិទ្ធិជាម្ចាស់ | + | + | | | | + | |
| ការបែងចែក | + | + | + | + | + | + | |
| ភាពគ្មានដីធ្លី | + | + | + | + | + | + | + |
| ការជួល | + | + | + | + | | + | |
| ថ្លៃ | + | + | | | | | |

## ជំពូក ប្រាំមួយ

# លទ្ធផលសំខាន់ៗស្តីពីការកាន់កាប់ដី ប្រមូលបានពីអង្កេតនៅមូលដ្ឋាន [១]

### ៦.១. ចំនួន ទំហំដីកសិកម្មជាមធ្យម និងដីលំនៅដ្ឋាន

ចំនួនសរុបនៃក្បាលដីស្រែនៅកម្ពុជាក្នុងឆ្នាំ១៩៩៩ មាន ២.៨៧៧.០៧៦ប្លង់ យោងតាមអង្កេត SES-99 ដែលជាអង្កេតមានតំបន់គ្របដណ្តប់ធំជាងគេបំផុត[២] ។ ទំហំក្បាលដីជាមធ្យមគឺ ០,៨៩៩៦ហិកតា ។ ទិន្នន័យស្តីពីចំនួនក្បាលដីពុំមានប្រមូលនៅក្នុងអង្កេតណាមួយផ្សេងទៀតទេ រួមទាំងអង្កេត SES-97 ផង ដូច្នេះគេពិបាកនឹងនិយាយថាតើ ការពុះចែកដី ឬការចែករំលែកកាន់តែតូចទៅៗ បានកើតឡើងឬទេនាឆ្នាំថ្មីៗកន្លងទៅនេះ និងមានវិសាលភាពប៉ុណ្ណា ។ តាមពិត ទំហំដីជាមធ្យមគឺតូច បើពិនិត្យពីអត្រាពលកម្មធៀបនឹងដីនៅក្នុងប្រទេស (Godfrey *et al.* 2001) ។ គំលាតស្តង់ដា (standard deviation) ទំហំ១,១០ និងគំលាតនៃមេគុណ (coefficient of variation) ទំហំប្រហែល ៨១%[៣] បានឆ្លុះបញ្ចាំងថា ភាពខុសគ្នានៃទំហំក្បាលដីគឺមានកំរិតខ្ពស់ណាស់ ។

ទំហំដីកសិកម្មជាមធ្យមដែលបានគណនាសំរាប់ខេត្តផ្សេងៗមានបង្ហាញក្នុងតារាង៦.១ (ជួរទី ៦) ។ ទំហំក្បាលដីជាមធ្យមគឺធំជាង ១ហិកតានៅក្នុង១៣ខេត្ត (ក្នុងចំណោម ២៤ខេត្ត-ក្រុង) ដែលមានខេត្ត បន្ទាយមានជ័យ បាត់ដំបង ក្រចេះ មណ្ឌលគីរី ព្រះវិហារ ព្រៃវែង រតនគីរី សៀមរាប ក្រុងព្រះសីហនុ ស្ទឹងត្រែង តាកែវ ឧត្តរមានជ័យ និងប៉ៃលិន ។ នៅខេត្តផ្សេងទៀត ទំហំដីជាមធ្យមគឺតូចជាង ១ហិកតា ។ មានទំនាក់ទំនងបញ្ច្រាសមួយចំនួនរវាងដង់ស៊ីតេប្រជាជន (ប្រជាជនក្នុង ១ហិកតាដី) និងទំហំដីជាមធ្យម ប៉ុន្តែទំនាក់ទំនងនេះវាខ្សោយ ទេ ។ ករណីលើកលែងខ្លះៗគឺៈ មណ្ឌលគីរីជាខេត្តមានប្រជាជនតិចណាស់ និងមានផ្ទៃដីធំទូលាយ តែនៅទីនោះក្បាលដីនានាមិនមែនធំជាងគេទេ ប៉ុន្តែក្នុងខេត្តតាមដងទន្លេមេគង្គក្រោមមួយចំនួន គេបែរជាឃើញមាន ក្បាលដីធំៗទៅវិញ ។ គំលាតមេគុណ (coefficient of variation) ដូចក្នុងករណីផលបូកសរុប ក៏មានទំហំធំគួរសមដែរក្នុងខេត្តភាគច្រើន ។ ទាំងអស់នេះមានន័យថា ទំហំក្បាលដីមានភាពខុសគ្នាខ្លាំង ទាំងនៅកំរិតជាតិក៏ដូចជានៅកំរិត

---

[១] ជំពូកនេះគឺជាអត្ថបទលំអិតថែម ស្តីពីការងារមួយចំនួនដែល វិបសអ បានធ្វើពីមុននៅលើកំរងទិន្នន័យទាំងនេះ ។ សូមអានអត្ថបទ លោក ស៊ិក (២០០០) ។

[២] ក្បាលដីគឺជាដីមួយដុំ/ចំណែកដីជាឯកកម្មសិទ្ធិ ។

[៣] គំលាតនៃមេគុណ (coefficient of variation) ត្រូវបានគណនាឡើងដោយយកគំលាតស្តង់ដា (standard deviation) ទៅចែកនឹងមេធ្យាន (mean) រួចគុណប្រភាគនេះនឹង ១០០ ។ និន្នាការកណ្តាលត្រូវបានចាត់ទុកថាខ្សោយ ប្រសិនបើគំលាតមេគុណ coefficient of variation ធំជាង ១០-១៥% ។

ខេត្ត ។ មួយចំណែកទៀតគួរប្រុងប្រយ័ត្នក្នុងការបកស្រាយទិន្នន័យលំអិតតាមខេត្ត ពីព្រោះគំរូតាងនានាត្រូវបានជ្រើសរើសឡើងដើម្បីតំណាងឱ្យកំរិតជាតិតែប៉ុណ្ណោះ ។

ចំនួនគ្រួសារសរុបក្នុងអង្កេត SES-99 មាន ២.០៩៣.១៥២គ្រួសារ គឺនៅទីប្រជុំជនមាន ៣១០.៨០២គ្រួសារ និងនៅតាមជនបទមាន ១.៧៨២.៣៥០គ្រួសារ[៤] ។ ការបែងចែកតាមខេត្តនីមួយៗមានចុះក្នុងតារាង៦.២ ។ ដូចបានពិនិត្យឃើញក្នុងបរិបទនៃកថាខ័ណ្ឌមុនៗ ចំនួនក្បាលដីមានច្រើនជាងចំនួនគ្រួសារ ។ ដោយហេតុថា យ៉ាងហោចណាស់ ២៥% នៃកំលាំងពលកម្មធ្វើការងារមិនមែនកសិកម្ម ដូច្នេះ អត្រាគ្រួសារធៀបនឹងក្បាលដី មានលក្ខណៈល្អគួរសមដែរ ។ ទិដ្ឋភាពនេះនឹងលើកមកពិភាក្សាលំអិតនៅពេលក្រោយ ។

យោងតាមអង្កេត SES-99 ចំនួនក្បាលដីលំនៅដ្ឋានសរុបដែលរាប់បញ្ចូលទាំង "មានប័ណ្ណប្លង់ដី និងកាន់កាប់ដោយគ្មានប័ណ្ណ" និង "កម្មសិទ្ធិមិនទាន់ដាច់ស្រេច/កាន់កាប់ដោយសេរី" មាន ២.០២៩.១៦០ គឺប្រហែល ៩៧% នៃចំនួនគ្រួសារដែលបញ្ជាក់ក្នុងកថាខ័ណ្ឌខាងលើ ។ ដូច្នេះ ប្រហែល ៣% នៃគ្រួសារទាំងអស់ ហាក់ដូចជាស្នាក់នៅជាមួយអ្នកដទៃ ឬក៏គ្មានផ្ទះសំបែង ។ តួលេខលំអិតអំពីចំនួនដីកាន់កាប់សំរាប់លំនៅដ្ឋានតាមខេត្តមានចុះក្នុងតារាង៦.២ ។ ក្នុងគំរូតាងនេះ ក្នុងចំនួនក្បាលដីសរុបដែលកំណត់ដោយអ្នកឆ្លើយសំភាសន៍ថា មិនមែនដីកសិកម្ម គឺមានប្រហែល ៩០% ស្ថិតក្នុងប្រភេទ "មានប័ណ្ណប្លង់ដី និងកាន់កាប់ដោយគ្មានប័ណ្ណ" ហើយក្រៅពីនេះស្ថិតក្នុងប្រភេទ "កម្មសិទ្ធិមិនទាន់ដាច់ស្រេច/កាន់កាប់ដោយសេរី" ។ គេយល់ថា ការចាប់យកដីគឺស្ថិតនៅក្នុងប្រភេទទីពីរនេះ ។ ជាង ៩៨% នៃក្បាលដីទាំងអស់ដែលអ្នកឆ្លើយសំភាសន៍សំគាល់ថា "មានប័ណ្ណប្លង់ដី និងកាន់កាប់ដោយគ្មានប័ណ្ណ" គឺជាដីលំនៅដ្ឋាន ដូច្នេះ ដីសំរាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម មានតិចតួចណាស់នៅកម្ពុជា ។ ក្នុងប្រភេទ "កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬកាន់កាប់ដោយសេរី" ជាង ៩៥% ត្រូវបានប្រើប្រាស់ជា *ដីលំនៅដ្ឋាន* គឺបានន័យថា លំនៅដ្ឋានគ្របដណ្តប់លើដីមិនមែនកសិកម្មភាគច្រើន ។ ក្នុងចំណោមដីលំនៅដ្ឋានទាំងអស់ ប្រហែល ៩០% ស្ថិតក្នុងស្ថានភាព "មានម្ចាស់ និងមានការកាន់កាប់" ហើយក្រៅពីនេះស្ថិតក្នុងស្ថានភាព "កម្មសិទ្ធិមិនទាន់ដាច់ស្រេច/កាន់កាប់ដោយសេរី" ។ កំរមានគេរាយការណ៍ពីដីជួលណាស់: ចំនួនដីជួលសរុប មានតិចជាងមួយភាគរយនៃចំនួនក្បាលដីទាំងអស់ ។

ដីលំនៅដ្ឋាន "មានប័ណ្ណប្លង់ដី និងកាន់កាប់ដោយគ្មានប័ណ្ណ" មានទំហំជាមធ្យម ៨៨៨.១៣ម៉ែត្រការ៉េ យោងតាមគំរូតាងនៃអង្កេត SES-99 ។ នៅតាមជនបទ ក្បាលដីមានទំហំ ៩១៨.៥០ម៉ែត្រការ៉េ ឯនៅទីប្រជុំជនវាមានទំហំ ៦១៦.១៥ម៉ែត្រការ៉េ ។ ទិន្នន័យតាមខេត្តនីមួយៗមានចុះក្នុងតារាង៦.២ ។ បើពិនិត្យក្នុងបរិបទអន្តរជាតិវិញ ទំហំនេះហាក់ដូចជាធំគួរសម ។ ប៉ុន្តែគេគួរកត់សំគាល់ថា ផ្ទះជាប្រពៃណីរបស់ខ្មែរ ជាពិសេសនៅតាមតំបន់ជនបទ តែងសង់ឡើងនៅលើដីធំៗដែលគេប្រើប្រាស់សំរាប់ដាំដំណាំខ្លះៗផង ។ ក្នុងន័យនេះ ដីលំនៅដ្ឋានក៏ត្រូវបានប្រើប្រាស់សំរាប់គោលដៅផលិតកម្មដែរ ។

[៤] ជំរឿនប្រជាជនរាប់ឃើញទាំងអស់ ២.១៨៨.៦៦៣ក្បាលដី ។

**តារាង៦.១. ដីមធ្យមក្នុងមួយគ្រួសារ និងទំហំក្បាលដី តាមខេត្តនីមួយៗ (ជាហិកតា)**

| ខេត្ត | MRC-95-96 (ដី/គ្រួសារ) | SES-97 (ជនបទ) (ដី/គ្រួសារ) | SES-99 (ជនបទ) (ដី/គ្រួសារ) | SESC-99 (ដី/គ្រួសារ) | SES-99 (Parcels) | Baseline-00 (ដី/គ្រួសារ) | Follow-up-00 (ដី/គ្រួសារ) |
|---|---|---|---|---|---|---|---|
| ប.មានជ័យ | | 2.05 | 1.81 | 1.82 | 1.64 | | 1.63 |
| បាត់ដំបង | 1.76 | 1.15 | 1.81 | 1.64 | 1.33 | 1.32 | 1.38 |
| កំពង់ចាម | 0.51 | 0.63 | 1.51 | 1.47 | 0.79 | 0.91 | 0.96 |
| កំពង់ឆ្នាំង | 0.81 | 0.43 | 1.10 | 1.05 | 0.64 | 0.44 | 1.10 |
| កំពង់ស្ពឺ | | 0.91 | 0.66 | 0.64 | 0.56 | 0.71 | 0.80 |
| កំពង់ធំ | 0.97 | 1.31 | 1.41 | 1.46 | 0.54 | 0.91 | 1.38 |
| កំពត | | 0.77 | 1.21 | 1.22 | 0.75 | 0.83 | 0.35 |
| កណ្ដាល | 0.45 | 0.79 | 1.00 | 0.96 | 0.69 | 0.55 | 0.57 |
| កោះកុង | | 4.38 | 0.52 | 0.43 | 0.75 | | |
| ក្រចេះ | | 1.23 | 1.38 | 1.24 | 1.29 | 0.48 | |
| មណ្ឌលគិរី | | | - | 1.36 | 1.10 | | |
| ភ្នំពេញ | 0.35 | | 0.24 | 0.12 | 0.74 | | |
| ព្រះវិហារ | | | 1.40 | 1.47 | 1.07 | | |
| ព្រៃវែង | | 1.09 | 1.38 | 1.37 | 1.22 | 1.21 | 0.84 |
| ពោធិសាត់ | 1.63 | 1.81 | 1.27 | 1.31 | 0.76 | | |
| រតនគិរី | | 0.42 | 2.41 | 2.41 | 1.78 | | |
| សៀមរាប | 1.10 | 0.97 | 1.95 | 1.66 | 1.24 | 0.99 | 1.34 |
| ក្រុងព្រះសី. | | 0.40 | - | 0.79 | 1.31 | | |
| ស្ទឹងត្រែង | | 1.87 | 1.99 | 1.52 | 1.09 | 1.04 | |
| ស្វាយរៀង | | 1.28 | 1.42 | 1.38 | 0.60 | 0.57 | 1.00 |
| តាកែវ | | 0.83 | 1.35 | 1.34 | 1.22 | 0.92 | 0.48 |
| ឧត្ដរមានជ័យ | | | 1.08 | 1.61 | 1.36 | 0.86 | |
| ក្រុងកែប | | | - | 0.93 | 0.72 | | |
| ក្រុងប៉ៃលិន | | | - | 1.81 | 1.47 | | |
| សរុប | 0.75 | 1.07 | 1.33 | 1.24 | 0.90 | 0.98 | 0.96 |

*កំណត់សំគាល់: ទំហំកសិដ្ឋានមធ្យម គឺជាទំហំដីកសិកម្មគិតជាហិកតាក្នុងមួយគ្រួសារ ។ ដី/គ្រួសារមានន័យថា ដីដែលកាន់កាប់ដោយគ្រួសារ ។*

អង្កេតមួយចំនួនបានប្រមូលទិន្នន័យស្ដីពីការកាន់កាប់ដីកសិកម្ម ។ ការប្រៀបធៀបទំហំដីកសិកម្មជាមធ្យមក្នុងមួយគ្រួសារមានចុះក្នុងតារាង៦.៣[៥] ។ គេអាចធ្វើការប្រៀបធៀបជាទូទៅបានរវាងកំរងទិន្នន័យនានា ដោយសារតំបន់ជនបទពីតំបន់មួយទៅតំបន់មួយមិនសូវខុសគ្នាច្រើនទេ ។ ដីជាមធ្យមក្នុងមួយគ្រួសារមានប្រហែល ១ហិកតា ដោយមានគំលាតពី ២៥-៣០% ពីអង្កេតមួយទៅអង្កេតមួយ ។ អង្កេត PET-98 បង្ហាញថា ទំហំដីមធ្យមធំបំផុតក្នុងមួយគ្រួសារ គឺ ១.៣២ហិកតា ដែលគេមិនអាចពន្យល់បានទេ ពីព្រោះភាគច្រើនបំផុតនៃអ្នកឆ្លើយសំភាសន៍ក្នុង PET គឺជាជនភៀសសឹកក្នុងស្រុក ហើយគេដឹងថាអ្នកទាំងនេះពុំមានដីធំទេ ។ អង្កេត SES-97

[៥] ទំហំដីជាមធ្យមក្នុងមួយគ្រួសារ គឺជាការកាន់កាប់ដីកសិកម្មគិតជាមធ្យមនៃគ្រួសារទាំងអស់ ។ គ្រួសារដែលគ្មានដីក៏ត្រូវគិតបញ្ចូលក្នុងការគណនាដែរ ដោយគោលបំណងនៅទីនេះគឺដើម្បីកំណត់ទំហំដីជាមធ្យម និងបែងចែក ជាជាងការគណនាដទៃទៀតដូចជាការគ្រប់គ្រងសេដ្ឋកិច្ចកសិដ្ឋានជាដើម ។

និង SES-99 ប្រហែលមិនអាចប្រៀបធៀបគ្នាបានទាំងស្រុងទេ ។ អង្កេតទាំងពីរមានទំរង់ប្រមូលទិន្នន័យស្តីពីដីកសិកម្មខុសគ្នា ដូច្នេះទិន្នន័យអាចមានខ្លឹមសារខុសគ្នាខ្លះ ។ ដោយសារអង្កេត SES-99 មានបញ្ចូលខេត្តមួយចំនួនដែលមិនមាននៅក្នុងអង្កេត SES-97 និងដែលមានដីកាន់កាប់ទំហំធំជាងកន្លែងឯទៀតៗ ដូច្នេះតួលេខមធ្យមភាគអាចខុសគ្នា ។ ប៉ុន្តែរវាងអង្កេត SES-97 និង SES-99 តួលេខដីកាន់កាប់ជាមធ្យម វាខុសគ្នាដល់ទៅ ០,២៧ ហិកតា ។ ក្នុងនេះគេបានរាយការណ៍ថា ដីកសិកម្មក្នុងមួយគ្រួសារនៅជនបទនៅឆ្នាំ១៩៩៩ (១,៣៣ហិកតា) វាធំជាងកាលពីឆ្នាំ១៩៩៧ (១,០៧ហិកតា) ។ ម្យ៉ាងវិញទៀត SES-99 ទំនងជាច្បាស់លាស់ជាង SES-97 ពីព្រោះគេរៀបចំបញ្ជីសំនួរបានល្អជាងដើម្បីប្រមូលទិន្នន័យដីកសិកម្ម ដូច្នេះការប៉ាន់ស្មានក្នុង SES-99 អាចទុកចិត្តបានច្រើនជាង ។ ប៉ុន្តែមានមនុស្សមួយចំនួនបានអះអាងខ្លាំងណាស់ថា ការប្រមូលទិន្នន័យក្នុង SES-99 មានកំហុសឆ្គងខ្លះ ។ ក្នុងន័យនេះ កំរងទិន្នន័យនៃអង្កេតទាំងពីរគឺខ្វះសុក្រឹតភាពក្នុងកំរិតណាមួយ[៦] ។ អង្កេត Baseline-98 និង Follow-up-00 មានគំរូតាងអាចប្រៀបធៀបគ្នា ហើយក៏ផ្តល់លទ្ធផលដែលអាចប្រៀបធៀបគ្នាបានដែរ: ទំហំដីក្នុងមួយគ្រួសារនៅក្នុងគំរូតាងទាំងនេះគឺប្រហែល ០,៩៧ហិកតា ។ ចំណែកឯអង្កេត MRC-95-96 បានផ្តល់ទំហំដីជាមធ្យមតូចជាងគេបំផុត (០,៧៩ហិកតា) ដែលគេអាចយល់បាន ដោយហេតុថាអង្កេតនេះផ្តោតតែលើសហគមន៍នេសាទប៉ុណ្ណោះ ។ អង្កេតទាំងអស់បង្ហាញថា គ្រួសារមានស្ត្រីជាមេគ្រួ មានដីកាន់កាប់ជាមធ្យមតូចជាងគ្រួសារមានបុរសជាមេគ្រួ ។

ទំហំដីក្នុងមួយគ្រួសារតាមខេត្តនីមួយៗ និងតាមកំរងទិន្នន័យខុសៗគ្នា មានចុះក្នុងតារាង៦.១ (ជួរទី២, ៣, ៤, ៥, ៧ និង ៨) ។ ទិន្នន័យ SES-99 បង្ហាញថា ទាំងតួលេខសរុប ទាំងតួលេខនៅកំរិតខេត្ត ទំហំដីក្នុងមួយគ្រួសារគឺធំជាងក្បាលដី (ជាមធ្យមមាន ១,៣៧ក្បាលដីក្នុងមួយគ្រួសារ) ។ មានតែនៅកោះកុង ភ្នំពេញ និងក្រុងព្រះសីហនុទេ ដែលមានទំហំក្បាលដីជាមធ្យមធំជាងទំហំដីជាមធ្យមក្នុងមួយគ្រួសារ ។ ទីពីរ ទំហំដីជាមធ្យមក្នុងមួយគ្រួសារតាមខេត្តខុសៗគ្នា មានភាពស៊ីគ្នាគួរសមរវាងកំរងទិន្នន័យនានា គឺមានន័យថា ខេត្តទាំងឡាយណាដែលមានតួលេខដីធំក្នុងមួយគ្រួសារនៅក្នុងកំរងទិន្នន័យមួយ ក៏មានតួលេខដីធំនៅក្នុងកំរងទិន្នន័យមួយផ្សេងទៀតដែរ ។ តារាង៦.១ មានគោលដៅគ្រាន់តែបង្ហាញឱ្យឃើញប៉ុណ្ណោះ ហើយការទាញយកសេចក្តីសន្និដ្ឋានផ្សេងទៀត អាចធ្វើបានតិចតួចណាស់ ។

[៦] សំខាន់យើងត្រូវកត់សំគាល់ថា ក្នុងអង្កេត SES-97 ទិន្នន័យស្តីពីដីកសិកម្មមិនត្រូវបានប្រមូលជាក្បាលដីទេ ប៉ុន្តែដីសរុបក្នុងមួយម្ចាស់ ហើយត្រូវបានកត់ត្រាជាម៉ែត្រការ៉េ (ដែលអាចបណ្តាលឱ្យមានកំហុសឆ្គងខ្លះ) ។ ក្នុង SES-99 អ្នកអង្កេតត្រូវបានគេអនុញ្ញាតឱ្យកត់ទំហំដីជា រ៉ៃ កុង ម៉ែត្រ ឬក៏ហិកតា ដូច្នេះកំហុសផ្សេងៗក្នុងការកត់ត្រាគឺមានប្រូបាប៊ីលីតេខ្ពស់ ។ រង្វាស់នៅមូលដ្ឋានមួយចំនួនដូចជាកុង ពុំមានលក្ខណៈស្តង់ដាទេ ដូច្នេះកំហុសកាន់តែមានប្រូបាប៊ីលីតេខ្ពស់ថែមទៀត ។

**តារាង៦.២. ចំនួនគ្រួសារ ការកាន់កាប់ដីលំនៅដ្ឋាន និងទំហំដីជាមធ្យម តាមខេត្ត**

| ខេត្ត | គ្រួសារ | ការកាន់កាប់ដីលំនៅដ្ឋាន | ទំហំជាមធ្យម ( $ម^{២}$ ) |
|---|---|---|---|
| បន្ទាយមានជ័យ | 104874 | 99992 | 917.10 |
| បាត់ដំបង | 129900 | 113603 | 1014.12 |
| កំពង់ចាម | 284298 | 280943 | 822.65 |
| កំពង់ឆ្នាំង | 79831 | 78637 | 1402.77 |
| កំពង់ស្ពឺ | 92098 | 91413 | 801.67 |
| កំពង់ធំ | 105204 | 102708 | 1289.70 |
| កំពត | 103020 | 101705 | 1017.76 |
| កណ្តាល | 212806 | 207902 | 711.22 |
| កោះកុង | 20909 | 20737 | 368.32 |
| ក្រចេះ | 52278 | 51592 | 795.68 |
| មណ្ឌលគិរី | 2444 | 2084 | - |
| ភ្នំពេញ | 173815 | 169407 | 209.22 |
| ព្រះវិហារ | 21660 | 21660 | 1290.21 |
| ព្រៃវែង | 206622 | 206622 | 796.60 |
| ពោធិសាត់ | 61977 | 47200 | 1150.09 |
| រតនគិរី | 20611 | 20407 | 1444.23 |
| សៀមរាប | 117135 | 112665 | 1077.11 |
| ក្រុងព្រះសីហនុ | 23093 | 22517 | 927.14 |
| ស្ទឹងត្រែង | 12379 | 11832 | 1219.81 |
| ស្វាយរៀង | 92298 | 92298 | 1208.92 |
| តាកែវ | 151338 | 149303 | 824.79 |
| ឧត្តរមានជ័យ | 12496 | 12158 | 1069.04 |
| ក្រុងកែប | 8128 | 7935 | 1180.25 |
| ក្រុងប៉ៃលិន | 3940 | 3841 | 2113.21 |
| សរុប | 2093152 | 2029160 | 888.13 |

*ប្រភព: SES-99* ។

**តារាង ៦.៣. ទំហំដីកសិកម្មជាមធ្យមក្នុងមួយគ្រួសារ ( ជាហិកតា)**

| | ទំហំដីកសិកម្មជាមធ្យមក្នុងមួយគ្រួសារ | | |
|---|---|---|---|
| | គ្រួសារមានបុរសជាមេគ្រួ | គ្រួសារមានស្ត្រីជាមេគ្រួ | សរុប |
| PET-98 | 1.32 | 1.28 | 1.32 |
| SES-97 (ជនបទ) | 1.18 | 0.67 | 1.07 |
| SES-99 (ជនបទ) | 1.41 | 0.98 | 1.33 |
| SES-99 | 1.33 | 0.87 | 1.23 |
| Baseline-98 | 0.97 | 1.13 | 0.98 |
| Follow-up-00 | 0.96 | 0.83 | 0.96 |
| MRC-95–96 | 0.79 | 0.56 | 0.75 |

## ៦.២. ការទទួលបានដី

ការបែងចែកដីធ្លីនៅក្នុងឆ្នាំ១៩៨៩ បានផ្អែកទៅលើទំហំដីដែលមាននៅក្នុងភូមិ និងចំនួនសមាជិកទាំងអស់ក្នុងគ្រួសារនីមួយៗ ។

*ដើម្បីធានាឱ្យការបែងចែកដីធ្លីមានយុត្តិធម៌ រដ្ឋាភិបាលបញ្ជាឱ្យអាជ្ញាធរមូលដ្ឋានលៃទុកដីកសិកម្ម ពី ១ ទៅ ២ហិកតាក្នុងភូមិនីមួយៗ អាស្រ័យទៅតាមដង់ស៊ីតេប្រជាជន និងផ្ទៃដីដែលមាន ។ ដីនេះសំរាប់ទុកចែកទៅឱ្យជនមាតុភូមិនិវត្តន៍មកពីជំរំតាមទល់ដែន ទាហានរំសាយ និងជនមាតុភូមិនិវត្តន៍មកពីបរទេសនាពេលអនាគត ។ ដូច្នេះ វាសមហេតុផលហើយដែលធ្វើការសន្និដ្ឋានថា ប្រជាជនភាគច្រើនបានទទួលដីដោយស្របច្បាប់ តាមរយៈការបែងចែកដីឡើងវិញក្នុងឆ្នាំ១៩៨៩ និងត្រូវបានអាជ្ញាធរមូលដ្ឋានទទួលស្គាល់ជាផ្លូវការថាជាម្ចាស់ដី* (Sik 2000:11) ។

**តារាង ៦.៤. ការទទួលបានដីកសិកម្ម**

| វិធីទទួលបានដី | ភាគរយនៃគ្រួសារ |
|---|---|
| សាច់ញាតិ ឬមិត្តភ័ក្តិផ្តល់ឱ្យ | 43 |
| រដ្ឋអំណាចផ្តល់ឱ្យ | 28 |
| ទិញ | 11 |
| រានដីដោយខ្លួនឯង | 10 |
| ក្រុមសាមគ្គីផ្តល់ឱ្យ | 5 |
| ដីកសិកម្មទុកចោលមិនប្រើប្រាស់ | 3 |
| សរុប | 100 |

*ប្រភព:* PET-98 *ដូចមាននៅក្នុង* Sik (2000) ។

PET-98 ដែលយកចិត្តទុកដាក់ជាចំបងទៅលើប្រជាជនភៀសសឹកក្នុងស្រុក និងជាអង្កេតតែមួយគត់ដែលប្រមូលទិន្នន័យស្តីពីវិធីទទួលបានដី បានបង្ហាញថា ប្រជាជនក្នុងតំបន់អង្កេតគេទទួលបានដីតាមបែបបទជាច្រើន: ៤៣% នៃគ្រួសារទាំងអស់ទទួលបានដីដោយសារសាច់ញាតិផ្តល់ឱ្យ ២៨% នៃគ្រួសារទាំងអស់ទទួលបានដីពីអាជ្ញាធរផ្តល់ឱ្យ ហើយមានតែ ៥% ទេដែលទទួលបានដីពីក្រុមសាមគ្គី ។ មូលហេតុដែលលោកស៊ិក (ឆ្នាំ២000) បានលើកឡើងគឺថា ការជ្រើសរើសគំរូតាងក្នុងអង្កេតនេះ លំអៀងទៅរកគោលដៅដ៏ជាក់លាក់មួយចំនួន ។ មួយចំណែកទៀត អង្កេតនេះបានធ្វើឡើងនៅឆ្នាំ១៩៩៨ គឺយូរពេលណាស់ក្រោយការបែងចែកដីឆ្នាំ១៩៨៩ ហើយដោយសារលក្ខណៈប្រជាសាស្ត្រមានការប្រែប្រួលខ្លាំងក្នុងទសវត្សទី៩0 (ដូចជាមានគ្រួសារថ្មីៗច្រើនទៀតបានផុសឡើង) ដូច្នេះការបែងចែកដីដំបូងក្នុងទសវត្សរ៍ទី៨0 ប្រហែលមិនបានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ទេនៅក្នុងអង្កេតនេះ ។ ដោយសារការគ្របដណ្តប់លើតំបន់ដ៏ជាក់លាក់នៃ PET-98 ដូច្នេះគេមិនអាចប្រើប្រាស់វាជាទូទៅបានទេសំរាប់ធ្វើការវិភាគពីដីធ្លី ហើយការបកស្រាយទិន្នន័យនានាគួរធ្វើឡើងដោយប្រុងប្រយ័ត្ន ។

## ៦.៣. ការកាន់កាប់ដីធ្លី

នៅពេលសរសេររបាយការណ៍នេះ ច្បាប់ភូមិបាលអនុញ្ញាតឱ្យមាន *សិទ្ធិភោគ:* សំរាប់ដីកសិកម្ម និង*កម្មសិទ្ធិ* សំរាប់ដីលំនៅដ្ឋាន ។ សំរាប់ដីពីរប្រភេទនេះ មានការចេញប័ណ្ណបញ្ជាក់ឱ្យ នៅពេលមានសំណើ (ចេញបង្កាន់ដៃឱ្យនៅពេលដាក់ពាក្យសុំកម្មសិទ្ធិ) ។

តារាង៦.៥ បង្ហាញពីចម្លើយរបស់គ្រួសារអង្កេតចំពោះសំនួរថា តើពួកគេមានដីឬទេ មានប៉ុន្មាន ដោយមានលំអិតតាមប្រភេទដី និងទីតាំងដីនៅតំបន់ទីក្រុង ឬជនបទ ។ តារាងនេះដែលបានមកពី SES-97 បង្ហាញថាគ្រួសារជាច្រើនបានឆ្លើយថា *បានកាន់កាន់ដីដោយមានប័ណ្ណ* ទាំងចំពោះដីកសិកម្ម និងដីលំនៅដ្ឋាន, ទាំងនៅជនបទ និងនៅតំបន់ទីក្រុង ។ ស្ថានភាពនេះមិនប្រាកដនិយមសោះ ហើយវាផ្ទុយទាំងស្រុងទៅនឹងការរកឃើញក្នុងជំពូក៤ (តារាង ៤.១) ខាងលើ ។ នេះជាចំណុចគួរកត់សំគាល់មួយ ពីព្រោះ SES-97 អាចតំណាងឱ្យទូទាំងប្រទេសបាន ហើយការតាក់តែងអង្កេតក៏គ្មានលំអៀងទៅរកភូមិសាស្ត្រជាក់លាក់ណាមួយដូចក្នុង PET-98 ទេ ។

**តារាង៦.៥ ភាគរយនៃគ្រួសារដែលរាយការណ៍ថា បានកាន់កាប់ដីក្នុងស្ថានភាពមានកម្មសិទ្ធិ**

| ស្ថានភាពកម្មសិទ្ធិ | ដីលំនៅដ្ឋាន | | ដីកសិកម្ម | |
|---|---|---|---|---|
| | តំបន់ទីក្រុង | តំបន់ជនបទ | តំបន់ទីក្រុង | តំបន់ជនបទ |
| កម្មសិទ្ធិដោយមានប័ណ្ណប្លង់ដី | 77 | 82 | 79 | 87 |
| កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬ កាន់កាប់ដោយសេរី | 2 | 17 | 19 | 12 |
| ជួលពីគេ | 1 | 1 | 2 | 1 |
| សរុប | 100 | 100 | 100 | 100 |

*ប្រភព: SES-97 ដូចមាននៅក្នុង Sik (2000) ។*

លោកស៊ិក (២០០០) បានលើកឡើងថា សំនួរដែលមាននៅក្នុងបញ្ជីសំនួរ SES-97 មិនសូវមានលក្ខណៈជាក់លាក់ល្អទេ ដែលជាហេតុធ្វើឱ្យអ្នកឆ្លើយសំភាសន៍ជាច្រើននាក់មានការយល់ច្រឡំរវាងប័ណ្ណបញ្ជាក់សិទ្ធិ និងបង្កាន់ដៃទទួលពាក្យសុំ ឬក្រដាសស្នាមផ្សេងទៀតដែលពួកគេអាចមាន ដើម្បីបញ្ជាក់ពីការកាន់កាប់ដីរបស់ខ្លួន ។ សំនួរក្នុងបញ្ជីសំនួរ អនុញ្ញាតឱ្យមានជំរើសចំលើយតែបីប៉ុណ្ណោះ គឺកម្មសិទ្ធិដោយមានប័ណ្ណប្លង់ដី កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬដីកាន់កាប់ដោយសេរី និងជួលពីគេ ។ ដូច្នេះហើយគ្រួសារជាច្រើនដែលមានបង្កាន់ដៃ និងកំពុងរង់ចាំទទួលប័ណ្ណ មិនអាចរាយការណ៍ពីស្ថានភាពជាក់ស្តែងបានទេ ។ ប្រាកដណាស់ ពួកគេមិនជឿទេថាកម្មសិទ្ធិរបស់ខ្លួនមិនទាន់ដាច់ស្រេច ដូច្នេះហើយក៏អាចជ្រើសរើសយកចម្លើយទីមួយតែម្តង[៧] ។ លើសពីនេះទៀត ប្រជាជនជាច្រើនបានយកបង្កាន់ដៃធ្វើជាលិខិតកម្មសិទ្ធិដោយស្មោះត្រង់ ដូចបានរកឃើញក្នុងការសិក្សាថ្មីៗលើ "ការវាយតំលៃសង្គមស្តីពីបញ្ហាដីធ្លីនៅកម្ពុជា" (So *et al.* 2001) ។

សំនួរដូចគ្នានេះ ត្រូវបានសួរនៅក្នុង SES-99 ផងដែរ ប៉ុន្តែទំរង់សំនួរវាដូចគ្នាតែចំពោះដីលំនៅដ្ឋានទេ ។ ចម្លើយបង្ហាញឱ្យឃើញថា គ្រួសារខ្លះកាន់កាប់ដីពីរ ឬបីកន្លែងដែលមានជា "កម្មសិទ្ធិដោយមានប័ណ្ណប្លង់ដី" និង "កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬកាន់កាប់ដោយសេរី" ។ ជាលទ្ធផល តួលេខសរុបចូលគ្នា មិនបានគ្រប់ ១០០% ដូចក្នុងតារាង៦.៥ ទេ ។ ចំពោះដីកសិកម្ម សំនួរផ្តោតលើការប្រើប្រាស់ដី ប៉ុន្តែតួលេខអាចផ្ទុំគ្នាទៅតាមទំរង់ដូចក្នុងតារាង៦.៥ ដែរ ។ ក្នុងករណីនីមួយៗ ទិន្នន័យក្នុង SES-99 *មិនជាប់ទាក់ទងនឹង* "របាយគ្រួសារទេ" ។ ក្នុងករណីដីលំនៅដ្ឋាន គឺមានការចែកតាម "របាយនៃការកាន់កាប់ដី" (ចែកទៅតាម "កម្មសិទ្ធិមានប័ណ្ណប្លង់ដី" "កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬកាន់កាប់ដោយសេរី" និង "ជួលពីគេ") ។ សំរាប់ដីកសិកម្មវិញ របាយគឺធ្វើទៅតាមដីមួយប្លង់ៗ ។

[៧] SES-96 ក៏បានសួរសំនួរនេះដែរ ។ អង្កេតរកឃើញថា គ្រួសារ ៩៦% មានដីលំនៅដ្ឋាន, ០,៤% ជួលដី, ៣,២% កាន់កាប់ដីដោយសេរី និង ០,៤% មានកម្មសិទ្ធិមិនទាន់ដាច់ស្រេច ។ គ្រួសារប្រហែល ៩៥% មានឯកសារចេញដោយមន្ទីរសុរិយោដី ។ ចំពោះដីកសិកម្ម ៤៦% មានម្ចាស់ ឬមានគេកាន់កាប់ ក្នុងនេះ ៩៨% មានឯកសារចេញដោយមន្ទីរសុរិយោដី ។ តួលេខទាំងនេះជាច្រើន គឺហាក់ដូចជាខុស ។

តារាងពីរខាងក្រោម ត្រូវបានបង្កើតឡើងតាមលក្ខណៈខាងលើ ហើយចំណងជើងក្នុងតារាងក៏ត្រូវបានកំណត់តាមនេះដែរ ។

ទិន្នន័យក្នុងតារាង៦.៦ក និង ៦.៦ខ បង្ហាញថា ក្នុងឆ្នាំ១៩៩៩ មានភាគរយប្រជាជនកាន់តែច្រើនជាងក្នុងអង្កេត SES-97 កាលពីឆ្នាំ១៩៩៧ ទៅទៀតដែលរាយការណ៍ថា ខ្លួនមានប័ណ្ណបញ្ជាក់កម្មសិទ្ធិដី ។ រឿងនេះរឹតតែធ្វើឱ្យមានការជឿជាក់ថា ការកាន់កាប់ដីធម្មតាដោយមានក្រដាសស្នាមខ្លះសំរាប់បញ្ជាក់ការអះអាងកម្មសិទ្ធិ ត្រូវបានគេរាយការណ៍ថាជា "កម្មសិទ្ធិមានប័ណ្ណប្លង់ដី" ។ នៅក្នុងករណីដីកសិកម្ម មានជួរមួយទៀតក្នុងបញ្ជីសំនួរ SES-99 សំរាប់កត់ត្រាដីជួលឱ្យគេ ។ តារាងខាងលើបង្ហាញថា ករណីនេះមានច្រើនជាង ១% បន្តិចប៉ុណ្ណោះ ។ កំណត់សំគាល់ដ៏សំខាន់មួយលើទិន្នន័យគឺ ប្រហែល ៧% នៃដីកសិកម្មទាំងអស់ត្រូវបានកាន់កាប់ដោយប្រជាជនរស់នៅក្នុងតំបន់ទីក្រុង ។ រឿងនេះអាចមានន័យថា ប្រជាជនមួយចំនួនដែលកាន់កាប់ដីកសិកម្ម គេបានផ្លាស់ទីលំនៅមកតំបន់ទីក្រុងនៅក្នុងពេលធ្វើអង្កេត និង/ឬ ប្រជាជនទីក្រុងបានទិញ ឬទទួលបានដីនៅជនបទ ។

**តារាង៦.៦.ក ភាគរយនៃការកាន់កាប់ដីលំនៅដ្ឋាន គិតទៅតាមស្ថានភាពកម្មសិទ្ធិ**

| ស្ថានភាពកម្មសិទ្ធិ | ដីលំនៅដ្ឋាន | | |
|---|---|---|---|
| | តំបន់ទីក្រុង | តំបន់ជនបទ | សរុប |
| កម្មសិទ្ធិដោយមានប្លង់ | 77.44 | 91.13 | 89.07 |
| កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬកាន់កាប់ដោយសេរី | 19.72 | 8.42 | 10.12 |
| ជួលពីគេ | 2.84 | 0.45 | 0.81 |
| សរុប | 100 | 100 | 100 |

*ប្រភព:* SES-99 ។

**តារាង៦.៦.ខ ភាគរយនៃប្លង់ដីកសិកម្ម គិតតាមស្ថានភាពកម្មសិទ្ធិ**

| ស្ថានភាពកម្មសិទ្ធិ | ដីលំនៅដ្ឋាន | | |
|---|---|---|---|
| | តំបន់ទីក្រុង | តំបន់ជនបទ | សរុប |
| កម្មសិទ្ធិមានប័ណ្ណប្លង់ដី | 84.6 | 89.8 | 89.5 |
| កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬកាន់កាប់ដោយសេរី | 8.5 | 5.5 | 5.7 |
| ជួលឱ្យគេ | 2.6 | 1.2 | 1.3 |
| ជួលពីគេ | 3.5 | 3.1 | 3.1 |
| មិនរាយការណ៍ | 0.8 | 0.4 | 0.4 |
| សរុប | 100 | 100 | 100 |

*ប្រភព:* SES-99 ។

អង្កេត PET-98 ហាក់ដូចជាបង្ហាញនូវរូបភាពប្រាកដនិយមជាង ស្ដីពីស្ថានភាពកម្មសិទ្ធិដីធ្លី ដោយហេតុថាចំនួនអ្នកមានប័ណ្ណ ឬលិខិតស្នាមត្រឹមត្រូវ វាប្រហាក់ប្រហែលនឹងការពិតដូចបានរៀបរាប់ក្នុងជំពូក៤ ។ តារាង៦.៧ បង្ហាញថា ប្រហែលតែ ២%នៃអ្នកឆ្លើយសំភាសន៍ប៉ុណ្ណោះដែលមានប័ណ្ណប្លង់ដីជាផ្លូវការសំរាប់ដីលំនៅដ្ឋាន ហើយប្រហែល ១% មានប័ណ្ណប្លង់ដីកសិកម្ម ។ ជិតបីភាគបួននៃអ្នកឆ្លើយសំភាសន៍ គ្មានក្រដាសស្នាមអ្វីសំរាប់បញ្ជាក់ការអះអាងកម្មសិទ្ធិដីរបស់ខ្លួនទេ ។

**តារាង៦.៧ ភាគរយនៃរបាយគ្រួសារ គិតតាមប្រភេទនៃលិខិតស្នាមដែលគាត់មាន**

| ស្ថានភាពកម្មសិទ្ធិ | ដីលំនៅដ្ឋាន | | | ដីកសិកម្ម | | |
|---|---|---|---|---|---|---|
| | ស្ត្រីមេគ្រួសារ | បុរសមេគ្រួសារ | សរុប | ស្ត្រីមេគ្រួសារ | បុរសមេគ្រួសារ | សរុប |
| គ្មានក្រដាសស្នាម | 74 | 60 | 73 | 75 | 62 | 74 |
| មានបង្កាន់ដៃ | 14 | 18 | 15 | 13 | 16 | 13 |
| បានដាក់ពាក្យសុំកម្មសិទ្ធិ | 2 | 4 | 2 | 2 | 6 | 2 |
| មានកំណត់ហេតុអង្កេតដី | 1 | 3 | 1 | 1 | 1 | 1 |
| មានប័ណ្ណប្លង់ដី | 2 | 0 | 2 | 1 | 0 | 1 |
| គ្មានដី | 7 | 15 | 7 | 8 | 15 | 9 |
| សរុប | 100 | 100 | 100 | 100 | 100 | 100 |

*ប្រភព: PET-98 ដូចមាននៅក្នុងឯកសារ Sik (2000) ។*

តារាងនេះក៏បង្ហាញឱ្យឃើញនូវលក្ខណៈពិសេសចំពោះតួនាទីបុរស-ស្ត្រី ។ ភាគរយគ្រួសារមានបុរសជាមេគ្រួដែលមានប័ណ្ណប្លង់ដី មានកំរិតខ្ពស់ជាងគ្រួសារមានស្ត្រីជាមេគ្រួ ប៉ុន្តែភាគរយគ្រួសារមានស្ត្រីជាមេគ្រួដែលមានបង្កាន់ដៃមានកំរិតខ្ពស់ជាងវិញ ។ ម្យ៉ាងវិញទៀត ភាគរយគ្រួសារមានបុរសជាមេគ្រួដែលគ្មានក្រដាសស្នាមអ្វីសំរាប់បញ្ជាក់ពីកម្មសិទ្ធិដីរបស់ខ្លួន មានកំរិតខ្ពស់ជាងគ្រួសារមានស្ត្រីជាមេគ្រួ ។ ក្នុងនេះប្រហែលជាការជ្រើសគំរូតាងដែលមានមុខសញ្ញាជាក់លាក់ បានធ្វើឱ្យលំអៀងដល់លទ្ធផល ។ ទោះយ៉ាងនេះក៏ដោយ ក៏ PET-98 បានបង្ហាញលទ្ធផល ប្រហាក់ប្រហែលនឹងការពិតនៅជនបទ ជាជាងអង្កេតសង្គមកិច្ច-សេដ្ឋកិច្ច (SES) នានា ក្នុងបញ្ហានេះ ។

## ៦.៤. សិទ្ធិកាន់កាប់ដីធ្លី

បញ្ហាកម្មសិទ្ធិដីធ្លី ត្រូវបានពិនិត្យខុសៗគ្នាទៅតាមកំរងទិន្នន័យផ្សេងៗ ដោយអនុលោមទៅតាមគោលដៅចំបងនៅក្នុងការធ្វើអង្កេតនីមួយៗ ។ អង្កេត MRC-95-96 ដែលផ្តោតលើសហគមន៍នេសាទ បានសិក្សាពីដីធ្លីតែនៅក្នុងបរិបទនៃលទ្ធភាពរកចិញ្ចឹមជីវិតដោយសារធនធានដី និងទឹក ប៉ុណ្ណោះ ។ ដូច្នេះហើយ គេក៏បានធ្វើចំណាត់ថ្នាក់កម្មសិទ្ធិដីធ្លីទៅតាមនេះ ( តារាង៦.៨) ។

**តារាង៦.៨ ភាគរយនៃគ្រួសារដែលរាយការណ៍ថាមានកាន់កាប់ដី**

| ដី | គ្រួសារបុរសមេគ្រួ | គ្រួសារស្ត្រីមេគ្រួ | សរុប |
|---|---|---|---|
| ដីលំនៅដ្ឋាន | 99.1 | 99.2 | 99.1 |
| ដីកសិកម្ម | 76.9 | 70.2 | 75.6 |
| ដីចំការ | 15.4 | 13.2 | 15.0 |
| ដីផ្សេងទៀត | 0.5 | 0.3 | 0.5 |
| ស្រះត្រីនៅក្នុងដីលំនៅដ្ឋាន | 3.6 | 2.6 | 3.4 |
| ស្រះត្រីនៅក្រៅដីលំនៅដ្ឋាន | 0.5 | 0.1 | 0.4 |

*ប្រភព : អង្កេតMRC 95-96 ដូចមានចុះក្នុងឯកសារ Sik (2000) ។*

ទិន្នន័យទាំងនេះបង្ហាញថា ភាពគ្មានដីលំនៅដ្ឋាន ហាក់ដូចជាមិនចោទបញ្ហាទេ នៅក្នុងតំបន់គំរូតាង ។ គ្រួសារប្រហែលបីភាគបួនមានដីកសិកម្ម ក្នុងនេះគ្រួសារមានបុរសជាមេគ្រួ មានកំរិតភាគរយខ្ពស់ជាង គ្រួសារមានស្ត្រីជាមេគ្រួ ។ ជាការមួយគួរឱ្យភ្ញាក់ផ្អើលដែរ ដែលគ្រួសារតិចណាស់មានស្រះត្រី ក្នុងនេះដូចមុនដែរ គ្រួសារមានបុរសជាមេគ្រួ មានកំរិតភាគរយខ្ពស់ជាង គ្រួសារមានស្ត្រីជាមេគ្រួ ។ ការពិត មានគ្រួសារច្រើនជាងដែលមានដី

ចំការ (ប្រៀបធៀបនឹងគ្រួសារមានស្រះត្រី) ទោះបីជាគ្រួសារក្នុងអង្កេតភាគច្រើន រស់នៅក្នុងសហគមន៍នៅជិតបឹងទន្លេក៏ដោយ ។ ស្ថិតិនេះធ្វើឱ្យគេយល់ឃើញថា សហគមន៍នៅក្បែរទឹក តែងពឹងផ្អែកខ្លាំងណាស់លើការនេសាទក្នុងដែនទឹកសាធារណៈ ប៉ុន្តែការពឹងផ្អែកតែលើការនេសាទមួយមុខ ពុំមានកំរិតខ្ពស់ទេ ។

តារាង៦.៩ក និង ៦.៩ខ បញ្ជាក់ម្តងទៀតថា ភាពគ្មានដីលំនៅដ្ឋានមានកំរិតតិចតួចទេ ហើយទិន្នន័យបានបង្ហាញដែរថា ភាគរយអ្នកគ្មានដីលំនៅដ្ឋានក្នុងចំណោម*ប្រជាជនទូទៅ* មានកំរិតខ្ពស់ជាង ភាគរយក្នុង*សហគមន៍នេសាទ* (តារាង៦.៨) ។ កំរងទិន្នន័យទាំងពីរ (SES-97 និង SES-99) បង្ហាញថា អ្នកគ្មានដីលំនៅដ្ឋានមានចំនួនពី ២% ទៅ ៤% ដោយកំរិតភាគរយនៅតំបន់ទីក្រុងវាខ្ពស់ជាងនៅតំបន់ជនបទ ហើយកំរិតភាគរយក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួ វាខ្ពស់ជាងគ្រួសារមានបុរសជាមេគ្រួ[៨] ។ ដោយសារ SES-97 និង SES-99 តំណាងឱ្យប្រជាជនទាំងមូលបានល្អ គេអាចជឿទុកចិត្តលើតួលេខទាំងនេះបាន ។

**តារាង ៦.៩ក ភាគរយនៃគ្រួសារដែលរាយការណ៍ថាមានដីលំនៅដ្ឋាន និងដីកសិកម្ម**

| ដី | តំបន់ទីក្រុង | | | តំបន់ជនបទ | | |
|---|---|---|---|---|---|---|
| | គ្រួសារបុរសមេគ្រួ | គ្រួសារស្ត្រីមេគ្រួ | សរុប | គ្រួសារបុរសមេគ្រួ | គ្រួសារស្ត្រីមេគ្រួ | សរុប |
| ដីលំនៅដ្ឋាន | 95.7 | 94.9 | 95.4 | 97.4 | 97.3 | 97.4 |
| ដីកសិកម្ម | 27.6 | 26.5 | 27.3 | 87.0 | 83.7 | 86.2 |

*ប្រភព: SES-97 ដូចមាននៅក្នុងឯកសារ Sik (2000) ។*

**តារាង ៦.៩ខ ភាគរយនៃគ្រួសារដែលរាយការណ៍ថាមានដីលំនៅដ្ឋាន និងដីកសិកម្ម**

| ដី | តំបន់ទីក្រុង | | | តំបន់ជនបទ | | | ទូទៅ | | |
|---|---|---|---|---|---|---|---|---|---|
| | បុរសមេគ្រួ | ស្ត្រីមេគ្រួ | សរុប | បុរសមេគ្រួ | ស្ត្រីមេគ្រួ | សរុប | បុរសមេគ្រួ | ស្ត្រីមេគ្រួ | សរុប |
| ដីលំនៅដ្ឋាន | 96.0 | 96.3 | 96.1 | 97.2 | 97.6 | 97.3 | 97.0 | 97.4 | 97.1 |
| ដីកសិដ្ឋាន | 42.1 | 29.5 | 39.3 | 85.4 | 79.4 | 84.2 | 79.1 | 71.2 | 77.6 |

*ប្រភព: SES-99 ។*

ចំពោះការកាន់កាប់ដីកសិកម្ម មានការខុសគ្នាគួរឱ្យកត់សំគាល់មួយចំនួន រវាងកំរងទិន្នន័យទាំងពីរ ។ ចំពោះគ្រួសារនៅក្នុងតំបន់ជនបទ ការកាន់កាប់ដីកសិកម្មសរុបមិនខុសគ្នាច្រើនទេ គឺ ៨៦,២% ក្នុង SES-97 និង ៨៤,២% ក្នុង SES-99, ប៉ុន្តែចំពោះតំបន់ទីក្រុងវិញ SES-97 បង្ហាញថា មានគ្រួសារ ២៧,៣% មានដីកសិកម្ម រីឯ SES-99 បង្ហាញថាមានគ្រួសារដល់ទៅ ៣៩,៣% មានដីកសិកម្ម ។ តើការថយចុះដីកាន់កាប់ក្នុងចំណោមគ្រួសារនៅជនបទ និងកំណើនដីកាន់កាប់របស់អ្នកនៅទីក្រុង វាមានន័យថាកសិករត្រូវបាត់បង់ដីទៅលើអ្នកទីក្រុងឬ? ឬក៏ការប្រែប្រួលនេះបណ្តាលមកពីកត្តាប្រជាសាស្ត្រ និងចំណាកស្រុក ឬការខុសគ្នានេះបណ្តាលមកពីសំនួរដែលគេសួរ និងការយល់សំនួររបស់អ្នកឆ្លើយ? ឬក៏វាបណ្តាលមកពីមានលំអៀងទិន្នន័យម្តងទៀត? សំនួរទាំងនេះត្រូវមានការស្រាវជ្រាវបន្ថែមទៀត ។ នៅក្នុងបរិបទតួនាទីបុរស-ស្ត្រីវិញ បញ្ហានៅតែមានលំនាំដូចធម្មតាគឺ គ្រួសារមានបុរសជាមេគ្រួដែលមានដីកសិកម្ម គឺមានកំរិតភាគរយខ្ពស់ជាងគ្រួសារមានស្ត្រីជាមេគ្រួ ។

---

[៨] ក្នុងទិដ្ឋភាពនេះ, SES-96 ក៏មានទិន្នន័យប្រហាក់ប្រហែលនឹងតួលេខទាំងនេះដែរ ។

អង្កេត Baseline-98, Follow-up-00 និង PET-98 ក៏បានប្រមូលទិន្នន័យពីការកាន់កាប់ដីកសិកម្មផងដែរ ។ ទិន្នន័យក្នុងតារាង៦.១០ ជាប់ទាក់ទិននឹងដីកសិកម្មតែមួយមុខប៉ុណ្ណោះ ដោយមានការបែងចែកទៅតាមប្រភេទនៃការប្រើប្រាស់ដី ។ ក្នុងអង្កេតទាំងបី លទ្ធភាពទទួលបាន "ដីប្រភេទណាក៏ដោយ" ក្នុងចំណោមគ្រួសារទាំងនេះ ឃើញថាមានកំរិតខ្ពស់ជាង បើធៀបនឹងតារាង៦.៨, ៦.៩ក និង ៦.៩ខ ។ តើការជ្រើសយកគំរូតាងមានមុខសញ្ញានៅក្នុងអង្កេតទាំងនេះ វាជាមូលហេតុនៃការខុសគ្នាឬ? លទ្ធភាពខ្ពស់ក្នុងការទទួលបានដីក្នុងចំណោមគ្រួសារឆ្លើយអង្កេត PET ពុំមានហេតុផលច្បាស់លាស់ទេ ។ តាមន័យស្ថិតិ គេអាចប្រៀបធៀប Baseline-98 និង Follow-up-00 បាន ហើយការប្រៀបធៀបបង្ហាញឱ្យឃើញថា គ្រួសារអង្កេតមានលទ្ធភាពទទួលបានដីស្រែវស្សាច្រើនជាងកាលពី២ឆ្នាំមុន ។ ក្នុងពេលជាមួយគ្នានេះ លទ្ធភាពទទួលបានដីចំការធ្លាក់ចុះ តែលទ្ធភាពទទួលបានដីច្បារដំណាំតាមផ្ទះបានកើនឡើង ។ តើការប្រែប្រួលក្នុងទំហំបែបនេះអាចទៅរួចឬទេក្នុងរយៈពេលដ៏ខ្លី ។ មានការខុសគ្នាខ្លាំងក្នុងផ្នែកតួនាទីបុរស-ស្ត្រី ដែលមិនអាចពន្យល់បាន ។ អាចមានលំអៀងខ្លះក្នុងទិន្នន័យ ពីព្រោះគេបានលុបចោលអស់ប្រហែល ៥% នៅពេលគេសំអាតទិន្នន័យក្នុង Follow-up-00 ។ មួយចំណែកទៀតក៏អាចមានលំអៀងក្នុងទិន្នន័យផ្ទាល់តែម្តង ពីព្រោះ Baseline-98 និង Follow-up-00 ផ្តោតលើអាហារូបត្ថម្ភ មិនមែនកម្មសិទ្ធិដីធ្លីទេ ដូច្នេះភាពត្រឹមត្រូវនៃអញ្ញាតមួយចំនួនក្រៅពីបញ្ហាអាហារូបត្ថម្ភចេញ ប្រហែលមិនបានល្អទេ ។

**តារាង ៦.១០ ភាគរយនៃគ្រួសារកាន់កាប់ដីស្រែ និងចំការ**

| ប្រភេទដី | Baseline-98 | | | Follow-up-00 | | | PET-98 | | |
|---|---|---|---|---|---|---|---|---|---|
| | បុរសមេគ្រួ | ស្ត្រីមេគ្រួ | សរុប | បុរសមេគ្រួ | ស្ត្រីមេគ្រួ | សរុប | បុរសមេគ្រួ | ស្ត្រីមេគ្រួ | សរុប |
| ដី | - | - | - | 92.5 | 96.0 | 92.6 | 93 | 83 | 92 |
| ដីស្រែវស្សា | 82 | 86 | 82 | 89.9 | 96.0 | 90.0 | 74 | 62 | 73 |
| ដីស្រែប្រាំង | 8 | 8 | 8 | 6.9 | 2.0 | 6.7 | 2 | 4 | 2 |
| ដីចំការ | 24 | 19 | 24 | 16.2 | 6 | 15.7 | 42 | 31 | 41 |
| ដីច្បារតាមផ្ទះ | 32 | 32 | 32 | 47.9 | 36 | 47.4 | 61 | 62 | 61 |

## ៦.៥. ភាពគ្មានដីធ្លី

ក្នុងសេដ្ឋកិច្ចមួយដូចនៅប្រទេសកម្ពុជា សំនួរថា តើអ្វីទៅជាភាពគ្មានដី ហើយអ្នកណាជាអ្នកគ្មានដី វាអាចមានន័យស្រពិចស្រពិល ។ ក្នុងប្រទេសផ្សេងទៀត ដូចជានៅឥណ្ឌូណេស៊ី ហ្វីលីពីន និងបង់ក្លាដេស ជាដើម គឺមានចំនាត់ថ្នាក់កសិករមួយប្រភេទដែលគេដាក់ឈ្មោះថាកសិករគ្មានដី ដែលជាអ្នកលក់កំលាំងពលកម្មជាប្រចាំឱ្យអ្នកមានដីដើម្បីរកកំរៃ ។ នៅក្នុងប្រទេសកម្ពុជាវិញ ចំណាត់ថ្នាក់បែបនេះមានតិចតួចណាស់ គឺប្រហែល ១% នៃកំលាំងពលកម្មសរុបក្នុងវិស័យកសិកម្មប៉ុណ្ណោះ បើយោងតាមជំរឿនឆ្នាំ១៩៩៨ (RGC 1999) ។ ឯកសារនានាបានបង្ហាញថា មានប្រជាជនដែលលក់ដីដើម្បីយកទុនទៅប្រកបរបរប្រសើរជាងនៅក្រៅកសិកម្ម និងមានអ្នកផ្សេងទៀតដែលគ្មានដីតែមិនប្រកបរបរដាំដុះទេ ដូចជាអ្នកនេសាទ អ្នកកាប់ឈើ ឬអ្នកជួញដូរតូចតាច ហើយពួកនេះក៏ចង់បានដីដែរ ដើម្បីឱ្យជីវភាពបានកាន់តែគ្រាន់បើឡើង ។ តើអ្នកទាំងនេះគួរចាត់ទុកជាអ្នកគ្មានដីឬ? នៅមានប្រជាជនមួយចំនួនទៀតដែលរស់នៅតំបន់ទីក្រុង តែមានដីកសិកម្មនៅជនបទ ។ បើសិនពួកគេលក់ដី តើគួរហៅពួកគេថាជាអ្នកគ្មានដីដែរឬទេ? ក្នុងន័យចង្អៀតបំផុត គឺទាល់តែអ្នកដែលបាត់បង់ដីដោយបង្ខំចិត្ត ដែលគ្មានជំនាញអ្វីផ្សេងក្រៅពីរបរកសិកម្ម ហើយមានជីវភាពមិនទៀងទាត់ដោយសារការបាត់បង់ដី ទើបអាចចាត់ទុកថាជាអ្នកគ្មានដី ។ គ្មានអង្កេតធំដុំណាមួយក្រៅពី LADIT-00 ទេ ដែលបានប្រមូលទិន្នន័យបានត្រឹមត្រូវគួរសមតាមនិយមន័យនេះ ។ ប៉ុន្តែ

LADIT-00 ក៏មិនបានដោះស្រាយបញ្ហាទាំងអស់ដែលមានបញ្ជាក់ក្នុងកថាខ័ណ្ឌនេះដែរ ។ ទិន្នន័យអង្កេតមានវែកញែកពិភាក្សាដូចខាងក្រោម ។

**តារាង៦.១១ ភាគរយគ្រួសារគ្មានដីលំនៅដ្ឋាន**

| | ភាគរយគ្រួសារគ្មានដីលំនៅដ្ឋាន | | |
|---|---|---|---|
| | គ្រួសារមានបុរសជាមេគ្រួ | គ្រួសារមានស្ត្រីជាមេគ្រួ | សរុប |
| PET-98 | 10.8 | 21.6 | 11.6 |
| SES-96 | - | - | 4.6 |
| SES-97 (ទីក្រុង) | 4.3 | 5.1 | 4.6 |
| SES-97 (ជនបទ) | 2.6 | 2.7 | 2.6 |
| SES-99 (ទីក្រុង) | 4.1 | 3.7 | 4.0 |
| SES-99 (ជនបទ) | 2.8 | 2.5 | 2.8 |
| SES-99 (សរុប) | 3.0 | 2.7 | 3.0 |
| MRC-95–96 | 0.9 | 0.8 | 0.9 |

**តារាង៦.១២ ភាពគ្មានដីកសិកម្ម តាមបណ្តាខេត្ត (ភាពគ្មានដីគឺជាភាគយគ្រួសារគ្មានដីកសិកម្ម)**

| ខេត្ត-ក្រុង | MRC-95-96 | SES-97 (ជនបទ) | SES-99 (ជនបទ) | SES-99 (សរុប) | Baseline-98 | Follow-up – 00 | LADIT-00 |
|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | | 13 | 15 .8 | 19 .0 | | 19 .2 | 12 .7 |
| បាត់ដំបង | 25 | 27 | 28 .8 | 36 .1 | 29 | 33 .3 | 19 .5 |
| កំពង់ចាម | 20 | 19 | 14 .2 | 15 .9 | 4 | 13 .5 | 10 .7 |
| កំពង់ឆ្នាំង | 25 | 16 | 14 .3 | 18 .0 | 17 | 0 .0 | 12 .0 |
| កំពង់ស្ពឺ | | 6 | 3 .5 | 4 .8 | 7 | 0 .0 | 10 .4 |
| កំពង់ធំ | 16 | 9 | 8 .8 | 10 .0 | 1 | 2 .6 | 11 .0 |
| កំពត | | 2 | 5 .3 | 8 .0 | | 0 .0 | 5 .6 |
| កណ្តាល | 35 | 17 | 15 .9 | 17 .8 | 13 | 9 .5 | 15 .6 |
| កោះកុង | | 50 | 37 .9 | 48 .6 | | | 24 .5 |
| ក្រចេះ | | 23 | 39 .3 | 37 .6 | 37 | | 12 .1 |
| មណ្ឌលគិរី | | | | 15 .5 | | | - |
| ភ្នំពេញ | | | 74 .3 | 88 .2 | | | 3 .1 |
| ព្រះវិហារ | | | 2 .4 | 2 .4 | | | - |
| ព្រៃវែង | | 7 | 8 .9 | 9 .3 | 8 | 3 .6 | 5 .7 |
| ពោធិសាត់ | 7 | 13 | 26 .2 | 26 .2 | | | 13 .0 |
| រតនគិរី | | 3 | 7 .9 | 10 .7 | | | - |
| សៀមរាប | 12 | 8 | 8 .3 | 19 .5 | 4 | 0 .0 | 18 .8 |
| ក្រុងព្រះសីហនុ | | | | 56 .6 | | | - |
| ស្ទឹងត្រែង | | | 5 .0 | 24 .2 | 2 | | 5 .6 |
| ស្វាយរៀង | | 4 | 4 .4 | 6 .5 | 6 | 2 .0 | 6 .4 |
| តាកែវ | | 3 | 9 .3 | 9 .2 | 8 | 1 .6 | 7 .9 |
| ឧត្តរមានជ័យ | | | 4 .8 | 5 .4 | 6 | | 12 .1 |
| ក្រុងកែប | | | | 7 .6 | | | - |
| ក្រុងប៉ៃលិន | | | | 0 .0 | | | 6 .5 |
| សរុប | 24 | 13 | 15 .8 | 22 .4 | 11 | 7 .4 | 12 .0 |

ចំពោះប្រជាជនគ្មានដីលំនៅដ្ឋាន គេស្រួលកំណត់និយមន័យជាង។ ពួកនេះជាអ្នកតាំងទីលំនៅតាមចិញ្ចើម

ផ្តល់ ជាអ្នករស់នៅក្នុងលក្ខណៈបណ្តោះអាសន្ន ឬដោយរំលោភយកដីសាធារណៈ ។ ពតិមានមួយចំនួនស្តីពីការកាន់កាប់ដីលំនៅដ្ឋាន មានចុះនៅក្នុងផ្នែកស្តីអំពីកម្មសិទ្ធិដីធ្លីនៅខាងលើ ។ ទិន្នន័យបានមកពីអង្កេតទាំងអស់ដែលពិនិត្យពីគ្រួសារគ្មានដីធ្លី ត្រូវបានប្រមូលផ្តុំនៅក្នុងតារាង៦.១១ ។ ក្នុងនេះទិន្នន័យ PET-98 បង្ហាញនូវភាពគ្មានដីលំនៅដ្ឋានក៏រិតខ្ពស់ ដោយសារតែរបៀបកំណត់យកគំរូតាង (បញ្ហានេះបានបញ្ជាក់ហើយនៅពេលពិភាក្សាពីតារាង ៦.៨, ៦.៩.ក និង ៦.៩.ខ ដូច្នេះមិនចាំបាច់បកស្រាយថែមទៀតទេ) ។

តួលេខសរុប និងតួលេខតាមខេត្ត ស្តីអំពីភាពគ្មានដីកសិកម្ម ដែលស្រង់ចេញពីអង្កេតផ្សេងៗមានបង្ហាញនៅក្នុងតារាង៦.១២ ។ តួលេខតាមខេត្តនីមួយៗ គ្រាន់តែជាការចង្អុលបង្ហាញខ្លះៗប៉ុណ្ណោះ ពីព្រោះការតាក់តែងគំរូតាងនៃអង្កេតនានា មិនគួរអនុញ្ញាតឱ្យមានការបំបែកតួលេខតាមខេត្តឡើយ ។ អង្កេត MRC-95-96 បង្ហាញឱ្យឃើញនូវភាពគ្មានដីច្រើនជាងគេ ដោយសារមូលហេតុគ្រួសារភាគច្រើនជាអ្នកនេសាទ ។ អង្កេត SES-97(ជនបទ) និង SES-99(ជនបទ) មានតួលេខមិនខុសគ្នាច្រើនទេ គឺ ១៣% និង ១៥,៨% គ្មានដីកសិកម្ម ។ តើតាមនេះគេអាចសន្និដ្ឋានបានទេថា ភាពគ្មានដីបានកើនឡើង ២,៨% ពីឆ្នាំ ១៩៩៧ ដល់ ១៩៩៩? អង្កេត Baseline-98 និង LADIT-00 បង្ហាញតួលេខស្រដៀងគ្នានឹង SES-97(ជនបទ) ដែរ ។ តួលេខសរុបក្នុង Follow-up-00 ដែលទាបជាង Baseline-98 មិនអាចពន្យល់បានទេ។ សរុបមក ទិន្នន័យទាំងនេះបង្ហាញថា ភាពគ្មានដីមានពី ១២% ទៅ ១៥% ។ ប៉ុន្តែ ដោយសារមានការខ្វែងមតិច្រើននៅក្នុងការបកស្រាយទិន្នន័យស្តីពីភាពគ្មានដី ដូច្នេះគ្មានការពន្យល់បន្ថែមពីតារាងទាំងឡាយខាងលើទៀតទេ គឺទុកលទ្ធភាពឱ្យអ្នកអានធ្វើការបកស្រាយដោយខ្លួនឯងចុះ ។

ដូចបានបញ្ជាក់រួចហើយ LADIT-00 មានគោលគំនិតច្បាស់លាស់ជាងគេអំពីអត្ថន័យពិតនៃ ភាពគ្មានដីធ្លី[៩] ។ នៅក្នុងបរិបទតួនាទីបុរស-ស្ត្រី LADIT-00 បង្ហាញថា អត្រាគ្មានដីធ្លីមានក៏រិតខ្ពស់ជាងគេ ក្នុងចំណោមគ្រួសារមានស្ត្រីជាមេគ្រួ (២១,២%) ។ ដោយផ្អែកលើការធ្វើអង្កេតឡើងវិញ, LADIT-00 បង្ហាញថា ភាពគ្មានដីធ្លីបានកើនឡើងពី ៤,០១%ក្នុងឆ្នាំ១៩៦៩ ដល់ ១១,៩៧%ក្នុងឆ្នាំ១៩៩៩ (ឆ្នាំ១៩៨៤ មាន ២,៤៨%) ។ អង្កេតនេះបានបញ្ជាក់ទៀតថា មានគ្រួសារជាច្រើនត្រូវចាកចេញពីភូមិរបស់ខ្លួនក្រោយពេលក្លាយជាអ្នកគ្មានដី ។

LADIT-00 បង្ហាញថា ក្នុងចំណោមអ្នកគ្មានដីធ្លី មានប្រហែល ៤៣,៦% គ្មានដីលំនៅដ្ឋានទេ ។ ក្នុងចំណោមអ្នកគ្មានដីធ្លីដដែល ប្រហែល *៥៤,៨% មិនធ្លាប់មានដីទេ រីឯអ្នកផ្សេងទៀតបានបាត់បង់ដីទៅវិញដោយមូលហេតុផ្សេងៗ* ។ ចំពោះអ្នក *មិនធ្លាប់មានដី*, មូលហេតុបានរាយការណ៍មានដូចតទៅ: ទើបនឹងរៀបការ (៤២,៣%)[១០] ជនមាតុភូមិនិវត្តន៍ (២៧,៣%), ការដូរភូមិ (២៦,៨%), ការវិលមកពីបំរើក្នុងជួរកងទ័ព (១,៤%), ការភៀសខ្លួនក្នុងប្រទេស (០,៧%), និងមូលហេតុផ្សេងទៀត (១,៥%) ។ ចំពោះអ្នកបាន *បាត់បង់ដី* មូលហេតុមានដូចតទៅ: ចំណាយព្យាបាលជំងឺ (៤៣,៧%), កង្វះខាតស្បៀង(២០,១%), គេរំលោភយក(១៣%), ការជំពាក់បំណុល(៤,៦%), ជំនួញខាត ឬដូរមុខរបរ(៣,៥%), គ្រោះធម្មជាតិ(៣,៤%), និងមូលហេតុផ្សេងទៀត (១១,៧%) ។ អង្កេតបង្ហាញថា អាចមានមូលហេតុលើសពីមួយក្នុងពេលដំណាលគ្នា ដែលធ្វើឱ្យមានការបាត់បង់ដី ។ ភាគីរំលោភយកដីដែលគេបានរាយការណ៍ប្រាប់គឺមាន យោធា(៣៦%), អាជ្ញាធរខេត្ត(៣៥,៦%), ម្ចាស់ដីពីមុន(១២,៦%), រដ្ឋអំណាចមូលដ្ឋាន(១២,២%), ញាតិសណ្តាន(២,១%) និងមូលហេតុផ្សេងទៀត (១,៤%) ។

[៩] LADIT-00 កំនត់គ្រួសារសំដៅលើប្តី និងប្រពន្ធ ធ្វើជាឯកតារាប់ គឺខុសពីអង្កេតឯទៀតដែលកំនត់យកគ្រួសារធំ (ដែលនៅរួមគ្នា) ជាឯកតា ។ ធ្វើដូច្នេះគេអាចរកឃើញអ្នកគ្មានដីខ្លះទៀតដែលអាចកប់បាត់ បើសិនយកគ្រួសារធំរួមគ្នាធ្វើជាឯកតា ។

[១០] ទើបនឹងរៀបការ សំដៅលើអាពាហ៍ពិពាហ៍ នៅក្រោយការបែងចែកដីក្នុងទសវត្សន៍៨០ ។

## ៦.៦. ការជួលដី

នៅក្នុងប្រវត្តិសាស្ត្រ ការជួលដីនៅក្នុងសង្គមកសិករ គឺជាមធ្យោបាយមួយនៃការប្រើប្រាស់កត្តាផលិតកម្មផ្សេងៗឱ្យអស់លទ្ធភាព ហើយវាជាវិធីមួយដែលអនុញ្ញាតឱ្យអ្នកគ្មានដី អាចមានដីធ្លីបង្កបង្កើនផលតាមរយៈការបង់ថ្លៃឈ្នួល ។ ទាំងការជួលដីពីគេ ទាំងការជួលដីឱ្យគេ គឺជារបៀបរបបអនុវត្តមួយដែលមានយូរមកហើយ ។ អង្កេត MRC-95-96 បង្ហាញថា ការជួលដីមានប្រហែល ៥-៦% នៅឆ្នាំ១៩៩៥-៩៦ នៅក្នុងសហគមន៍ធ្វើអង្កេត ។ ប៉ុន្តែអង្កេត SES-97 ដែលគ្របដណ្តប់ពេញផ្ទៃប្រទេស បានបង្ហាញតួលេខទាបជាង (តារាង៦.១៣) ។

**តារាង៦.១៣ ការជួលដី: ភាគរយនៃគ្រួសារបានជួលដីកសិកម្ម (MRC-95-96 and SES-97)**[១១]

| ភាគរយនៃគ្រួសារដែល | MRC –95-96 | | | SES-97 | | |
|---|---|---|---|---|---|---|
| | គ្រួសារមាន បុរសជាមេគ្រួ | គ្រួសារមាន ស្ត្រីជាមេគ្រួ | សរុប | គ្រួសារមាន បុរសជាមេគ្រួ | គ្រួសារមាន ស្ត្រីជាមេគ្រួ | សរុប |
| ជួលដីពីគេ | 10.7 | 5.9 | 9.8 | 3.2 | 2.2 | 3.0 |
| ជួលដីឱ្យគេ | 5.1 | 6.5 | 5.4 | . | . | . |

**តារាង៦.១៤ ការជួលដី: ភាគរយនៃប្លង់ដីដែលបានជួល ( SES-99)**

| ភាគរយនៃគ្រួសារដែល | ដីលំនៅដ្ឋាន | | | ដីកសិកម្ម | | |
|---|---|---|---|---|---|---|
| | គ្រួសារមាន បុរសជាមេគ្រួ | គ្រួសារមាន ស្ត្រីជាមេគ្រួ | សរុប | គ្រួសារមាន បុរសជាមេគ្រួ | គ្រួសារមាន ស្ត្រីជាមេគ្រួ | សរុប |
| ជួលដីពីគេ | - | - | - | 4.1 | 2.3 | 3.8 |
| ជួលដីឱ្យគេ | 0.7 | 1.1 | 0.8 | 1.3 | 2.2 | 1.5 |

*ប្រភព: SES-1999 ។*

តារាង៦.១៤ បង្ហាញនូវទិន្នន័យនៃប្លង់ដី (plots) ជួលពីគេ ឬជួលឱ្យគេ ដែលបានមកពី SES-99 ។ ក្នុងនេះ (ខុសពីតារាង៦.១៣) គេអាចគណនាក៏រិតជួលដីសំរាប់ដីលំនៅដ្ឋាន និងដីកសិកម្ម ។ ដោយសារទិន្នន័យទាំងនេះគិតតាមប្លង់ដី ដូច្នេះគេមិនអាចប្រៀបធៀបឱ្យបានហ្មត់ចត់ជាមួយនឹងទិន្នន័យនៅក្នុងតារាង៦.១៣ បានទេ ។ SES-99 ក៏ដូចជាអង្កេតមុនៗដែរ បានបង្ហាញថាមានការជួលដីតិចតួចណាស់ ក្នុងនេះដីកសិកម្មមានជួលច្រើនជាងដីលំនៅដ្ឋាន។

## ៦.៧. វិសមភាពដីធ្លី

វិសមភាពដីធ្លីក្នុងសង្គមកសិករត្រូវបានលើកមកពិភាក្សា មិនមែនគ្រាន់តែដោយសារឆន្ទៈគិតប្រយោជន៍អ្នកដទៃប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីគិតគូរពីលទ្ធភាពរស់រានមានជីវិតរបស់ប្រជាជនទូទៅដែរ ពីព្រោះព្រំប្រទល់ដីមិនរីកធំលឿនដូចកំណើនប្រជាជនទេ ។ រឿងនេះកាន់តែជាក់ស្តែងថែមទៀតសំរាប់ប្រជាជនដែលពឹងពាក់លើកសិកម្មដើម្បីរស់ ។ ស្ទើរគ្រប់អង្កេតធំៗទាំងអស់ គឺបានប្រមូលទិន្នន័យពីវិសមភាពដីធ្លី ។ សេចក្តីសង្ខេបស្តីពីរបាយដីធ្លីដែលបានមកពីអង្កេតផ្សេងៗមានបង្ហាញក្នុងតារាង៦.១៥[១២] ។ គ្រប់អង្កេតទាំងអស់ បង្ហាញនូវការប្រមូលផ្តុំដី

[១១] SES-96 បង្ហាញថា គ្រួសារដែលជួលដី មានច្រើនជាង ១% បន្តិច ។

[១២] SES-96 បានប្រមូលទិន្នន័យស្តីពីដីកាន់កាប់គិតតាមទំហំដី ប៉ុន្តែទិន្នន័យមិនពេញលេញល្អទេ ដូច្នេះទើបមិនបានចុះក្នុងនេះ ។

គួរឱ្យកត់សំគាល់ ជាពិសេសក្នុងចំណោមប្រជាជនដែលមានដីលើសពី ១ហិកតា ។ អង្កេត MRC-95-96 បង្ហាញថា ២១% នៃគ្រួសារស្រទាប់លើ កាប់កាប់ដី ៦៥%, អង្កេត SES-97 (ជនបទ) បង្ហាញថា ២៣%នៃគ្រួសារទាំងនេះ កាន់កាប់ដី៧០%, អង្កេត SES-99 (ជនបទ) បង្ហាញថា ៤៤%នៃគ្រួសារធូរធារកាន់កាប់ដី ៨៨%, អង្កេត SES-99 (សរុបទូទាំងប្រទេស) បង្ហាញថា ៥២%នៃគ្រួសារធូរធារកាន់កាប់ដី ៨២%, អង្កេត Baseline-98 បង្ហាញថាគ្រួសារធូរធារ២៣% កាន់កាប់ដី ៥៦%, អង្កេត Follow-up-00 បង្ហាញថា គ្រួសារធូរធារ២៨% កាន់កាប់ដី ៦២%, អង្កេត PET-98 បង្ហាញថា គ្រួសារធូរធារ៣៦% កាន់កាប់ដី ៦៩% ។

**តារាង៦.១៥ ភាគរយរបាយគ្រួសារ, គិតតាមភាគរយនៃដីកាន់កាប់ និងតាមមេគុណវិសមភាព**

| ចំណាត់ថ្នាក់តាមទំហំដី | ភាគរយនៃគ្រួសារ | | | ភាគរយនៃដីកសិកម្មកាប់កាប់ដោយគ្រួសារ | | |
|---|---|---|---|---|---|---|
| | គ្រួសារមាន បុរសជាមេគ្រួ | គ្រួសារមាន ស្ត្រីជាមេគ្រួ | សរុប | គ្រួសារមាន បុរសជាមេគ្រួ | គ្រួសារមាន ស្ត្រីជាមេគ្រួ | សរុប |
| **MRC-95-96** (មេគុណជីនីនៃការប្រមូលផ្តុំដីកសិកម្ម = 0 .61) | | | | | | |
| គ្មានដី | 23 | 30 | 24 | - | - | - |
| >0-0 .5 ha/hh | 34 | 37 | 34 | 12 | 19 | 13 |
| >0 .5-1 .0 ha/hh | 22 | 20 | 21 | 24 | 32 | 22 |
| > 1 .0 ha/hh | 21 | 13 | 21 | 64 | 49 | 65 |
| **SES-97 (ជនបទ)** (មេគុណជីនីនៃការប្រមូលផ្តុំដីកសិកម្ម = 0 .66) | | | | | | |
| គ្មានដី | 11 | 15 | 12 | - | - | - |
| >0-0 .5 ha/hh | 37 | 48 | 40 | 8 | 18 | 10 |
| >0 .5-1 .0 ha/hh | 26 | 23 | 25 | 19 | 29 | 20 |
| > 1 .0 ha/hh | 26 | 14 | 23 | 73 | 53 | 70 |
| **SES-99 (ជនបទ)** (មេគុណជីនីនៃការប្រមូលផ្តុំដីកសិកម្ម = 0 .57) | | | | | | |
| គ្មានដី | 14 .6 | 20 .6 | 15 .8 | | | |
| >0-0 .5ha/hh | 15 .7 | 23 .8 | 17 .3 | 3 .5 | 7 .9 | 4 .1 |
| >0 .5-1 .0ha/hh | 21 .9 | 25 .6 | 22 .6 | 13 .0 | 21 .6 | 14 .2 |
| > 1 .0ha/hh | 47 .8 | 30 .0 | 44 .3 | 83 .5 | 70 .5 | 81 .7 |
| **SES-99 (សរុប)** (មេគុណជីនីនៃការប្រមូលផ្តុំដីកសិកម្ម = 0 .66) | | | | | | |
| គ្មានដី | 20 .9 | 28 .8 | 22 .4 | - | - | - |
| >0-0 .5ha/hh | 14 .6 | 21 .6 | 16 .0 | 3 .5 | 8 .0 | 4 .1 |
| >0 .5-1 .0ha/hh | 20 .2 | 22 .9 | 20 .7 | 12 .8 | 21 .8 | 14 .0 |
| > 1 .0ha/hh | 44 .3 | 26 .7 | 40 .9 | 83 .7 | 70 .2 | 81 .9 |
| **Baseline-98 (មេគុណជីនីនៃការប្រមូលផ្តុំដីកសិកម្ម =** 0 .50) | | | | | | |
| គ្មានដី | 11 | 11 | 11 | - | - | - |
| >0-0 .5 ha/hh | 34 | 43 | 35 | 14 | 14 | 14 |
| >0 .5-1 .0 ha/hh | 32 | 23 | 31 | 31 | 18 | 30 |
| > 1 .0 ha/hh | 23 | 23 | 23 | 55 | 68 | 56 |
| **Follow-up-00** (មេគុណជីនីនៃការប្រមូលផ្តុំដីកសិកម្ម = 0 .49) | | | | | | |
| គ្មានដី | 7 .5 | 4 .0 | 7 .4 | - | - | - |
| >0-0 .5 ha/hh | 35 .1 | 46 .0 | 35 .5 | 12 .6 | 17 .1 | 12 .7 |
| >0 .5-1 .0 ha/hh | 29 .4 | 28 .0 | 29 .4 | 24 .9 | 30 .7 | 25 .2 |
| > 1 .0 ha/hh | 28 .0 | 22 .0 | 27 .7 | 62 .5 | 52 .2 | 62 .1 |
| **PET-98** (មេគុណជីនីនៃការប្រមូលផ្តុំដី = 0 .47) | | | | | | |
| គ្មានដី | 16 | 30 | 17 | - | - | - |
| >0-0 .5 ha/hh | 19 | 17 | 18 | 7 | 8 | 7 |
| >0 .5-1 .0 ha/hh | 29 | 23 | 29 | 24 | 24 | 24 |
| >1 .0 ha/hh | 36 | 30 | 36 | 69 | 68 | 69 |

*កំណត់សំគាល់: hh មានន័យថាគ្រួសារ, ha មានន័យថាហិកតា ។*

មេគុណជីនីនៃវិសមភាព (Gini coefficient of inequality)) គឺជារង្វាស់នៃវិសមភាពក្នុងតំលៃពី 0 ដល់ ១ ។ សមភាពទាំងស្រុងបង្ហាញឱ្យឃើញនូវ Gini = 0 ហើយវិសមភាពទាំងស្រុងបង្ហាញនូវ Gini = 1 ។ អង្កេត MRC-95-96 បង្ហាញ Gini = 0.61 ។ មេគុណខ្ពស់នេះ បណ្តាលមកពីមានអ្នកអត់ដីច្រើននៅក្នុងគំរូតាង ពីព្រោះមេគុណជីនីប្រែប្រួលខ្លាំងទៅតាម*ភាពខុសគ្នាពីគ្រួសារមួយទៅគ្រួសារមួយ* មិនមែនប្រែប្រួលខ្លាំងទៅតាមទំហំដីជាក់ស្តែងនោះទេ ។ អង្កេតទាំងអស់ដែលបង្ហាញនូវភាពគ្មានដីកំរិតខ្ពស់ គឺមានលក្ខណៈយ៉ាងដូច្នេះ លើកលែងតែអង្កេត PET មួយចេញ ។ គួរពិនិត្យឱ្យបានហ្មត់ចត់ពីការខុសគ្នាខ្លាំង រវាងតំលៃមេគុណជីនីនៅក្នុង SES-97(ជនបទ) និង SES-99 (ជនបទ) ថាតើវាមកពីលំអៀងនៃគំរូតាង ឬមកពីលំអៀងទិន្នន័យនៅក្នុងអង្កេត SES ណាមួយឬទាំងពីរ ឬក៏បណ្តាលមកពីមានការបែងចែកដីធ្លីច្រើនគួរឱ្យកត់សំគាល់នៅទីជនបទក្នុងចន្លោះឆ្នាំ១៩៩៧-៩៩ ។ តាមពិត មានការខុសខ្លាំងក្នុងតួលេខទំហំដីកសិកម្មគិតជាមធ្យម (ដូចបានបង្ហាញក្នុងអត្ថបទនេះរួចហើយ) និងរបាយនៃការកាន់កាប់ដី (តារាង៦.១៥) រវាងគំរូតាងទាំងពីរ ។ ការប្រៀបធៀប Baseline-98 និង Follow-up-00 បង្ហាញថា ក្នុងចន្លោះពេលពីរឆ្នាំរវាងការធ្វើអង្កេតទាំងពីរ វិសមភាពបានធ្លាក់ចុះបន្តិចវិញនៅក្នុងតំបន់ធ្វើអង្កេត ។

ដោយសារ SES-99 និង Follow-up-00 ផ្តល់ទិន្នន័យថ្មីជាងគេ ទើបមានធ្វើការវិភាគលំអិតច្រើនទៅលើទិន្នន័យទាំងនេះ ។ តារាង៦.១៦ក បង្ហាញនូវរបាយកម្មសិទ្ធិដីធ្លីក្នុងអង្កេតនានាដោយដាក់តាមចន្លោះ (interval) តូចជាងក្នុងតារាង៦.១៥ ។ ទិន្នន័យ SES-99 សំរាប់តំបន់ជនបទបង្ហាញថា របាយកម្មសិទ្ធិមានសណ្ឋានស្រដៀងគ្នារហូតដល់ទំហំដី ៣ហិកតាក្នុងមួយគ្រួសារ, ប៉ុន្តែចំពោះទំហំលើសពីនេះ មានគ្រួសារតិចតួចប៉ុណ្ណោះដែលកាន់កាប់ដីច្រើន ។ តារាងនេះបង្ហាញឱ្យឃើញថា ៧.៤%នៃគ្រួសារស្រទាប់លើ កាន់កាប់ដីប្រហែល ៣0% ។ នៅក្នុងបរិបទកម្ពុជា តួលេខនេះមានកំរិតខ្ពស់ ប៉ុន្តែនៅប្រទេសអាស៊ីផ្សេងទៀត ការប្រមូលផ្តុំអាចមានកំរិតខ្ពស់ជាងនេះទៀត ។ ទិន្នន័យ Follow-up-00 បង្ហាញថា គ្មានការប្រមូលផ្តុំដីខ្លាំងទេនៅក្នុងចន្លោះពី ១ ទៅ ៣ហិកតា ប៉ុន្តែចំពោះដីធំជាងនេះ មានគ្រួសារ ៣.២% កាន់កាប់ដីចំនួន ១៥.៦% ។ ចំនុចនេះស៊ីគ្នា នឹងការរកឃើញក្នុងទិន្នន័យ SES-99 ។

**តារាង៦.១៦ក ភាគរយនៃគ្រួសារ និងភាគរយដីកសិកម្មដែលគ្រួសារកាន់កាប់ តាមអង្កេត SES-99 (ជនបទ) និង Follow-up-00**

| ចំណាត់ថ្នាក់តាមទំហំដីកសិកម្ម | ភាគរយនៃគ្រួសារ | ភាគរយនៃដីកសិកម្ម |
|---|---|---|
| SES 99 (rural) (មេគុណ Gini នៃការប្រមូលផ្តុំដី =0 .57) | | |
| គ្មានដី | 15.8 | |
| >0 – 0 .5ha | 17 .3 | 4 .1 |
| >0 .5 – 1 .0ha | 22 .6 | 14 .2 |
| >1 .0 – 1 .5ha | 13 .6 | 13 .8 |
| >1 .5 – 2 .0ha | 13 .2 | 18 .7 |
| >2 .0 – 2 .5ha | 5 .7 | 10 .0 |
| >2 .5 – 3 .0ha | 4 .4 | 9 .5 |
| >3 .0ha | 7 .4 | 29 .6 |
| Follow-up-00 (មេគុណ Gini នៃការប្រមូលផ្តុំដី = 0 .49) | | |
| គ្មានដី | 7 .4 | |
| >0 – 0 .5ha | 35 .6 | 12 .7 |
| >0 .5 – 1 .0ha | 29 .4 | 25 .2 |
| >1 .0 – 1 .5ha | 11 .3 | 16 .1 |
| >1 .5 – 2 .0ha | 8 .1 | 16 .2 |
| >2 .0 – 2 .5ha | 2 .1 | 5 .4 |
| >2 .5 – 3 .0ha | 2 .9 | 8 .9 |
| >3 .0ha | 3 .2 | 15 .6 |

វិសមភាពកាន់តែមានកំរិតខ្ពស់ចំពោះដីលំនៅដ្ឋាន គឺមេគុណជីនីធំដល់ទៅ ០,៦៨ ។ ក្នុងប្រភេទដីធំៗ មាន ១,៦% នៃដីលំនៅដ្ឋានទាំងអស់ មានទំហំលើសពី ៥.០០០ម៉ែត្រក្រឡាក្នុងដីមួយឡូត៍ៗ ហើយគ្របដណ្តប់លើជាង ៣០% នៃដីលំនៅដ្ឋានសរុបនៅក្នុងប្រទេសកម្ពុជា ។ ផ្ទុយទៅវិញ គ្រួសារជាង ៤៧% មានដីលំនៅដ្ឋានតូចៗ គឺតិចជាង ៥០០ម៉ែត្រក្រឡាក្នុងមួយឡូត៍ ដែលជាចំណុចមួយគួរឱ្យបារម្ភ ។

**តារាង៦.១៦ខ ភាគរយនៃគ្រួសារ និងភាគរយនៃដីលំនៅដ្ឋានដែលគ្រួសារកាន់កាប់តាមអង្កេត SES-99**

| ចំណាត់ថ្នាក់តាមទំហំដីលំនៅដ្ឋាន | ភាគរយនៃគ្រួសារ | ភាគរយនៃដីលំនៅដ្ឋាន |
|---|---|---|
| SES 99 (មេគុណ Gini នៃការប្រមូលផ្តុំដីលំនៅដ្ឋាន =0 .68) | | |
| គ្មានដី | 3 .1 | |
| >0 – 100m² | 15 .3 | 0 .7 |
| >101 – 500m² | 29 .3 | 7 .3 |
| >501 – 1000m² | 22 .7 | 15 .0 |
| >1001 – 5000m² | 28 .1 | 46 .9 |
| >5001m² | 1 .6 | 30 .1 |

## ជំពូក ប្រាំពីរ

# ទិដ្ឋភាពផ្សេងៗនៃការកាន់កាប់ដីកសិកម្ម

### ៧.១. ការកាន់កាប់ដី និងកំរិតជីវភាព ~ តារាងមានអញ្ញាតពីរ

ការសិក្សានានាផ្អែកលើ LADIT-00 គឺជាការស្រាវជ្រាវស្តីពីចំណងទាក់ទងរវាងភាពក្រីក្រ និងកម្មសិទ្ធិដីកសិកម្មនៅកម្ពុជា ដែលត្រូវបានគេលើកមកសំអាងញឹកញាប់ជាងគេបំផុត ។ តាមតួលេខស្ថិតិ ទំនាក់ទំនងរវាងអញ្ញាត (variables) ទាំងពីរ ក៏ឃើញមានក្នុងប្រទេសកសិកម្មនានានៅអាស៊ី និងតំបន់ផ្សេងទៀតក្នុងពិភពលោកដែរ[១] ។ តាមចរិតសមហេតុផល គេស្រួលយល់បានទេថា កាលណាដីកសិកម្មគឺជាមធ្យោបាយចំបងសំរាប់រកចំណូល និងដោះស្រាយជីវភាព ដូច្នេះភាពក្រីក្រវាអាចកើតចេញពីភាពគ្មានដីធ្លី ។ ប៉ុន្តែដោយ LADIT-00 មិនបានប្រមូលទិន្នន័យពីចំណូលជាក់ស្តែង ឬក៏ផ្តល់ពត៌មានពីប្រភពផ្សេងៗដែលប្រជាជននៅជនបទអាចរកចំណូលបាន ដូច្នេះគេក៏មិនអាចរកស្ថិតិមកបញ្ជាក់បានដែរថា អ្នកគ្មានដីធ្លីគឺជាអ្នកដែលក្រីក្របំផុត ។ នៅក្នុងរឿងនេះ ការអង្កេតដល់កន្លែងមួយ ដែលបានធ្វើពីមុននៅក្នុងតំបន់ជនបទកម្ពុជា ហាក់ដូចជាបង្ហាញថា ប្រជាជនរកចំណូលពីប្រភពជាច្រើនៈ កសិកម្ម ព្រៃឈើ នេសាទ ការងារស៊ីប្រាក់កំរៃ ហើយចំនូលពីការងារធ្វើកសិកម្មមិនមែនចំបងគេនោះទេ (Murshid 1998)[២] ។ ដូច្នេះរវាងភាពក្រីក្រ/កំរិតជីវភាព និងការកាន់កាប់ដី គឺពុំមានចំណងទាក់ទងសមាមាត្រគ្នាទេ ។

នៅក្នុងជំពូកនេះ កំរងទិន្នន័យថ្មីជាងគេបំផុតគឺ SES-99 និង Follow-up-00 ត្រូវបានយកទៅធ្វើតារាងប្រៀបធៀបដ៏លំអិត ជាមួយនឹងអញ្ញាតជ្រើសរើសមួយចំនួន ដើម្បីវាយតំលៃពីចំណងទាក់ទងរវាងកម្មសិទ្ធិដីធ្លី និងកំរិតជីវភាព ។ ដោយហេតុថា Baseline-98 និង Follow-up-00 អនុវត្តលើក្របខ័ណ្ឌគំរូតាងតែមួយ ហើយបញ្ជីសំនួរក៏ដូចគ្នាដែរ ដូច្នេះគំរូតាងទាំងពីរត្រូវបានបញ្ចូលគ្នាដើម្បីអាចតំណាងបានកាន់តែប្រសើរឡើង ។ ការគណនាបានចូលជ្រៅលើសពីអញ្ញាតទាំងពីរ ដើម្បីអាចមើលឃើញបានទូលាយនូវទិដ្ឋភាពនានានៃកម្មសិទ្ធិដីកសិកម្ម ។ ការវិភាគនេះធ្វើតែនៅតាមតំបន់ជនបទទេ ដែលនៅទីនោះប្រជាជនធ្វើការងារកសិកម្មជាសំខាន់ដើម្បីចិញ្ចឹមជីវិត ។

តារាង៧.១បង្ហាញពីការគណនាទិន្នន័យពីរផ្លូវស្តីពីរបាយគ្រួសារនៅជនបទតាមចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ (ប្រើជាខ្នាតសំរាប់វាស់កំរិតជីវភាព) និងការកាន់កាប់ដីកសិកម្មតាមតួលេខក្នុង SES-99 ។ តារាងនេះបង្ហាញនូវលទ្ធផលមួយចំនួនដែលគេមិនបានរំពឹងទុក ។ បន្ទាត់ទី១ បង្ហាញថា ១៣.៨% នៃគ្រួសារ

---

[១] សូមអានឯកសារ Visaria (1981) and Srinivasan and Bardhan (1988) ។ ទស្សនាវដ្តី The Economist ក៏បានបង្ហាញហេតុផលប្រហែលគ្នានេះដែរសំរាប់អាហ្វ្រិក (*The Economist*, March 31 2001:19) ។

[២] រឿងនេះក៏មានការបញ្ជាក់ពីទិន្នន័យក្នុង Baseline-98 និង Follow-up-00 ដែលបានផ្តល់ពត៌មានពីប្រាក់ចំនូលតាមប្រភព ។

គ្មានដីធ្លី ស្ថិតក្នុងបញ្ចភាគគ្រួសារក្រីក្របំផុត ហើយបន្ទាត់ទី១ស្ទួន (នៃក្រឡាដដែល)បង្ហាញថា នៅក្នុងបញ្ចភាគក្រីក្របំផុតនេះ គ្រួសារដែលគ្មានដីធ្លីមានតែ ១០,៩% ប៉ុណ្ណោះ ។ មួយចំណែកទៀត ៣៧,៧% នៃគ្រួសារគ្មានដីធ្លីស្ថិតនៅក្នុងបញ្ចភាគគ្រួសារធូរធារបំផុត ហើយនៅក្នុងបញ្ចភាគនេះ គ្រួសារដែលគ្មានដីធ្លីមាន ២៩,៧% (បន្ទាត់ទី១ ជួរទី៦) ។ ផ្ទុយទៅវិញ ២៣,៦% នៃ "គ្រួសារមានដីពីបីហិកតាឡើងទៅ" ស្ថិតនៅក្នុងបញ្ចភាគក្រីក្របំផុត ហើយនៅក្នុងបញ្ចភាគនេះ គ្រួសារក្រីក្របំផុតដែលមានដីពីបីហិកតាឡើងទៅ មាន ៨,៨% ។ ទោះបីនៅក្រៅពីក្រឡាខាងចុងទាំងនេះក៏ដោយ ក៏មិនឃើញមានលំនាំអ្វីជាក់លាក់ទេ ។ ក្រោយពីដកអ្នកគ្មានដីសោះចេញពីគំរូតាង ហើយ គេឃើញមានចំណងទាក់ទងខ្សោយណាស់រវាងចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ និងការកាន់កាប់ដីធ្លី ។ ប៉ុន្តែតើយើងដកអ្នកគ្មានដីធ្លី (ដែលជាចំណុចស្នូលនៃការជជែកវែកញែកពីភាពក្រីក្រនៅជនបទ) ចេញពីការគណនាយ៉ាងដូចម្តេចទៅ? អ្នកខ្លះយល់ថា លំអៀងទិន្នន័យក្នុងការវាស់វែងចំនាយប្រើប្រាស់ គឺអាចកើតមានបាន[៣] ។ ដើម្បីផ្ទៀងផ្ទាត់រឿងនេះ គេអាចមានគំនិតខ្លះៗ បើសិនធ្វើការគណនាដូចគ្នាចេញពីកំរងទិន្នន័យមួយទៀត ដូចជា Baseline-98/Follow-up-00 ជាដើម ។

**តារាង៧.១ របាយជា ភាគរយនៃគ្រួសារនៅជនបទ គិតតាមការកាន់កាប់ដីកសិកម្ម និងចំណាយប្រើប្រាស់ក្នុងគ្រួសារ គិតក្នុងមនុស្សម្នាក់ (បន្ទាត់ និងជួរ %) ដែលគណនាចេញពី SES-99**

| ការកាន់កាប់ដីកសិកម្ម (ហិកតា) | បញ្ចភាគទី១ (ក្របំផុត) | បញ្ចភាគ ទី២ | បញ្ចភាគ ទី៣ | បញ្ចភាគ ទី៤ | បញ្ចភាគទី៥ (មានបំផុត) | សរុប |
|---|---|---|---|---|---|---|
| 0.00 | 13.8 | 14.2 | 15.1 | 19.2 | 37.7 | 100 |
| | 10.9 | 11.1 | 11.9 | 15.1 | 29.7 | 15.8 |
| 0.0001-0.50 | 23.1 | 21.6 | 19.1 | 18.4 | 17.8 | 100 |
| | 19.9 | 18.6 | 16.4 | 15.9 | 15.4 | 17.3 |
| 0.5001-1.00 | 21.7 | 21.8 | 22.8 | 19.3 | 14.3 | 100 |
| | 24.6 | 24.6 | 25.8 | 21.9 | 16.2 | 22.6 |
| 1.0001-1.50 | 23.9 | 20.9 | 19.9 | 19.8 | 15.5 | 100 |
| | 16.3 | 14.2 | 13.6 | 13.5 | 10.6 | 13.6 |
| 1.5001-2.00 | 18.0 | 22.6 | 24.5 | 21.7 | 13.2 | 100 |
| | 11.9 | 14.9 | 16.2 | 14.4 | 8.8 | 13.2 |
| 2.0001-2.50 | 15.5 | 23.6 | 20.2 | 17.4 | 23.3 | 100 |
| | 4.4 | 6.7 | 5.7 | 4.9 | 6.6 | 5.7 |
| 2.5001-3.00 | 14.8 | 20.8 | 19.8 | 28.4 | 16.2 | 100 |
| | 3.2 | 4.5 | 4.3 | 6.2 | 3.5 | 4.4 |
| 3.0001 & more | 23.6 | 14.2 | 16.3 | 21.3 | 24.6 | 100 |
| | 8.8 | 5.3 | 6.1 | 8.0 | 9.2 | 7.4 |
| Total | 20.0 | 20.0 | 20.0 | 20.0 | 20.0 | 100 |
| | 100 | 100 | 100 | 100 | 100 | 100 |

តារាង៧.២ បង្ហាញពីការគណនាពីរផ្លូវនូវទិន្នន័យរបាយគ្រួសារនៅតាមជនបទគិតតាមចំនាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ និងការកាន់កាប់ដីកសិកម្ម ដោយផ្អែកលើតួលេខនៃ Baseline-98/Follow-up-00 ។ ដូចក្នុង SES-99 ដែរ ទិន្នន័យទាំងនេះបង្ហាញថា ក្នុងចំណោមគ្រួសារគ្មានដីធ្លីទាំងអស់មាន ៩,៣% ស្ថិតក្នុងបញ្ចភាគក្រីក្របំផុត និង ៣០% ក្នុងបញ្ចភាគមានចំណាយប្រើប្រាស់ខ្ពស់បំផុត ។ ផ្ទុយទៅវិញ ក្នុងចំណោមគ្រួសារកាន់កាប់ដីពីបីហិកតាឡើងទៅមាន ១៤,៧% ស្ថិតក្នុងបញ្ចភាគមានចំនាយប្រើប្រាស់ទាបបំផុត និង ២២,១% ក្នុងបញ្ចភាគ

[៣] Gibson (2000) បានគណនាពីភាពក្រីក្រដោយផ្អែកលើទិន្នន័យ SES-99 ហើយគាត់គិតថា អាចមានលំអៀងទិន្នន័យខ្លះៗ ។

មានចំណាយប្រើប្រាស់ខ្ពស់បំផុត ។ ដូចមុនដែរ មានចំនងទាក់ទងវិជ្ជមានខ្សោយរវាងចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ និងការកាន់កាប់ដីធ្លី (ក្រោយពីដកគ្រួសារគ្មានដីសោះចេញពីគំរូតាង) ។ ប៉ុន្តែយើងជួបនឹងសំនួរដដែលទៀត: តើដកគ្រួសារគ្មានដីសោះចេញពីគំរូតាងយ៉ាងដូចម្តេចបាន?

មតិស្តីពីលំអៀងទិន្នន័យដូចបានលើកពីមុន អាចលើកលែងចំពោះការពិភាក្សានៅពេលនេះបាន ពីព្រោះកំរងទិន្នន័យនានាបានផ្តល់លទ្ធផលប្រហាក់ប្រហែលគ្នា ។ សំនួរបន្តមកទៀតគឺថា តើចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ វាវាស់វែងកំរិតជីវភាពបានល្អឬទេ ។ សំនួរមួយទៀត តើការកាន់កាប់ដីវាវាស់វែងពីកំរិតជីវភាពបានល្អឬទេ ឬក៏ត្រូវគិតគូរពីអញ្ញាតផ្សេងទៀតដូចជា ការត្រួតត្រាជាក់ស្តែងលើដីធ្លី ផលិតភាព និងលទ្ធភាពមានទុនប្រើការ គឺបានន័យថា បញ្ហាដីមិនទាន់បានពិនិត្យសមស្របទេនៅក្នុងអង្កេតទាំងនេះ ដើម្បីឆ្លុះបញ្ចាំងពីភាពក្រីក្រ និងកំរិតជីវភាព ។

**តារាង៧.២ របាយជាភាគរយនៃគ្រួសារ គិតតាមដីកសិកម្មកាន់កាប់ និងតាមចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ (បន្ទាត់ និង ជួរ %) ដោយគណនាចេញពី Baseline-98/Follow-up-00**

| ដីកសិកម្មកាន់កាប់ (ha) | បញ្ចភាគ ក្រីក្របំផុត | បញ្ចភាគ ទី២ | បញ្ចភាគ ទី៣ | បញ្ចភាគ ទី៤ | បញ្ចភាគ ធូរធារបំផុត | សរុប |
|---|---|---|---|---|---|---|
| 0.00 | 9.3 | 16.3 | 25.6 | 18.6 | 30.2 | 100 |
| | 1.8 | 3.3 | 5.1 | 3.8 | 5.9 | 4.0 |
| 0.0001-0.50 | 19.1 | 19.8 | 20.2 | 20.2 | 20.8 | 100 |
| | 34.7 | 37.7 | 37.5 | 39.0 | 38.4 | 37.4 |
| 0.5001-1.00 | 19.1 | 22.1 | 20.7 | 18.9 | 19.2 | 100 |
| | 29.5 | 35.8 | 32.6 | 31.1 | 30.1 | 31.8 |
| 1.0001-1.50 | 30.0 | 18.6 | 18.2 | 19.8 | 13.4 | 100 |
| | 16.7 | 10.8 | 10.3 | 11.7 | 7.5 | 11.4 |
| 1.5001-2.00 | 27.3 | 14.3 | 16.8 | 17.4 | 24.2 | 100 |
| | 9.9 | 5.4 | 6.2 | 6.7 | 8.9 | 7.5 |
| 2.0001-2.50 | 23.1 | 17.3 | 21.2 | 17.3 | 21.2 | 100 |
| | 2.7 | 2.1 | 2.5 | 2.2 | 2.5 | 2.4 |
| 2.5001-3.00 | 22.0 | 12.0 | 18.0 | 20.0 | 28.0 | 100 |
| | 2.5 | 1.4 | 2.1 | 2.4 | 3.2 | 2.3 |
| 3.0001 ឡើងទៅ | 14.7 | 20.6 | 23.5 | 19.1 | 22.1 | 100 |
| | 2.3 | 3.3 | 3.7 | 3.1 | 3.4 | 3.1 |
| សរុប | 20.6 | 19.6 | 20.1 | 19.4 | 20.3 | 100 |
| | 100 | 100 | 100 | 100 | 100 | 100 |

កំរិតជីវភាពក៏អាចវាស់បានតាមអញ្ញាតផ្សេងទៀតដែរដូចជា កំរិតអប់រំ វត្តមានពលកម្មកុមារ អត្រាមរណៈ គុណភាពផ្ទះសំបែង សមាជិកគ្រួសារដែលខ្វះស្បៀងហូបមួយរយៈនៅក្នុងឆ្នាំ និងចំណាកស្រុកតាមរដូវកាល[៤] ។ ដើម្បីវិនិច្ឆ័យពីទំនាក់ទំនងរវាងការកាន់កាប់ដីធ្លី និងអញ្ញាតទាំងនេះ ការធ្វើតារាងប្រៀបធៀម រវាងទំហំនៃដីកសិកម្មកាន់កាប់ និងកំរិតអប់រំរបស់មេគ្រួសារ, រវាងទំហំដីកសិកម្មកាន់កាប់ និងពលកម្មកុមារ, រវាងទំហំដីកសិកម្មកាន់កាប់ និងអត្រាមរណៈភាព, ត្រូវបានធ្វើដោយប្រើកំរងទិន្នន័យ SES-99 ។ មិនឃើញមានទំនាក់ទំនងគួរកត់សំគាល់ទេរវាងអញ្ញាតមួយគូៗទាំងនេះ ។ ដូចគ្នាដែរ ការធ្វើតារាងប្រៀបធៀម រវាងដីកសិកម្មកាន់កាប់នឹងប្រភេទនៃផ្ទះ, រវាងដីកសិកម្មកាន់កាប់ និងការអត់ឃ្លាន, រវាងដីកសិកម្មកាន់កាប់ និងចំណាកស្រុកតាមរដូវ,

[៤] Dreze and Sen (1991) បានវែកញែកអញ្ញាតទាំងនេះយ៉ាងសមស្រប ដែលអាចជាកត្តាកំណត់ភាពក្រីក្រ ។

ត្រូវបានធ្វើដោយប្រើកំរងទិន្នន័យផ្សេងគឺ Baseline-98/Follow-up-00 ។ ដូចមុនដែរ ពុំមានទំនាក់ទំនងគួរកត់សំគាល់រវាងអញ្ញាតមួយគូរ១ទាំងនេះទេ ។ ការធ្វើតារាងប្រៀបធៀប (ដែលមិនបានបង្ហាញក្នុងឯកសារនេះ) គឺជាភស្តុតាងបញ្ជាក់ថា ពុំមានកំហុសអ្វីដែលលេចធ្លោនៅក្នុងការកំណត់និយមន័យនៃអញ្ញាត "គំរិតជីវភាព" ទេ ។

**តារាង៧.៣ របាយគ្រួសារនៅជនបទ គិតតាមដីកសិកម្មកាន់កាប់ និងដីលំនៅដ្ឋានកាន់កាប់ (បន្ទាត់ និងជួរ %) តាមទិន្នន័យ SES-99**

| ដីកសិកម្មកាន់កាប់ (ha) | ដីលំនៅដ្ឋានជាម៉ែត្រការ៉េ | | | | | | |
|---|---|---|---|---|---|---|---|
| | សូន្យ | 1-100 | 101-500 | 501-1000 | 1001-5000 | 5001 ឡើងទៅ | សរុប |
| 0.00 | 11.9 | 31.3 | 29.4 | 16.5 | 11.3 | 0.0 | 100 |
| | 67.6 | 43.3 | 15.5 | 10.8 | 6.0 | 0.0 | 15.8 |
| 0.0001-0.50 | 2.4 | 9.4 | 35.4 | 25.0 | 26.5 | 1.2 | 100 |
| | 15.1 | 14.4 | 20.5 | 18.1 | 15.6 | 7.3 | 17.3 |
| 0.5001-1.00 | 0.8 | 8.7 | 31.9 | 25.7 | 30.4 | 2.5 | 100 |
| | 6.2 | 17.5 | 24.1 | 24.5 | 23.3 | 20.4 | 22.6 |
| 1.0001-1.50 | 0.2 | 7.0 | 31.0 | 25.0 | 32.1 | 4.7 | 100 |
| | 1.2 | 8.5 | 14.1 | 14.3 | 14.9 | 22.9 | 13.6 |
| 1.5001-2.00 | 1.0 | 5.6 | 27.2 | 23.5 | 38.4 | 4.4 | 100 |
| | 4.6 | 6.6 | 12.0 | 13.1 | 17.3 | 20.6 | 13.2 |
| 2.0001-2.50 | 0.0 | 8.7 | 31.2 | 21.1 | 31.8 | 7.2 | 100 |
| | 0.0 | 4.4 | 5.9 | 5.0 | 6.1 | 14.5 | 5.7 |
| 2.5001-3.00 | 1.3 | 4.2 | 23.9 | 30.4 | 38.2 | 2.0 | 100 |
| | 2.1 | 1.6 | 3.5 | 5.6 | 5.7 | 3.1 | 4.4 |
| 3.0001 ឡើងទៅ | 1.2 | 5.7 | 17.2 | 27.7 | 44.0 | 4.2 | 100 |
| | 3.2 | 3.7 | 4.3 | 8.7 | 11.1 | 11.2 | 7.4 |
| សរុប | 2.8 | 11.3 | 29.9 | 23.8 | 29.4 | 2.8 | 100 |
| | 100 | 100 | 100 | 100 | 100 | 100 | 100 |

ការគណនាប្រៀបធៀបរវាងទំហំដីកសិកម្មកាន់កាប់ និងដីលំនៅដ្ឋានកាន់កាប់ មានបង្ហាញក្នុងតារាង៧.៣ ក្នុងគោលដៅពិនិត្យថាតើការកាន់កាប់ដីកសិកម្មមានទំនាក់ទំនងអ្វីទេ ។ តារាងនេះបង្ហាញនូវទំនាក់ទំនងគួរឱ្យកត់សំគាល់ខាងស្ថិតិរវាងអញ្ញាតទាំងពីរ (the Pearson correlation coefficient is small at 0.10, but is valid at 0.05 percent confidence level) ។ ដូច្នេះអ្នកមានដីកសិកកម្មច្រើន តែងមានដីលំនៅដ្ឋានច្រើនដែរ ។

ជារួមការវិភាគខាងលើនេះបានបង្ហាញថា ដីកសិកម្មកាន់កាប់ ឬដីលំនៅដ្ឋានកាន់កាប់ តាមការវាស់វែងក្នុងអង្កេតនានា ពុំមានបង្ហាញទំនាក់ទំនងខាងស្ថិតិជាមួយនឹងគំរិតជីវភាពទេ ទោះជាវាស់វែងតាមរបៀបណាក៏ដោយ ។ ដូច្នេះគួរមានការប្រមូលពតិមានលំអិតច្រើនថែមទៀតអំពីការកាន់កាប់ដី ការប្រើប្រាស់ និងត្រួតត្រាដី ដើម្បីស្រាវជ្រាវពីបញ្ហានេះឱ្យបានស៊ីជំរៅថែមទៀត ។

## ៧.២. ការវិភាគមានអញ្ញាតច្រើន

ដើម្បីស្វែងរក និងពន្យល់អញ្ញាតនានានៃគំរិតជីវភាព ជាពិសេសដើម្បីវិនិច្ឆ័យពីទំនាក់ទំនងរវាងគំរិតជីវភាព និងការកាន់កាប់ដីធ្លី *នៅក្នុងក្របខ័ណ្ឌមួយមានអញ្ញាតច្រើន* (multivariate framework) ដែលខុសពីការគណនាមានអញ្ញាតពីរដូចនៅខាងលើ ត្រូវប្រើសមីកា multiple regression ។ គំរូមានលក្ខណៈសាមញ្ញណាស់ គឺផ្អែកលើគោលការណ៍ដែលថា ប្រជាជនរស់នៅ និងហូបចុកប្រសើរឡើង នៅពេលប្រាក់ចំណូលកើនឡើង ហើយគំរិតប្រាក់ចំនូលក៏ត្រូវផ្សារភ្ជាប់វិញដែរទៅនឹងលទ្ធភាពខាងសំភារៈ និងធនធានមនុស្សរបស់ពួកគេ, សមត្ថភាពនៃបរិស្ថានសេដ្ឋកិច្ច-សង្គមកិច្ចក្នុងការផ្តល់នូវចំណូល និងការពឹងផ្អែកខាងសេដ្ឋកិច្ចនៅក្នុងគ្រួសារ ។

អញ្ញាតពឹងផ្អែកនៅក្នុង regression គឺជាចំណាយប្រចាំឆ្នាំលើអីវ៉ាន់គ្រប់មុខ[៥] ដែលវាស់វែងតាមចំណាយក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់ និងជាសរុប ។ អញ្ញាតនេះវាស់វែងក្នុងរូបភាពជា natural logarithmic ពីព្រោះសមីការសមស្របនឹងរូបភាពនេះជាង ។ លទ្ធភាពខាងសំភារៈ គឺវាស់វែងតាមទំហំដីកសិកម្មកាន់កាប់ ដោយរាប់បញ្ចូលទាំងអ្នកគ្មានដីសោះផងដែរ ។ ធនធានមនុស្ស វាស់វែងតាមកំរិតអប់រំដែលបានទទួល (ចំនួនឆ្នាំសិក្សា) ។ សមត្ថភាពនៃបរិស្ថានក្នុងការផ្តល់ចំណូល វាស់វែងតាមចំណូលមធ្យមនៅក្នុងភូមិ (ឬផលិតភាពនៃស្រូវ) ។ ការពឹងផ្អែកខាងសេដ្ឋកិច្ចវាស់វែងតាមសមាមាត្របញ្ច្រាសនៃអញ្ញាត (the reverse of the variable) ដែលជាផលចែករវាងចំនួនមនុស្សធ្វើការ និងចំនួនសរុបនៃសមាជិកក្នុងគ្រួសារ ។

សមីការដែលប៉ាន់ស្មានតាមទិន្នន័យ SES-99 សំរាប់តំបន់ជនបទ គឺជាសមីការដូចក្នុង (1) ខាងក្រោម:

$$\text{(1) Ln (PCC)} = \underset{(0.041)}{13.21^*} - \underset{(0.005)}{1.91(10)^{-2}\,\text{LAND}^*} + \underset{(0.002)}{2.57(10)^{-2}\,\text{EDN}^*} + \underset{(0.042)}{0.29\,\text{ECOD}^*} + \underset{(0.000)}{8.87(10)^{-7}\,\text{VINC}^*} - \underset{(0.005)}{5.06(10)^{-2}\,\text{HHS}^*}$$

$R^2 = 0.26$ $F = 251.86$ $n = 3599$

*កំណត់សំគាល់:* PCC – ចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ (រៀល), LAND – ដីកសិកម្មកាន់កាប់ (ha), EDN – ចំនួនឆ្នាំសិក្សា, ECOD – អត្រាពឹងផ្អែកសេដ្ឋកិច្ច, VINC – ចំណូលគ្រួសារមធ្យមនៅក្នុងភូមិ (រៀល) និង HHS ទំហំគ្រួសារ ។ តួលេខក្នុងរង្វង់ក្រចកគឺជាការប៉ាន់ស្មានពីលំអៀងស្តង់ដា (respective standard error estimates) និង * មានន័យថា statistical significance at 5 percent confidence level ។

សមីការនេះមានលក្ខណៈល្អពីព្រោះ អញ្ញាតពន្យល់ទាំងអស់មានកំរិតលំអិតស្ថិតិត្រឹម ៥% (all explanatory variables are statistically significant at 5 percent confidence level) ។ មេគុណអញ្ញាតទាំងអស់ (ក្រៅពី LAND ចេញ) បង្ហាញថា PCC វាស់វែងកំរិតជីវភាពបានសមស្រប ។ ចំណុចចំលែកក្នុងសមីការនេះ គឺតួលេខអវិជ្ជមាននៃមេគុណ LAND ដែលមានន័យថា អ្នកគ្មានដី និងអ្នកកាន់កាប់ដីតូចតាច ជាទូទៅមានកំរិតជីវភាពខ្ពស់ជាង ។ ចំណុចចំលែកនេះក៏បានពិនិត្យឃើញនៅក្នុងការវិភាគមានអញ្ញាតពីរ ដែលបានធ្វើពីខាងដើមដែរ ។

សមីការត្រូវបានប៉ាន់ស្មានឡើងវិញដោយក្នុងនេះ អញ្ញាតពឹងផ្អែក "ចំណាយប្រើប្រាស់ក្នុងគ្រួសារគិតក្នុងមនុស្សម្នាក់" ត្រូវបានជំនួសដោយ "ចំណាយប្រើប្រាស់សរុបវិញ" ។ ធ្វើដូច្នេះគឺដើម្បីជៀសវាងកំហុសក្នុងការប៉ាន់ស្មានដែលអាចកើតមាន កាលណាមានអញ្ញាតឯករាជ្យណាមួយ (ទំហំគ្រួសារក្នុងករណីនេះ) វាដើរតួជាភាគបែងនៅក្នុងអញ្ញាតពឹងផ្អែក (denominator in the dependent variable)[៦] ។ សមីការធ្វើការប៉ាន់ស្មានជាមួយនឹងទិន្នន័យ SES-99 មានបង្ហាញក្នុងសមីការ (2) ខាងក្រោម:

$$\text{(2) Ln (TC)} = \underset{(0.041)}{13.84^*} - \underset{(0.005)}{1.78(10)^{-2}\,\text{LAND}^*} + \underset{(0.002)}{2.80(10)^{-2}\,\text{EDN}^*} + \underset{(0.042)}{0.16\,\text{ECOD}^*} + \underset{(0.000)}{8.52(10)^{-7}\,\text{VINC}^*} + \underset{(0.005)}{0.14\,\text{HHS}^*}$$

$R^2 = 0.40$ $F = 469.59$ $n = 3599$

*កំណត់សំគាល់:* TC – ចំណាយប្រើប្រាស់សរុបក្នុងមួយគ្រួសារ ។

សមីការនេះមានលក្ខណៈសមស្របជាងសមីការមុន (total explanation here is 40 percent) ។ មេគុណនិមួយៗមានកំរិតលំអិត ៥% ។ មេគុណនៃទំហំគ្រួសារមានតួលេខវិជ្ជមាន ហើយធំគួរកត់សំគាល់, និងមានលក្ខណៈ

---

[៥] SES វាស់វែងចំណាយស្បៀងលើមូលដ្ឋានប្រចាំសប្តាហ៍, ចំនាយលើអីវ៉ាន់មិនជាប់លាប់ផ្សេងទៀតលើមូលដ្ឋានប្រចាំខែ, និងចំណាយលើអីវ៉ាន់ជាប់លាប់ និងសេវា (ឧ. ថ្លៃសាលារៀន) លើមូលដ្ឋានប្រចាំឆ្នាំ ។ ចំណាយទាំងអស់នេះត្រូវបានយកមកគណនាចេញលើមូលដ្ឋានប្រចាំឆ្នាំ ។

[៦] មានការខ្វែងមតិគ្នាយ៉ាងច្រើនក្នុងរឿងនេះ (see paper by Ahluwalia, in Mellor and Desai, 1985) ។

កែតំរូវខាងស្ថិតិទប់ទល់នឹងលំអៀងនានាដែលអាចកើតមានឡើងដោយសារទំហំគ្រួសារមិនស្មើគ្នា ។ ប៉ុន្តែសមីកានេះមានចំណុចចំលែកដូចមុននៃមេគុណអវិជ្ជមាននិងធំគួរកត់សំគាល់ខាងស្ថិតិនៃអញ្ញាត LAND ។

ក្នុងការខិតខំរកមើលថាតើតួលេខអវិជ្ជមាននៃមេគុណ LAND វាកើតមានឡើងដោយសារពួកអ្នកខុសគេខ្លាំងនៅក្នុងគំរូតាង (far flung outliers in the sample), សមីកាត្រូវបានប៉ាន់ស្មានឡើងវិញដោយប្រើ qualitative response model (a logistic regression model) ដែលក្នុងនេះអញ្ញាតពឹងផ្អែក គឺជាអញ្ញាតមានពីរសណ្ឋាន (គ្រួសារស្ថិតនៅខាងលើ ឬមួយនៅខាងក្រោមនៃបន្ទាត់ក្រីក្រ) ។ បន្ទាត់ក្រីក្រ គឺដូចគ្នានឹងបន្ទាត់កសាងឡើងដោយលោក Gibson (2000) ។ ចំណុចខុសគ្នាតែមួយក្នុងសមីកានេះគឺ មេគុណ LAND មិនធំគួរកត់សំគាល់ខាងស្ថិតិទេ ។ ដូច្នេះក៏គ្មានអ្វីដែលផ្ទុយនឹងសម្មតិកម្មពីមុនមកដែរ ។

គំរូក៏ត្រូវបានប៉ាន់ស្មានតាមទិន្នន័យ Baseline-98/Follow-up-00 ផងដែរ ។ ក្នុងនេះ ដោយសារគ្មានទិន្នន័យពីចំណូលមធ្យមនៅក្នុងភូមិ ដូច្នេះទិន្នផលស្រូវមធ្យមក្នុងភូមិត្រូវបានយកមកប្រើ ហើយចំណាយប្រើប្រាស់ក្នុងគ្រួសារត្រូវបានវាស់វែងប្រចាំខែ ។ ដោយហេតុថា Baseline-98/Follow-up-00 ជាលក្ខណៈបច្ចេកទេសគឺកើតចេញពីកំរងទិន្នន័យពីរ ដូច្នេះ intercept dummy មួយត្រូវបានដាក់បន្ថែម ដើម្បីបំបែកទិន្នន័យទាំងពីរចេញពីគ្នា ។ សមីកាប៉ាន់ស្មានតាមពីរបែប មានបង្ហាញក្នុងសមីកា (3) និង (4) ដូចខាងក្រោម:

(3) $Ln(PCC) = 10.70^{*} + 5.05(10)^{-3}\ LAND + 1.88(10)^{-2}\ EDN^{*} + 0.23\ ECOD^{**} + 3.24(10)^{-4}\ VINC^{*} - 8.20(10)^{-2}\ HHS^{*} - 7.64(10)^{-2}\ DUM^{*}$

(0.094) (0.018) (0.005) (0.122) (0.000) (0.008) (0.033)

$R^2 = 0.08$  F = 31.29  n = 2155

(4) $Ln(TC) = 11.59^{*} + 9.22(10)^{-3}\ LAND + 1.95(10)^{-2}\ EDN^{*} - 1.29(10)^{-2}\ ECOD + 3.25(10)^{-4}\ VINC^{*} + 7.63(10)^{-2}\ HHS^{*} - 7.98(10)^{-2}\ DUM^{*}$

(0.094) (0.018) (0.005) (0.122) (0.000) (0.008) (0.033)

$R^2 = 0.06$  F = 22.60  n = 2155

*Legend:* DUM - Intercept Dummy Variable to differentiate between the two samples, and ** refers to statistical significance at 10 percent confidence level.

សមីកាទាំងពីរនេះមិនសូវសមស្របទេ បើធៀបនឹងសមីកាមុនៗ ($R^2$ មានតំលៃទាបជាង) ។ ប៉ុន្តែក្នុងសមីកាទាំងពីរ, មេគុណ LAND គ្មានលក្ខណៈគួរកត់សំគាល់ខាងស្ថិតិទេ[៧] ។ ដូចមុនដែរ ចំណុចចំលែកនៃចំណងទាក់ទងអវិជ្ជមាន ឬមិនគួរឱ្យកត់សំគាល់រវាងកម្មសិទ្ធិដីធ្លី និងកំរិតជីវភាព បានឃើញកាន់តែច្បាស់ទៀតក្នុងសមីកាទាំងពីរ ។ អញ្ញាតឯទៀតៗបានបង្ហាញជាទូទៅនូវអ្វីដែលបានពិនិត្យឃើញក្នុងសមីកាមុនៗ ។

សេចក្តីសន្និដ្ឋានបណ្តោះអាសន្នមួយចំនួនអាចធ្វើបាននៅពេលនេះ: ១. អ្នកគ្មានដីធ្លីទាំងអស់នៅជនបទមិនសុទ្ធតែក្រីក្រដូចៗគ្នាទេ ហើយពួកគេមានមធ្យោបាយជាច្រើនសំរាប់ចិញ្ចឹមជីវិត ២. គ្រួសារនានាដែលកាន់កាប់ដីធំៗ ក៏មានគ្រួសារធំដែរ ដូច្នេះមានសមាជិកគ្រួសារច្រើនត្រូវទ្រទ្រង់ (មានទិន្នន័យបញ្ជាក់គាំទ្រ)[៨] ៣. អាចថាប្លង់ដីធំៗមានគុណភាពដីមិនសូវល្អ ឬត្រូវបំបែកជាច្រើនដុំ, ហើយដីធំៗអាចមិនសូវបានប្រើប្រាស់ខ្លាំងទេ ។ ក្នុងនេះគួរបញ្ជាក់ឡើងវិញពីចំណុចសង្កេតពីមុនដែលថា ទិន្នន័យទាំងនេះមិនសូវសមស្រប សំរាប់ការវិភាគពីស្ថានភាពដីទេ ។

---

៧ The same equation was also fitted for SES-97 data to be doubly sure of the conclusions drawn here.
The estimate is as below:
$Ln(TC) = 13.79^{*} + 1.43(10)^{-3}\ LAND + 1.96(10)^{-2}\ EDN^{*} + 5.96(10)^{-2}\ ECOD^{**} + 8.91(10)^{-7}\ VINC^{*} + 0.13\ HHS^{*}$
$R^2 = 0.23$  F = 224.32  n = 3761
The coefficient of LAND is positive but statistically not significant.

៨ មេគុណនៃចំណងទាក់ទងរវាងការកាន់កាប់ដី នឹងទំហំគ្រួសារមានតួលេខធំគួរកត់សំគាល់គឺ ០,៥% តាមទិន្នន័យ SES-99 ។

## ជំពូក ប្រាំបី

# សេចក្តីសន្និដ្ឋាន

ឯកសារនេះ មានគោលបំណងរៀបរាប់ពីស្ថាប័ននានា ដែលទទួលខុសត្រូវក្នុងការផ្តល់ប័ណ្ណប្រើប្រាស់ដីធ្លី និងការផ្តល់សម្បទាន បន្ទាប់មកនឹងធ្វើការពណ៌នាខ្លីៗពីប្រភេទផ្សេងៗនៃសម្បទានដែលមានផ្តល់ហើយរហូតមកដល់សព្វថ្ងៃ ។ ការពិពណ៌នាពីការប្រើប្រាស់ដីក្នុងទំរង់ផ្សេងៗ ក៏ត្រូវបានលើកឡើងនៅក្នុងឯកសារនេះដែរ ។ បន្ទាប់មកមានការអធិប្បាយលំអិតពីការធ្វើប្លង់ដីក្នុងរយៈពេលកន្លងមក ។ នៅចុងបញ្ចប់ មានធ្វើការវិភាគលំអិតលើកំរងទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ចផ្សេងៗ ។ ក្នុងនេះមានការប្រឹងប្រែងរាប់ចំនួនដីឡូតិ៍នៅកម្ពុជា, គណនាទំហំឡូតិ៍មធ្យម និងកំណត់អំពីកំរិតនៃភាពគ្មានដីធ្លី និងវិសមភាពដី ។

ឯកសារនេះ មិនប៉ុនប៉ងធ្វើការវិភាគសង្គមកិច្ច-សេដ្ឋកិច្ចលំអិត ឬធ្វើការបង្កើតជាគំរូស្មុគស្មាញជាមួយនឹងទិន្នន័យទាំងនេះឡើយ ។ ប៉ុន្តែគោលបំណងចំបងគឺការធ្វើសារពើភ័ណ្ឌនូវកំរងទិន្នន័យនានាដែលមានស្រាប់ ដូច្នេះពុំមានការសន្និដ្ឋានវែងឆ្ងាយទេ ។ ការសន្និដ្ឋាននានា ជាចំបងបានមកពីការប្រើប្រាស់កំរងទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ចនានាដែលត្រូវបានលើកយកមកវិភាគនៅទីនេះ។ ការសិក្សានេះមួយចំណែក គឺជាការពង្រីកបន្ថែមលើការងារកន្លងមករបស់ វបសអ ក្នុងប្រធានបទដីធ្លី ប៉ុន្តែមានការលើកបញ្ហាថ្មីមួយចំនួនដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទិន្នន័យទាំងនេះ និងការវិភាគកំរងទិន្នន័យបន្ថែមមួយចំនួន ។ អនុសាសន៍មួយចំនួនដូចខាងក្រោមត្រូវបាន លើកឡើងដើម្បីពង្រឹងមូលដ្ឋានទិន្នន័យដែលត្រូវយកមកប្រើប្រាស់ជាជំនួយក្នុងការធ្វើផែនការគ្រប់គ្រងដីធ្លី ។

### អនុសាសន៍

១. ទិន្នន័យស្តីពីការប្រើប្រាស់ដី គួរពង្រឹងឡើង និងដាក់នៅក្រោមការកាន់កាប់របស់អាជ្ញាធរតែមួយ ។ វិធីនេះនឹងធ្វើឱ្យមានការបន្សុីគ្នានូវចំនុចខុសគ្នាក្នុងទិន្នន័យ ដែលកើតចេញពីការប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា និង/ឬការកំណត់តំបន់គ្របដណ្តប់ខុសៗគ្នា និងរវាងកំរងទិន្នន័យនានាដែលមានស្រាប់នៅតាមក្រសួង-មន្ទីរនានា ឬដែលស្ថាប័នទាំងនេះបានប្រមូលឡើងជាប្រចាំ ។

២. គួរមានកាន់កាប់បញ្ជីកត់ត្រាជាលក្ខណៈវិទ្យាសាស្ត្រនូវព័តិមានស្តីពី សម្បទានដែលបានផ្តល់ទាំងអស់ ដូចជា សម្បទានព្រៃឈើ កសិកម្ម និងនេសាទ ។ គួរមានការធ្វើចរន្តការពតិមានស្តីពីសម្បទាន ក៏ដូចជាការត្រួតពិនិត្យសកម្មភាពនៃសម្បទានដែរ ។ លើសពីនេះទៀត ការបើកចំហទិន្នន័យទាំងនេះចំពោះមជ្ឈដ្ឋានអ្នកត្រូវការប្រើប្រាស់ នឹងធានាឱ្យមានតម្លាភាពខ្ពស់ឡើង ព្រមទាំងការត្រួតពិនិត្យសកម្មភាពរបស់ម្ចាស់សម្បទានិកផង ។

៣. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចផ្សេងៗដែលបានលើកយកមកពិភាក្សានៅក្នុងឯកសារនេះ ត្រូវបានធ្វើឡើងដោយស្ថាប័នផ្សេងៗគ្នា សំរាប់គោលដៅខុសៗគ្នា និងផ្តោតលើតំបន់ខុសគ្នាៗដែរ ។ ជាលទ្ធផល ការប្រៀបធៀបអង្កេតទាំងនេះបានចោទការលំបាក ពីព្រោះគេអាចធ្វើការប្រៀបធៀបតែក្នុងកំរិតណាមួយប៉ុណ្ណោះ ។ ការបង្កើតមូលដ្ឋានទិន្នន័យមួយដ៏រឹងមាំដើម្បីធានាឱ្យមានការពិតជាក់ស្តែង គឺជាការចាំបាច់បំផុត ។

៤. ក្នុងពេលបច្ចុប្បន្ន ចំនួនសរុបនៃដីឡូត៍ គ្រួសារ ដីលំនៅដ្ឋាន ។ល។ អាចទាញយកបានពីអង្កេតដែលមានគំរូតាងតំណាងឱ្យទូទាំងប្រទេស ដូចជា SES-97 និង SES-99, ជាជាងអង្កេតដទៃទៀតដែលដៅលើតំបន់ជាក់លាក់ មិនគ្របដណ្តប់ទូទាំងប្រទេស ឬមិនអាចបង្កើតមេគុណឬទំងន់បាន, ដើម្បីបង្ហាញនូវទិដ្ឋភាពរួមទូទាំងប្រទេស ។ ការធ្វើអង្កេតជាប្រចាំដែលអាចប្រៀបធៀបគ្នាបាន ដូចជា SES ដែលធ្វើដោយវិទ្យាស្ថានជាតិស្ថិតិជាដើម គឺជាការសំខាន់ណាស់ ។

៥. ក្នុងចំនោមអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចដែលមានស្រាប់ គ្មានមួយណាសោះដែលផ្តោតទាំងស្រុង ឬក្នុងចំណែកណាមួយ ទៅលើបញ្ហាដីធ្លីដោយចំៗ ។ មានតែអង្កេត LADIT ទេ ដែលពិនិត្យសុទ្ធសាធពីបញ្ហាដីធ្លី ប៉ុន្តែក៏មិនបានសព្វគ្រប់ល្អដែរ ទាំងក្នុងខ្លឹមសារបញ្ជីសំនួរ ទាំងក្នុងលក្ខណៈតំណាងឱ្យប្រទេសទាំងមូល ។ ដូច្នេះគឺមានតំរូវការអង្កេតបែបបរិមាណមួយដែលផ្តោតតែទៅលើដីធ្លីមួយមុខយ៉ាងខ្លាំង ។ នៅប្រទេសដទៃទៀត កន្លងមកគេបានធ្វើអង្កេតដីធ្លីជាច្រើនហើយ ។ មជ្ឈមណ្ឌលនៃការកាន់កាប់ដីធ្លីនៃសាកលវិទ្យាល័យវីសកុនស៊ិននៅសហរដ្ឋអាមេរិក មានកាន់កាប់បញ្ជីសារពើភ័ណ្ឌដ៏មានប្រយោជន៍ស្តីពីទិន្នន័យ និងវិធីសាស្ត្រធ្វើអង្កេត ។ ឯកសារដែលប្រមូលផ្តុំនៅ FAO ជាពិសេស ឯកសារក្រោយពីសន្និសីទអន្តរជាតិស្តីពីកំណែទំរង់កសិកម្ម និងអភិវឌ្ឍន៍ជនបទ ក៏អាចជាជំនួយផងដែរ ។

# ឯកសារយោង


ADB (2001), Environment in Transition: Cambodia, Lao PDR, Thailand Vietnam (Manila)

Biddulph, R. (2000), Making the Poor Visible (Phnom Penh: Cambodia Land Study Project, Oxfam)

Dreze, J. and A. Sen (1991), Hunger and Public Action (Helsinki: WIDER)

Godfrey, M., S. So, S. Tep, C. Katz, D. Pon, S. Acharya, S. Chanto and H Thoraxy (2001), "A Study of the Cambodian Labour Market: Reference to Poverty Reduction, Growth and Adjustment to Crisis", in Development Analysis Network (ed.), Labour Markets in Transitional Economies of Southeast Asia and Thailand (Phnom Penh)

Helmers, K. and E. Kenefick (1999), The UN World Food Programme Protracted Emergency Target Project (PET) Surveys of Households in Cambodian Communes Affected by Civil Conflict Since 1989 (Phnom Penh: World Food Programme)

Gibson, J. (2000), "A Poverty Profile of Cambodia, 1999", draft report submitted to the World Bank and the Ministry of Planning (Phnom Penh), (Mimeo: Washington: The World Bank--Poverty Reduction and Economic Management Sector Unit)

Mellor, J. and G. Desai (eds.) (1985), Agricultural Change and Rural Poverty (Baltimore: Johns Hopkins University Press)

Murshid, K.A.S, (1998) Food Security in an Asian Transitional Economy: The Cambodian Experience, Working Paper 6, Phnom Penh: Cambodia Development Resource Institute.

RGC (1998), Cambodia: National Environment Action Plan, (Phnom Penh: Ministry of Environment)

RGC (1999), General Population Census 1998 (Phnom Penh: NIS)

RGC (2000), Cambodia Socio-Economic Survey (Phnom Penh: NIS)

Sik, B. (2000), Land Ownership, Sales and Concentration in Cambodia, Working Paper #16, (Phnom Penh: Cambodia Development Resource Institute)

So, S., S. Real, U. Uch, R. Sy, B. Ballard and S. Acharya (2001), Social Assessment of Land in Cambodia, (Phnom Penh: Cambodia Development Resource Institute)

Srinivasan, T.N. and P.K. Bardhan (eds.) (1988), Rural Poverty in South Asia, (New York: Columbia University Press)

van Acker, F. (1999), Hitting the Stone with an Egg? Cambodia's Rural Economy and Land Tenure in Transition, Discussion Paper (Antwerp: Centre for Asian Studies)

Visaria, P. (1981), Poverty and Unemployment, World Development, Vol. 9, No. 5

Williams, S. (1999), Review of Secondary Sources Relating to Land Tenure and Access Issues in Cambodia, Phnom Penh: Oxfam GB.

World Bank (2001), World Development Report (Washington)

# សេចក្តីបន្ថែម

## ១. ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ១៩៩៦

*ផ្នែកទី៥. ទ្រព្យសកម្ម និងទ្រព្យអសកម្មរបស់គ្រួសារ*

*ការកាន់កាប់ដី*

| Q30. តើគ្រួសារអ្នកមានដីកម្មសិទ្ធិ ឬកាន់កាប់ដែរ ឬទេ? | Q31. តើដីរបស់អ្នកជាដីប្រភេទណា?<br><br>១ មាន<br>២ គ្មាន (ចោលសំណួរពី Q31 ដល់ Q34) | Q32. តើស្ថានភាពកម្មសិទ្ធិដីអ្នកយ៉ាងណាដែរ?<br><br>១ មានកម្មសិទ្ធិ<br>២ ជួលពីគេ (សួរបន្តទៅ Q34)<br>៣ កាន់កាប់ដោយសេរី (សួរបន្តទៅ Q34)<br>៤ កម្មសិទ្ធិមិនទាន់ដោះស្រាយរួច (សួរបន្តទៅ Q34) | Q33. តើដីរបស់អ្នកមានឯកសារដែលចេញដោយនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្មដែរឬទេ?<br><br>១ មាន<br>២ គ្មាន<br>៣ មិនដឹង | Q34. តើដីរបស់មានទំហំប៉ុណ្ណា?<br><br>១ តិចជាងកន្លះហិកតា<br>២ កន្លះហិកតា ទៅមួយហិកតា<br>៣ មួយហិកតា ទៅពីរហិកតា<br>៤ ច្រើនជាងពីរហិកតា |
|---|---|---|---|---|
| ១ = មាន<br>២ = គ្មាន<br>(តទៅ Q35 ) | ១ ដីលំនៅដ្ឋាន | | | |
| | ២ ដីកសិកម្ម | | | |
| | ៣ ផ្សេងៗទៀត | | | |

## ២. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ១៩៩៩

*បញ្ជីសំណួរស្តង់ស សំរាប់សួរគ្រួសារ* (CSES FORM 3)

VII . *ទ្រព្យសកម្ម និងទ្រព្យអសកម្មរបស់គ្រួសារ*

*Q22.* តើគ្រួសារអ្នកមានកម្មសិទ្ធិ ឬរស់នៅលើដី និងសំណង់ដែលប្រើប្រាស់សំរាប់លំនៅដ្ឋាន ពាណិជ្ជកម្ម និង ឧស្សាហកម្ម ដែរឬទេ (ចុះលេខកូដ)?

១ = មាន ២ = គ្មាន (>>Q .23) □ (បើមាន សូមផ្តល់នូវពត៌មានខាងក្រោម)

| ប្រភេទ | ដីលំនៅដ្ឋាន និងសំណង់ | | ដីផ្សេងទៀត និងសំណង់ ដែលប្រើប្រាស់ សំរាប់លំនៅដ្ឋាន ពាណិជ្ជកម្ម និងឧស្សាហកម្ម | |
|---|---|---|---|---|
| | ផ្ទៃក្រឡា (ម៉ែត្រក្រឡា) | តំលៃទីផ្សារ (រៀល) | ផ្ទៃក្រឡា (ម៉ែត្រក្រឡា) | តំលៃទីផ្សារ (រៀល) |
| (១) | (២) | (៣) | (៥) | (៦) |
| ២២.១ កាន់កាប់ដោយមានប្លង់ ហើយរស់នៅ | | | | |
| ២២.២ កម្មសិទ្ធិមិនទាន់ដាច់ស្រេច ឬកាន់កាប់ដោយសេរី | | | | |
| ២២.៣ ជួល | | | | |

### ម៉ូឌុលអំពីចំណូល និងការងារ (CSES FORM 4)

*សកម្មភាពកសិដ្ឋាន និងចំណូលពីកសិដ្ឋាន*

**ក. ដីកសិដ្ឋាន**

*Q4.* តើមានដីកសិកម្មប៉ុន្មានដែលគ្រួសារអ្នកមានកម្មសិទ្ធិ ឬបានកាន់កាប់នៅក្នុងរដូវវស្សា និងប្រាំងកន្លងមក?

| ដីឡូត៍លេខ | ស្ថានភាពកម្មសិទ្ធិ | ផ្ទៃក្រឡា | | តើដីនេះថ្លៃប៉ុន្មាន បើលក់ក្នុងពេលបច្ចុប្បន្ន? |
|---|---|---|---|---|
| | | ចំនួន | ឯកតា | |
| (១) | (៣) | (៤ក) | (៤ខ) | (៧) |
| | | | | |
| | | | | |
| | | | | |

**លេខកូដ**

ស្ថានភាពកម្មសិទ្ធិ: (បង្គោលទី៤ក) ១=ជាកម្មសិទ្ធិ និងគ្រប់គ្រង ២=ជាកម្មសិទ្ធិប៉ុន្តែជួលឱ្យគេ ៣=ជួលពីគេ ៤=កម្មសិទ្ធិមិនទាន់ដាច់ស្រេច (កាន់កាប់ដោយសេរី)

លេខកូដឯកតា (បង្គោលទី៤ខ): ១=ម៉ែត្រក្រឡា ២=អារ ៣=ហិកតា ៤=រ៉ៃ ៥=កុង ៦=ផ្សេងទៀត

## បញ្ជីសំណួរ LANDIT




Group Discussion:
Families who are likely to lose their land in the next two years: 0
Families now landless but will probably acquire land in next two years 0
Changes in landlessness over time:
1969 population 0
1969 landless 0
1984 population 0
1984 landless 0
1999 population 0
1999 landless 0
2001 population 0
2001 landless 0
Families who left the village because they lost their land since 1979: 0
Situation reasons for landlessness:
Village code 0
Family/Community 0
Cause code 0
Cause
Notes
Record: 1 of 1
Impact of development activities on landlessness:
Record: 184 of 184
Select a name from tblDataEntryOperator

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជាៈ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូល ជំនួយស្រពិចស្រពិលៈ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេរ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) *ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនត្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និង រ៉ូប៊ីន-ប៊ុដឺលរី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.000រៀល ។

៥. Toshiyasu Kato ច័ន្ទ-សុផល និង ឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.000រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ីៈ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៨. ច័ន្ទ-សុផល Martin Godfrey, Toshiyasu Kato ឡុង-វូ-ពិសិដ្ឋ Nina Orlova, Per Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជាៈ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរតំលៃ ៦.000រៀល ។

៩. តេង-យូគី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនត្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ្ង ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ារ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គីមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ។

១៦. ស៊ិក បូរ៉ាក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល, សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ, ទេព-សារ៉ាវី, ប៊ុន-ដូរីណា, Claude Katz, Sarthi Acharya, ស៊ីសុវត្ថិ ឌូង ចាន់តូ, និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។